ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

# (គ.ជ.ប)

# សៀវភៅណែនាំ

ស្តីពី

# ការចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយ និង នីតិវិធីនៃការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹង សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២

# មាតិកា

**ទំព័រ**

**អក្សរកាត់**---------------------------------------------------------------------------------------- i

**គោលបំណង** ---------------------------------------------------------------------------------ii

**ជំពូកទី ១ ការចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយ** ----------------------------១

១. ភាពមានសិទ្ធិឈរឈ្មោះជាបេក្ខជន ----------------------------------------១

២. ភាពគ្មានសិទ្ធិឈរឈ្មោះជាបេក្ខជន ----------------------------------------១

៣. ការដាក់ពាក្យសុំច្បាប់ឈប់ពិសេស ------------------------------------------១

៤. ការដាក់ពាក្យសុំចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយ ------------- ២

៥. ការទទួលពាក្យសុំចុះបញ្ជីបេក្ខជនដោយ គឃ.សប --------------------៤

៦. ការបិទផ្សាយបញ្ជីបេក្ខជននៃគណបក្សនយោបាយ ---------------------៥

៧. ការពិនិត្យ និងសម្រេចរបស់ គឃ.សប លើពាក្យសុំចុះបញ្ជីបេក្ខជន--------៥

**ជំពូកទី ២ នីតិវិធីនៃការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្ដឹង** ----- ៧

**ផ្នែកទី ១ ការប្ដឹងតវ៉ា ឬការប្ដឹងជំទាស់**------------------------------------------ ៧

១. ពាក្យបណ្ដឹង ------------------------------------------------------------------- ៧

២. ការរាប់ចំនួនថ្ងៃតវ៉ា ឬថ្ងៃជំទាស់ និងការសម្រេចលើពាក្យបណ្ដឹងតវ៉ា ឬពាក្យបណ្ដឹងជំទាស់ -----------------------------------------------------៨

**ផ្នែកទី ២ បណ្ដឹងក្នុងដំណាក់កាលចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយ សម្រាប់ឈរឈ្មោះបោះឆ្នោត** ---------------------------------------៩

១. ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្ដឹងនៅ គធ.ខប --------៩

១.១ ការដាក់ និងការទទួលពាក្យបណ្ដឹងនៅ គធ.ខប------------------៩

១.២ ការដោះស្រាយពាក្យបណ្ដឹងនៅ គធ.ខប -------------------------៩

២. ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្ដឹងនៅ គ.ជ.ប ------- ១០

២.១ ការដាក់ និងការទទួលពាក្យបណ្ដឹងនៅ គ.ជ.ប --------------- ១០

២.២ ការដោះស្រាយពាក្យបណ្ដឹងនៅ គ.ជ.ប----------------------- ១០

**ផ្នែកទី ៣ បណ្ដឹងក្នុងដំណាក់កាលបិទផ្សាយបញ្ជីបេក្ខជនដំបូង**----------១៣

១. ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្ដឹងនៅ គ.ជ.ប ---១៣

១.១ ការដាក់ និងការទទួលពាក្យបណ្ដឹងនៅ គ.ជ.ប--------------------១៣

១.២ ការដោះស្រាយពាក្យបណ្ដឹងនៅ គ.ជ.ប----------------------------១៣

**ផ្នែកទី ៤ នីតិវិធីនៃការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹង ក្នុងដំណាក់កាលឃោសនាបោះឆ្នោត និងនៅមួយថ្ងៃមុនថ្ងៃបោះឆ្នោត និងនៅថ្ងៃបោះឆ្នោត និងរាប់សន្លឹកឆ្នោត ចំពោះគ្រប់អំពើចំពានលើបទប្បញ្ញត្តិនៃជំពូកទី ១៤ នៃ ច.ប.ឃ.ស ដែលអាចនាំឱ្យមានការផាកពិន័យ** ------------------------------------ ១៥

**I. ពាក្យបណ្តឹងដែលពាក់ព័ន្ធនឹងជនមិនមែនជាមន្ត្រីបោះឆ្នោត ឬគណបក្សនយោបាយ**------------------------------------------------------------ ១៥

១. ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងនៅ គឃ.សប-----១៥

១.១ ការដាក់ និងការទទួលពាក្យបណ្តឹងនៅ គឃ.សប------------ ១៥

១.២ ការដោះស្រាយពាក្យបណ្តឹងនៅ គឃ.សប --------------------១៧

២. ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងនៅ គធ.ខប ----- ២០

២.១ ការដាក់ និងការទទួលពាក្យបណ្តឹងនៅ គធ.ខប -------------- ២០

២.២ ការដោះស្រាយពាក្យបណ្តឹងនៅ គធ.ខប ---------------------២២

៣. ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងនៅ គ.ជ.ប ----------២៥

៣.១ ការដាក់ និងការទទួលពាក្យបណ្តឹងនៅ គ.ជ.ប --------------- ២៥

៣.២ ការដោះស្រាយពាក្យបណ្តឹងនៅ គ.ជ.ប------------------------២៦

**II. ពាក្យបណ្តឹងពាក់ព័ន្ធនឹងជនជាមន្ត្រីបោះឆ្នោត**-------------------------៣០

**ផ្នែកទី ៥ បណ្តឹងទាក់ទងនឹងភាពមិនប្រក្រតីនៅមួយថ្ងៃមុនថ្ងៃបោះឆ្នោត និងក្នុងថ្ងៃបោះឆ្នោត**--------------------------------------------- ៣២

១. ការតវ៉ា ឬការជំទាស់ និងការដោះស្រាយ នៅ គ.ក.ប/គ.ក.រ ----------------៣២

១.១ ការតវ៉ា ឬការជំទាស់នៅ គ.ក.ប/គ.ក.រ -------------------------៣២

១.២ ការដោះស្រាយការតវ៉ា ឬការជំទាស់នៅ គ.ក.ប/គ.ក.រ------ ៣២

២. ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងនៅ គឃ.សប -----៣៣

២.១ ការដាក់ និងការទទួលពាក្យបណ្តឹងនៅ គឃ.សប----------- ៣៣

២.២ ការដោះស្រាយពាក្យបណ្តឹងនៅ គឃ.សប --------------------៣៤

៣. ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងនៅ គធ.ខប-------៣៦

៣.១ ការដាក់ និងការទទួលពាក្យបណ្តឹងនៅ គធ.ខប --------------៣៦

៣.២ ការដោះស្រាយពាក្យបណ្តឹងនៅ គធ.ខប --------------------- ៣៧

៤. ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងនៅ គ.ជ.ប ------- ៤១
៤.១ ការដាក់ និងការទទួលពាក្យបណ្តឹងនៅ គ.ជ.ប --------------- ៤១
៤.២ ការដោះស្រាយពាក្យបណ្តឹងនៅ គ.ជ.ប------------------------ ៤២
**ផ្នែកទី ៦ នីតិវិធីអនុវត្តសេចក្តីសម្រេចស្ថាពរចំពោះការដាក់ទណ្ឌកម្ម ពិន័យជាប្រាក់** ------------------------------------------------------------------ ៤៥
**ជំពូកទី ៣ សមត្ថកិច្ច និងនីតិវិធីប្រជុំផ្សះផ្សា ប្រជុំសម្រេច និងសវនាការ ដោះស្រាយពាក្យបណ្តឹង** ------------------------------------------------------------ ៤៦
**ផ្នែកទី ១ សមាសភាព និងសិទ្ធិអំណាចរបស់ក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬ ក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះ**------------------ ៤៦
១. សមាសភាពក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាប្រជុំសម្រេច ឬ ក្រុមប្រឹក្សាជំនុំជម្រះ ------------------------------------------------------- ៤៦
១.១ ក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាប្រជុំសម្រេចនៃ គឃ.សប ----៤៦
១.២ ក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាជំនុំជម្រះនៃ គធ.ខប -----៤៧
១.៣ ក្រុមប្រឹក្សាជំនុំជម្រះនៃ គ.ជ.ប---------------------------------៤៧
២. សិទ្ធិអំណាចរបស់ក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាប្រជុំសម្រេច ឬ ក្រុមប្រឹក្សាជំនុំជម្រះ --------------------------------------------------------- ៤៨
២.១ ក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាប្រជុំសម្រេចនៃ គឃ.សប --- ៤៨
២.២ ក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាជំនុំជម្រះនៃ គធ.ខប -- ៤៨
២.៣ ក្រុមប្រឹក្សាជំនុំជម្រះនៃ គ.ជ.ប--------------------------------- ៤៩
**ផ្នែកទី២ សិទ្ធិ និងកាតព្វកិច្ចរបស់គូភាគី ដើមបណ្តឹង ចុងចម្លើយ មេធាវី ឬតំណាង**---------------------------------------------------------------- ៥០
១. សិទ្ធិ និងកាតព្វកិច្ចរបស់គូភាគី ------------------------------------------ ៥០
២. សិទ្ធិ និងកាតព្វកិច្ចរបស់ដើមបណ្តឹង ------------------------------------ ៥១
៣. សិទ្ធិ និងកាតព្វកិច្ចរបស់ចុងចម្លើយ -------------------------------------- ៥២
៤. សិទ្ធិ និងកាតព្វកិច្ចរបស់មេធាវី ឬតំណាង------------------------------ ៥២
៥. សិទ្ធិ និងកាតព្វកិច្ចរបស់សាក្សី --------------------------------------------- ៥២
**ផ្នែកទី ៣ នីតិវិធីប្រជុំផ្សះផ្សា ឬប្រជុំសម្រេច ឬសវនាការ**------------- ៥៤
១. ប្រភេទសវនាការ------------------------------------------------------------- ៥៤
២. ភាសាដែលប្រើក្នុងការប្រជុំផ្សះផ្សា ឬប្រជុំសម្រេច ឬសវនាការ ------------៥៥

៣. ពេលវេលាដោះស្រាយពាក្យបណ្ដឹង-------------------------------------------៥៥
៤. ការជូនដំណឹងបើកអង្គប្រជុំផ្សះផ្សា ឬបើកអង្គប្រជុំសម្រេច ឬបើកសវនាការ------------------------------------------------------------------------------------------ ៥៥
៤.១ ការជូនដំណឹងបើកអង្គប្រជុំផ្សះផ្សា ឬអង្គប្រជុំសម្រេចនៅ គឃ.សប-- ៥៥
៤.២ ការជូនដំណឹងបើកអង្គប្រជុំផ្សះផ្សា ឬបើកសវនាការនៅ គធ.ខប ------ ៥៥
៤.៣ ការជូនដំណឹងបើកសវនាការនៅ គ.ជ.ប ---------------------- ៥៦
៥. ភារកិច្ចរបស់លេខាធិការអង្គប្រជុំផ្សះផ្សា ឬលេខាធិការអង្គប្រជុំសម្រេច ឬលេខាធិការសវនាការ ឬគណៈលេខាធិការសវនាការ------------- ៥៦
៦. ការរៀបចំកន្លែង និងរបៀបរបបការងាររបស់ក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះ-----------------------៥៧
៧. ការបង្ហាញខ្លួននៅពេលប្រជុំផ្សះផ្សា ឬប្រជុំសម្រេច ឬសវនាការ -- ៥៩
៨. មធ្យោបាយបង្ហាញភស្តុតាង ------------------------------------------ ៦០
៩. ការបំពេញ និងការប្រើប្រាស់ ទ.១២០៣------------------------------ ៦០
១០. ទម្រង់បែបបទផ្សេងៗទៀត សម្រាប់ការប្រជុំផ្សះផ្សា ការប្រជុំសម្រេច និងសវនាការ ------------------------------------------------------------ ៦២
**ឧបសម្ព័ន្ធ** ----------------------------------------------------------------------------៦៣
**ឧបសម្ព័ន្ធទី ១ ៖ ពាក្យសុំចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយ និងសេចក្ដីសម្រេចរបស់ គឃ.សប (ទ.១០០៨)**-----------៦៣
**ឧបសម្ព័ន្ធទី ២ ៖ កំណត់ហេតុនៃការចាប់ឆ្នោតដើម្បីកំណត់លំដាប់លេខរៀងគណបក្សនយោបាយដែលត្រូវដាក់លើសន្លឹកឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១២១)** ----------------------------------៧១
**ឧបសម្ព័ន្ធទី ៣ ៖ ទម្រង់បែបបទពាក្យបណ្ដឹង (ទ.១២០២)** -------------៧២
**ឧបសម្ព័ន្ធទី ៤ ៖ ទម្រង់បែបបទសម្រង់សេចក្ដីសម្រេច (ទ.១២០៣)** ----- ៧៣
**ឧបសម្ព័ន្ធទី ៥ ៖ បទបញ្ជាផ្ទៃក្នុងពេលបើកអង្គប្រជុំផ្សះផ្សា ឬអង្គប្រជុំសម្រេច ឬសវនាការដោះស្រាយពាក្យបណ្ដឹង** -------៧៤
**ឧបសម្ព័ន្ធទី ៦ ៖ នីតិវិធី និងខ្លឹមសារនៃសម្បថ** -------------------------៧៥

# អក្សរកាត់

| | |
|---|---|
| - គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត | គ.ជ.ប |
| - គណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត | គធ.ខប |
| - លេខាធិការដ្ឋាននៃគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត | លគធ.ខប |
| - ក្រុមប្រឹក្សាឃុំ សង្កាត់ | កបឃ.ស |
| - គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត | គឃ.សប |
| - គណៈកម្មការការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត | គ.ក.ប/គ.ក.រ |
| - ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត | ច.គ.ជ.ប |
| - ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ | ច.ប.ត.រ |
| - ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ | ច.ប.ឃ.ស |
| - បទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ | ប.ន.ឃ.ស |
| - អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ | អ.ខ |
| - ឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការបោះឆ្នោត | ឯ.អ |
| - ទម្រង់បែបបទលេខ | ទ. |
| - ពាក្យសុំចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយ និងសេចក្តីសម្រេចរបស់ គឃ.សប | ទ.១០០៨ |
| - កំណត់ហេតុនៃការចាប់ឆ្នោតដើម្បីកំណត់លំដាប់លេខរៀងគណបក្សនយោបាយដែលត្រូវដាក់លើសន្លឹកឆ្នោតក្នុងឃុំ សង្កាត់ | ទ.១១២១ |
| - ទម្រង់បែបបទពាក្យបណ្តឹង | ទ.១២០២ |
| - ទម្រង់បែបបទសម្រង់សេចក្តីសម្រេច | ទ.១២០៣ |

# គោលបំណង

សៀវភៅណែនាំស្តីពី**ការចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយ និងនីតិវិធីនៃការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២** នេះ ត្រូវបានរៀបចំឡើងដោយផ្អែកលើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ (ច.ប.ឃ.ស) និងបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ (ប.ន.ឃ.ស) អាណត្តិទី៥ ឆ្នាំ២០២២។ សៀវភៅណែនាំនេះរៀបចំឡើងដើម្បីជាជំនួយស្មារតីសម្រាប់មន្ត្រីបោះឆ្នោត និងភាគីពាក់ព័ន្ធទាំងអស់ ឱ្យបានយល់ដឹងអំពីការចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយ និងនីតិវិធីនៃការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងក្នុងដំណើរការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២។ សៀវភៅណែនាំនេះចែកចេញជាបីជំពូក ៖

**ជំពូកទី ១** បង្ហាញអំពីការចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយសម្រាប់ឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់។

**ជំពូកទី ២** បង្ហាញដោយសង្ខេបអំពីនីតិវិធីនៃការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹង នៅគ្រប់ដំណាក់កាលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់។

**ជំពូកទី ៣** បង្ហាញដោយសង្ខេបអំពីសមត្ថកិច្ច និងនីតិវិធីប្រជុំផ្សះផ្សា ឬប្រជុំសម្រេច ឬសវនាការដោះស្រាយពាក្យបណ្តឹង ដែលកើតមានឡើងនៅគ្រប់ដំណាក់កាល ដែលក្នុងនោះមានជាអាទិ៍ សមាសភាពក្រុមប្រឹក្សាប្រជុំផ្សះផ្សា ក្រុមប្រឹក្សាប្រជុំសម្រេច ក្រុមប្រឹក្សាជំនុំជម្រះ ប្រភេទសវនាការ សិទ្ធិ និងកាតព្វកិច្ចរបស់ភាគីពាក់ព័ន្ធនឹងពាក្យបណ្តឹង។

ផ្នែកខាងក្រោយនៃសៀវភៅណែនាំនេះមាន ៦ ឧបសម្ព័ន្ធ ៖

- ឧបសម្ព័ន្ធទី ១ ពាក្យសុំចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយ និងសេចក្តីសម្រេចរបស់ គឃ.សប (ទ.១០០៨)
- ឧបសម្ព័ន្ធទី ២ កំណត់ហេតុនៃការចាប់ឆ្នោតដើម្បីកំណត់លំដាប់លេខរៀងគណបក្សនយោបាយដែលត្រូវដាក់លើសន្លឹកឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១២១)
- ឧបសម្ព័ន្ធទី ៣ ទម្រង់បែបបទពាក្យបណ្តឹង (ទ.១២០២)
- ឧបសម្ព័ន្ធទី ៤ ទម្រង់បែបបទសម្រង់សេចក្តីសម្រេច (ទ.១២០៣)
- ឧបសម្ព័ន្ធទី ៥ បទបញ្ជាផ្ទៃក្នុងពេលបើកអង្គប្រជុំផ្សះផ្សា ឬអង្គប្រជុំសម្រេច ឬសវនាការដោះស្រាយពាក្យបណ្តឹង
- ឧបសម្ព័ន្ធទី ៦ នីតិវិធី និងខ្លឹមសារនៃសម្បថ។

# ជំពូកទី ១
# ការចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយសម្រាប់ឈរឈ្មោះ បោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់

## ១. ភាពមានសិទ្ធិឈរឈ្មោះជាបេក្ខជន

ដើម្បីមានសិទ្ធិឈរឈ្មោះជាបេក្ខជន សម្រាប់ការបោះឆ្នោតជ្រើសរើស កបឃ.ស ប្រជាពលរដ្ឋទាំងពីរភេទ ត្រូវបំពេញលក្ខខណ្ឌ ដូចខាងក្រោម ៖

- មានសញ្ជាតិខ្មែរពីកំណើត។
- ចេះអាន និងសរសេរអក្សរខ្មែរ។
- បានចុះឈ្មោះក្នុងបញ្ជីបោះឆ្នោតក្នុងឃុំ សង្កាត់ ដែលខ្លួនមានបំណងឈរឈ្មោះបោះឆ្នោត។
- មានអាយុយ៉ាងតិច ២៥ (ម្ភៃប្រាំ) ឆ្នាំ គិតមកទល់ថ្ងៃបោះឆ្នោតជ្រើសរើស កបឃ.ស ។

## ២. ភាពគ្មានសិទ្ធិឈរឈ្មោះជាបេក្ខជន

ហាមឈរឈ្មោះជាបេក្ខជនបោះឆ្នោតជ្រើសរើស កបឃ.ស ចំពោះ ៖

- សមាជិករដ្ឋសភា សមាជិកព្រឹទ្ធសភា សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ សមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម សមាជិករាជរដ្ឋាភិបាល និងចៅក្រម។
- អភិបាល ឬអភិបាលរងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។
- សមាជិក គ.ជ.ប គធ.ខប គឃ.សប គ.ក.ប បុគ្គលិកបម្រើការងារក្នុង គ.ជ.ប និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់។
- មន្ត្រីរាជការស៊ីវិល មន្ត្រីតុលាការ កងយោធពលខេមរភូមិន្ទ ឬនគរបាលជាតិក្នុងមុខតំណែង។
- ព្រះសង្ឃ ឬបព្វជិតសាសនានៃសាសនាណាមួយ។
- ស្មៀនឃុំ សង្កាត់ណាមួយ។

## ៣. ការដាក់ពាក្យសុំច្បាប់ឈប់ពិសេស

មន្ត្រីរាជការស៊ីវិល មន្ត្រីតុលាការ កងយោធពលខេមរភូមិន្ទ និងនគរបាលជាតិ ដែលមានបំណងឈរឈ្មោះបោះឆ្នោតជ្រើសរើស កបឃ.ស ត្រូវដាក់ពាក្យសុំច្បាប់ឈប់ពិសេសយ៉ាងតិច ៧ (ប្រាំពីរ) ថ្ងៃ មុនថ្ងៃបើកយុទ្ធនាការឃោសនាបោះឆ្នោតរហូតដល់ថ្ងៃប្រកាសលទ្ធផលនៃការបោះឆ្នោតផ្លូវការ។

លិខិតបញ្ជាក់ការអនុញ្ញាតច្បាប់ឈប់ពិសេសពីក្រសួង ឬអង្គភាពអាចភ្ជាប់មកជាមួយពាក្យសុំចុះបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត។ ក្នុងករណីមិនអាចធ្វើទាន់ត្រូវផ្ញើពាក្យសុំច្បាប់ឈប់ពិសេសជូន គឃ.សប ក្នុងរយៈពេលយ៉ាងតិច ៧ (ប្រាំពីរ) ថ្ងៃ មុនថ្ងៃចាប់ផ្ដើមបើកយុទ្ធនាការឃោសនាបោះឆ្នោត។ លិខិតបញ្ជាក់ការអនុញ្ញាតច្បាប់ឈប់ពិសេស ត្រូវបញ្ជាក់ឱ្យបានច្បាស់អំពីឈ្មោះសាមីជនដែលបានសុំច្បាប់ឈប់ពិសេស មុខតំណែង ក្រសួង ឬអង្គភាព ដែលសាមីជនកំពុងបម្រើការងារ កាលបរិច្ឆេទសុំច្បាប់ឈប់ពិសេស និងមានហត្ថលេខារបស់ថ្នាក់ដឹកនាំរបស់ខ្លួន ពោលគឺនៅថ្នាក់លើមួយថ្នាក់ដែលខ្លួននៅក្រោមឱវាទ។

## ៤. ការដាក់ពាក្យសុំចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយ

ដើម្បីឈរឈ្មោះបោះឆ្នោតជ្រើសរើស កបឃ.ស គណបក្សនយោបាយត្រូវដាក់ពាក្យសុំចុះបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត តាមការកំណត់របស់ គ.ជ.ប ទៅ គឃ.សប យ៉ាងតិច ៩០ (កៅសិប) ថ្ងៃ មុនថ្ងៃបោះឆ្នោត។

**ក.** គណបក្សនយោបាយ ត្រូវបំពេញពាក្យសុំចុះបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត និងសេចក្ដីសម្រេចរបស់ គឃ.សប (ទ.១០០៨) ចំនួន ២ (ពីរ) ច្បាប់។ ពាក្យសុំចុះបញ្ជីបេក្ខជននេះ ត្រូវបានផ្ដល់ដោយឥតគិតថ្លៃជូនគណបក្សនយោបាយ ដែលមានបំណងចុះបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត។

**ខ.** ពាក្យសុំត្រូវចុះហត្ថលេខាដោយប្រធានគណបក្សនយោបាយ ឬតំណាងដែលបានទទួលការផ្ទេរសិទ្ធិជាលាយលក្ខណ៍អក្សរពីប្រធានគណបក្សនយោបាយនោះ។ ការផ្ទេរសិទ្ធិនេះ មិនអនុញ្ញាតឱ្យផ្ទេរសិទ្ធិបន្តឡើយ លើកលែងតែក្នុងលិខិតផ្ទេរសិទ្ធិនោះមានខ្លឹមសារអនុញ្ញាតឱ្យផ្ទេរសិទ្ធិបន្ត។

**គ.** ពាក្យសុំចុះបញ្ជីបេក្ខជនត្រូវភ្ជាប់មកជាមួយនូវ ៖

១- សេចក្ដីចម្លងលិខិតបញ្ជាក់ការចុះបញ្ជីគណបក្សនយោបាយនៅក្រសួងមហាផ្ទៃ ចំនួន ១ (មួយ) ច្បាប់។

២- អាសយដ្ឋាននៃទីស្នាក់ការកណ្ដាលគណបក្សនយោបាយ អាសយដ្ឋានទីស្នាក់ការគណបក្សនយោបាយក្នុងឃុំ សង្កាត់ និងឈ្មោះតំណាងប្រចាំទីស្នាក់ការគណបក្សនយោបាយក្នុងឃុំ សង្កាត់ ដែលបានដាក់ស្នើបញ្ជីបេក្ខជន។

៣- បញ្ជីរាយនាមបេក្ខជនចំនួន ៧ (ប្រាំពីរ) ច្បាប់ ដែលមានចំនួនបេក្ខជនយ៉ាងហោចណាស់ស្មើនឹង ២ (ពីរ) ដង នៃចំនួនសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់។ គឃ.សប ត្រូវរក្សាឱ្យបានបញ្ជីរាយនាមបេក្ខជនទាំង ៧ (ប្រាំពីរ) ច្បាប់ ដើម្បីប្រើប្រាស់ ៖
- ១ (មួយ) ច្បាប់ បិទផ្សាយនៅទីស្នាក់ការ គឃ.សប ក្រោយពេលទទួលពាក្យសុំចុះបញ្ជីបេក្ខជន
- ១ (មួយ) ច្បាប់ បិទផ្សាយនៅទីស្នាក់ការ គឃ.សប ជាបញ្ជីបេក្ខជនដំបូង
- ១ (មួយ) ច្បាប់ បិទផ្សាយនៅទីស្នាក់ការ គឃ.សប ជាបញ្ជីបេក្ខជនផ្លូវការ
- ១ (មួយ) ច្បាប់ តម្កល់ទុកជាឯកសារនៅ គឃ.សប
- ១ (មួយ) ច្បាប់ ផ្ញើជូន គធ.ខប
- ១ (មួយ) ច្បាប់ ផ្ញើជូន គ.ជ.ប
- ១ (មួយ) ច្បាប់ ជូនសាមីគណបក្សនយោបាយ។

៤- លិខិតបញ្ជាក់ពីមេឃុំ ចៅសង្កាត់ថា ពិតជាបានចុះឈ្មោះ និងមានឈ្មោះក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោតក្នុងឃុំ សង្កាត់ ដែលខ្លួនមានបំណងឈរឈ្មោះបោះឆ្នោត ដោយបញ្ជាក់ឱ្យបានច្បាស់អំពីនាមត្រកូល នាមខ្លួន និងអាសយដ្ឋាន។ មេឃុំ ចៅសង្កាត់ត្រូវចេញលិខិតបញ្ជាក់ជូនតាមការស្នើសុំ ក្នុងរយៈពេលយ៉ាងយូរ ៣ (បី) ថ្ងៃ បន្ទាប់ពីបានទទួលលិខិតស្នើសុំ ដោយផ្អែកលើបញ្ជីបោះឆ្នោតផ្លូវការ។

៥- ជីវប្រវត្តិសង្ខេប និងសេចក្តីប្រកាសយល់ព្រមឈរឈ្មោះរបស់បេក្ខជនដែលបំពេញផ្ទាល់ដៃរបស់បេក្ខជនម្នាក់ៗ មានបិទរូបថត និងរូបថតបេក្ខជនម្នាក់ចំនួន ៣ (បី) សន្លឹកទៀត ទំហំ ៤X៦ ថតចំពីមុខតាមគំរូរូបថតផ្ញើ អ.ខ ។ ការប្រើប្រាស់រូបថតរបស់បេក្ខជននៃគណបក្សនយោបាយនីមួយៗ គឺ ១ (មួយ) សន្លឹក សម្រាប់បិទផ្សាយជាមួយបញ្ជីបេក្ខជន បន្ទាប់ពីថ្ងៃពិនិត្យពាក្យសុំចុះបញ្ជីបេក្ខជនរួចនៅទីស្នាក់ការ គឃ.សប ១ (មួយ) សន្លឹក សម្រាប់បិទជាបញ្ជីបេក្ខជនដំបូងនៅទីស្នាក់ការ គឃ.សប ១ (មួយ) សន្លឹក សម្រាប់បិទផ្សាយបញ្ជីបេក្ខជនផ្លូវការនៅទីស្នាក់ការ គឃ.សប ។ របៀបបិទរូបថតបេក្ខជន ៖ គឃ.សប ត្រូវបិទរូបថតតាមលេខរៀងឈ្មោះបេក្ខជននៃគណបក្សនយោបាយនីមួយៗ លើក្រដាសដែលមានទំហំសមស្របទៅតាមចំនួនបេក្ខជន។

៦- លិខិតសន្យារបស់បេក្ខជនឈរឈ្មោះបោះឆ្នោត ដែលជាមន្ត្រីរាជការថានឹងផ្តល់ច្បាប់សុំឈប់ពិសេសជូន គឃ.សប ។

៧- ឈ្មោះគណបក្សនយោបាយជាអក្សរពេញ ជាអក្សរកាត់ និងសញ្ញាសម្គាល់គណបក្សនយោបាយ។

## ៥. ការទទួលពាក្យសុំចុះបញ្ជីបេក្ខជនដោយ គឃ.សប

គ.ជ.ប ត្រូវកំណត់កាលបរិច្ឆេទនៃការទទួលពាក្យសុំចុះបញ្ជីបេក្ខជនសម្រាប់ឃុំ សង្កាត់នីមួយៗ។

**ក.** គ.ជ.ប ត្រូវផ្សព្វផ្សាយជាសាធារណៈនូវកាលបរិច្ឆេទ និងរយៈពេលនៃការទទួលពាក្យសុំចុះបញ្ជីបេក្ខជននៅគ្រប់ទីស្នាក់ការ គឃ.សប ។

**ខ.** ការទទួលពាក្យសុំចុះបញ្ជីបេក្ខជនមានរយៈពេល ៣ (បី) ថ្ងៃ គឺរៀងរាល់ថ្ងៃ ព្រឹកចាប់ពីម៉ោង ៧:០០ នាទី ដល់ ១១:៣០ នាទី រសៀលចាប់ពីម៉ោង ២:០០ នាទី ដល់ ៥:៣០ នាទី។

**គ.** គឃ.សប ត្រូវចេញបង្កាន់ដៃទទួលពាក្យជូនគណបក្សនយោបាយដែលបានដាក់ពាក្យសុំចុះបញ្ជីបេក្ខជន និងរក្សាគល់បញ្ជី ១ (មួយ) ច្បាប់ទុកជាឯកសារ។

**ឃ.** បង្កាន់ដៃទទួលពាក្យត្រូវបញ្ជាក់អំពីចំនួន និងប្រភេទឯកសារដែលបានទទួល ចុះកាលបរិច្ឆេទប្រគល់ ទទួល និងហត្ថលេខា ឬស្នាមមេដៃនៃអ្នកប្រគល់ ទទួល។ បន្ទាប់មក គឃ.សប ត្រូវបញ្ចូលព័ត៌មានរបស់គណបក្សនយោបាយ និងស្កេនបង្កាន់ដៃទទួលពាក្យនោះបញ្ចូលក្នុងកម្មវិធីគ្រប់គ្រងការចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយ។

**ង.** នៅពេលបញ្ចប់ការទទួលពាក្យ គឃ.សប ត្រូវធ្វើកំណត់ហេតុស្តីពីលទ្ធផលនៃការចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតសម្រាប់ឃុំ សង្កាត់របស់ខ្លួនចំនួន ៤ (បួន) ច្បាប់ ដោយមានចុះកាលបរិច្ឆេទ ហត្ថលេខា ឈ្មោះ និងបោះត្រា គឃ.សប រួចបិទផ្សាយ ១ (មួយ) ច្បាប់នៅទីស្នាក់ការ គឃ.សប ផ្ញើជូន គធ.ខប ១ (មួយ) ច្បាប់ ជូន គ.ជ.ប ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។ តំណាងគណបក្សនយោបាយអាចចូលរួមចុះហត្ថលេខាលើកំណត់ហេតុនេះបាន។

## ៦. ការបិទផ្សាយបញ្ជីបេក្ខជននៃគណបក្សនយោបាយ

**ក.** បន្ទាប់ពីថ្ងៃបញ្ចប់ការទទួលពាក្យសុំចុះបញ្ជីបេក្ខជន គឃ.សប ត្រូវធ្វើការពិនិត្យពាក្យសុំចុះបញ្ជីបេក្ខជនទាំងនោះក្នុងរយៈពេល ១ (មួយ) ថ្ងៃ។ គឃ.សប ត្រូវបិទផ្សាយជាសាធារណៈនៅទីស្នាក់ការរបស់ខ្លួននូវបញ្ជីបេក្ខជននៃគណបក្សនយោបាយទាំងអស់ ដែលបានទទួលពាក្យសុំចុះបញ្ជីបេក្ខជនក្នុងរយៈពេលយ៉ាងយូរ ៣ (បី) ថ្ងៃ បន្ទាប់ពីថ្ងៃពិនិត្យពាក្យសុំចុះបញ្ជីបេក្ខជន។

**ខ.** ប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតក្នុងឃុំ សង្កាត់ មានសិទ្ធិផ្តល់មតិចំពោះបញ្ជីបេក្ខជននៃគណបក្សនយោបាយ ដែលបានបិទផ្សាយខាងលើមក គឃ.សប ដើម្បីជាព័ត៌មានសម្រាប់ជាមូលដ្ឋានពិចារណាមុនពេលសម្រេចយល់ព្រម ឬបដិសេធការចុះបញ្ជីបេក្ខជន។

## ៧. ការពិនិត្យ និងសម្រេចរបស់ គឃ.សប លើពាក្យសុំចុះបញ្ជីបេក្ខជន

**ក.** គឃ.សប ត្រូវពិនិត្យ និងសម្រេចយល់ព្រម ឬបដិសេធលើពាក្យសុំចុះបញ្ជីបេក្ខជនរបស់គណបក្សនយោបាយ ក្នុងរយៈពេលយ៉ាងយូរ ៧ (ប្រាំពីរ) ថ្ងៃ បន្ទាប់ពីថ្ងៃបានទទួលពាក្យសុំចុះបញ្ជីបេក្ខជន។

**ខ.** គឃ.សប ត្រូវបញ្ចូលទិន្នន័យបេក្ខជននៃគណបក្សនយោបាយផ្អែកតាមបញ្ជីរាយនាមបេក្ខជនដែលបានភ្ជាប់មកជាមួយ ទ.១០០៨ ដោយត្រូវទាញទិន្នន័យពីបញ្ជីបោះឆ្នោតផ្លូវការក្នុងកម្មវិធីគ្រប់គ្រងការចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយ ដើម្បីពិនិត្យ និងផ្ទៀងផ្ទាត់លក្ខខណ្ឌរបស់បេក្ខជននៃគណបក្សនយោបាយ ដែលបានដាក់ពាក្យសុំចុះបញ្ជីបេក្ខជន។

**គ.** ក្នុងករណីគណបក្សនយោបាយណាមួយ បានបំពេញត្រឹមត្រូវតាមលក្ខខណ្ឌកំណត់ គឃ.សប ត្រូវសម្រេចយល់ព្រមលើពាក្យសុំចុះបញ្ជីបេក្ខជននោះ ដោយត្រូវបំពេញលើ ទ.១០០៨ ទាំង ២ (ពីរ) ច្បាប់ ចុះហត្ថលេខា ឈ្មោះ កាលបរិច្ឆេទ និងបោះត្រា គឃ.សប រួចជូនទៅសាមីគណបក្សនយោបាយ ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

**ឃ.** ក្នុងករណីគណបក្សនយោបាយណាមួយ បំពេញមិនបានត្រឹមត្រូវតាមលក្ខខណ្ឌដូចបានកំណត់ខាងលើ គឃ.សប ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរ និងណែនាំដល់គណបក្សនយោបាយ ដែលបានដាក់ពាក្យសុំចុះបញ្ជីបេក្ខជននោះឱ្យធ្វើការកែតម្រូវឱ្យបានត្រឹមត្រូវ ហើយផ្តល់ឱកាសឱ្យគណបក្សនយោបាយនោះ ធ្វើការកែតម្រូវនូវចំណុចខ្វះខាតក្នុងរយៈពេលយ៉ាងយូរ ៥ (ប្រាំ) ថ្ងៃ បន្ទាប់ពីបានទទួលលិខិតជូនដំណឹង។

**ង.** ក្នុងករណីគណបក្សនយោបាយ ដែលបានទទួលលិខិតជូនដំណឹងជាលាយលក្ខណ៍អក្សរពី គយ.សប ឱ្យធ្វើការកែតម្រូវនូវចំណុចខ្វះខាតបានកែតម្រូវត្រឹមត្រូវ និងទាន់ពេលវេលាហើយនោះ គយ.សប ត្រូវយល់ព្រមលើពាក្យសុំចុះបញ្ជីបេក្ខជន ដូចមានចែងក្នុងចំណុច **គ (ទំព័រ៥)** ក្នុងរយៈពេល ១ (មួយ) ថ្ងៃ បន្ទាប់ពីបានទទួលពាក្យស្នើសុំដែលបានកែតម្រូវរួចហើយ។

**ច.** ក្នុងករណីគណបក្សនយោបាយដែលដាក់ស្នើបញ្ជីបេក្ខជន មិនបានកែតម្រូវចំណុចខ្វះខាតតាមលក្ខខណ្ឌ និងពេលវេលាដូចមានចែងក្នុងចំណុច **ឃ (ទំព័រ៥)** គយ.សប ត្រូវបដិសេធពាក្យសុំចុះបញ្ជីបេក្ខជននោះ។

# ជំពូកទី ២
# នីតិវិធីនៃការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹង
## ផ្នែកទី ១
## ការប្តឹងតវ៉ា ឬការប្តឹងជំទាស់

ជនណាក៏ដោយ ឬតំណាងមានសិទ្ធិប្តឹងតវ៉ា ឬ/និងប្តឹងជំទាស់តាមឋានានុក្រមទៅ គឃ.សប ឬ គធ.ខប ឬ គ.ជ.ប អំពីបញ្ហាទាំងឡាយដែលទាក់ទងនឹងការបោះឆ្នោត ប្រសិនបើមានភស្តុតាងបញ្ជាក់ថា មានភាពមិនត្រឹមត្រូវតាមបទប្បញ្ញត្តិនៃ ច.ប.ឃ.ស និង ប.ន.ឃ.ស ឬ/និងបទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប លើកលែងតែ ៖

- ការប្តឹងតវ៉ា និងការប្តឹងជំទាស់ទាក់ទងនឹងការចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយសម្រាប់ឈរឈ្មោះបោះឆ្នោត ដែលត្រូវប្តឹងដោយសាមីគណបក្សនយោបាយ
- ការបិទផ្សាយបញ្ជីបេក្ខជនដំបូង ដែលត្រូវប្តឹងដោយប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតក្នុងឃុំ សង្កាត់
- ការបោះឆ្នោត និងរាប់សន្លឹកឆ្នោត ដែលត្រូវប្តឹងដោយមន្ត្រីការិយាល័យបោះឆ្នោត ឬភ្នាក់ងារគណបក្សនយោបាយ
- លទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោត ដែលត្រូវប្តឹងដោយជនគ្រប់រូបដែលបានចុះឈ្មោះបោះឆ្នោតនៅលើបញ្ជីឈ្មោះបោះឆ្នោតនៅឃុំ សង្កាត់នោះ ឬគណបក្សនយោបាយដែលមានបញ្ជីបេក្ខជនឈរឈ្មោះ។

### ១. ពាក្យបណ្តឹង

ពាក្យបណ្តឹង ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរតាម ទ.១២០២ ចំនួន ៣ (បី) ច្បាប់ **(ករណីប្តឹងតវ៉ា)** ឬចំនួន ៤ (បួន) ច្បាប់ **(ករណីប្តឹងជំទាស់)**។ គឃ.សប ឬមន្ត្រីបោះឆ្នោតត្រូវប្រគល់ ទ.១២០២ ដល់អ្នកប្តឹងដើម្បីប្តឹង ឬប្តឹងបន្តប្រសិនបើមានការស្នើសុំ។

អ្នកប្តឹងដំបូងអាចថតចម្លង ទ.១២០២ ដែលខ្លួនបានបំពេញ រួចចុះហត្ថលេខា ឬផ្តិតមេដៃលើច្បាប់ចម្លងទាំងនោះដោយខ្លួនឯង ហើយអាចដាក់ពាក្យបណ្តឹងដោយផ្ទាល់ ឬអាចប្រគល់សិទ្ធិជាលាយលក្ខណ៍អក្សរឱ្យតំណាងដាក់ពាក្យបណ្តឹងជួសខ្លួនបាន។

ពាក្យបណ្ដឹង ត្រូវបញ្ជាក់នូវព័ត៌មានចាំបាច់មួយចំនួនដូចខាងក្រោម ៖

១- ឈ្មោះ និងអាសយដ្ឋានរបស់អ្នកប្ដឹង ឬតំណាង

២- កម្មវត្ថុនៃពាក្យបណ្ដឹង

៣- ប្រភេទនៃអំពើល្មើស

៤- ពេលវេលា និងទីកន្លែងនៃការប្រព្រឹត្តអំពើល្មើស ឬភាពមិនប្រក្រតីកើតឡើង

៥- បើអាចធ្វើបាន បញ្ជាក់អំពីមាត្រានៃ ច.ប.ឃ.ស ឬប្រការនៃ ប.ន.ឃ.ស ដែលបានរំលោភ

៦- អត្តសញ្ញាណរបស់ជនដែលពាក់ព័ន្ធនឹងការប្ដឹងតវ៉ា ឬការប្ដឹងជំទាស់

៧- ឈ្មោះ និងអាសយដ្ឋានរបស់សាក្សី បើមាន

៨- ភស្តុតាងផ្សេងៗទៀត បើមាន។

ពាក្យបណ្ដឹងអនាមិក ពុំត្រូវបានចាត់ទុកជាពាក្យបណ្ដឹងស្របច្បាប់ និងមិនត្រូវបានលើកយកមកដោះស្រាយឡើយ ប៉ុន្តែត្រូវបានចាត់ទុកជាឯកសារព័ត៌មានសម្រាប់ការពិចារណា។

ពាក្យបណ្ដឹងប្ដឹងពីអញ្ញាតជន[១] ត្រូវចាត់ទុកជាបណ្ដឹងស្របច្បាប់ និងត្រូវបានសហការជាមួយអាជ្ញាធរទទួលបន្ទុកសន្តិសុខបោះឆ្នោត ដើម្បីស្វែងរកអត្តសញ្ញាណរបស់អ្នកប្រព្រឹត្តល្មើសនោះ និងពង្រឹងការការពារ និងទប់ស្កាត់បន្ថែម។ ក្នុងករណីដែលស្វែងរកអត្តសញ្ញាណអញ្ញាតជនមិនឃើញ គឃ.សប ឬ គធ.ខប ឬ គ.ជ.ប ត្រូវធ្វើលិខិតជូនដំណឹងទៅអ្នកប្ដឹងវិញអំពីករណីនេះ ក្នុងរយៈពេលសមស្រប។

គ្រប់ពាក្យបណ្ដឹង (ទ.១២០២) សម្រង់សេចក្ដីសម្រេច (ទ.១២០៣) និងសេចក្ដីសម្រេចទាំងមូលពាក់ព័ន្ធនឹងពាក្យបណ្ដឹងនៅ គ.ជ.ប នឹងត្រូវបង្ហោះនៅលើគេហទំព័ររបស់ គ.ជ.ប (www.nec.gov.kh)។

## ២. ការរាប់ចំនួនថ្ងៃតវ៉ា ឬថ្ងៃជំទាស់ និងការសម្រេចលើពាក្យបណ្ដឹងតវ៉ា ឬពាក្យបណ្ដឹងជំទាស់

ថ្ងៃធ្វើការត្រូវបានកំណត់ទាំងថ្ងៃសៅរ៍ ទាំងថ្ងៃអាទិត្យ ប៉ុន្តែការរាប់ចំនួនថ្ងៃប្ដឹងតវ៉ា ឬថ្ងៃប្ដឹងជំទាស់ និងការសម្រេចលើពាក្យបណ្ដឹងតវ៉ា ឬពាក្យបណ្ដឹងជំទាស់ ពុំត្រូវបានរាប់បញ្ចូលថ្ងៃបុណ្យផ្លូវការ ដែលកំណត់ក្នុងអនុក្រឹត្យស្ដីពីប្រតិទិនឈប់សម្រាកការងាររបស់មន្ត្រីរាជការ និយោជិត កម្មករប្រចាំឆ្នាំ។

[១] ជនមិនស្គាល់អត្តសញ្ញាណ

# ផ្នែកទី ២
# បណ្តឹងក្នុងដំណាក់កាលចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយ សម្រាប់ឈរឈ្មោះបោះឆ្នោត

## ១. ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងនៅ គធ.ខប

### ១.១ ការដាក់ និងការទទួលពាក្យបណ្តឹងនៅ គធ.ខប

ក. គណបក្សនយោបាយណាដែលបានដាក់ស្នើបញ្ជីបេក្ខជន ហើយត្រូវបាន គឃ.សប បដិសេធ សាមីគណបក្ស ឬតំណាងមានសិទ្ធិប្តឹងតវ៉ាជាលាយលក្ខណ៍អក្សរតាម ទ.១២០២ ទៅ គធ.ខប ក្នុងរយៈពេលយ៉ាងយូរ ៥ (ប្រាំ) ថ្ងៃ បន្ទាប់ពីថ្ងៃបានទទួល ទ.១២០៣ របស់ គឃ.សប ។

ខ. អ្នកប្តឹងត្រូវបំពេញ ទ.១២០២ ចំនួន ៣ (បី) ច្បាប់។ ក្នុងករណីដែលអ្នកប្តឹងមកប្តឹងតវ៉ាដោយផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរតាមលិខិតផ្សេងក្រៅពី ទ.១២០២ គធ.ខប ត្រូវណែនាំអ្នកប្តឹងឱ្យបំពេញ ទ.១២០២ ចំនួន ៣ (បី) ច្បាប់។

### ១.២ ការដោះស្រាយពាក្យបណ្តឹងនៅ គធ.ខប

ក. គធ.ខប ត្រូវបើកសវនាការជាសាធារណៈសម្រេចលើពាក្យបណ្តឹងក្នុងរយៈពេលយ៉ាងយូរ ៣ (បី) ថ្ងៃ បន្ទាប់ពីបានទទួលពាក្យបណ្តឹង។

ខ. ក្នុងករណីដែល គធ.ខប បើកសវនាការជាសាធារណៈ សម្រេចបដិសេធ ឬយល់ព្រមលើពាក្យបណ្តឹងតវ៉ា ប្រធានក្រុមប្រឹក្សាជំនុំជម្រះនៃ គធ.ខប ត្រូវ ៖

ខ.១ ចាត់លេខាធិការសវនាការ ឱ្យស្រង់សេចក្តីសម្រេចចូលក្នុង ទ.១២០៣ ចំនួន ៤ (បួន) ច្បាប់ ដោយមានការចុះហត្ថលេខាឈ្មោះរបស់លេខាធិការសវនាការ និងប្រធានក្រុមប្រឹក្សាជំនុំជម្រះ ហើយចុះកាលបរិច្ឆេទ និងបោះត្រា គធ.ខប ហើយលេខាធិការសវនាការត្រូវចាត់ចែងជូនគណបក្សនយោបាយសាមី ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូន គឃ.សប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ ផ្ញើជូន គ.ជ.ប ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

ខ.២ **ក្នុងករណីបដិសេធលើពាក្យបណ្តឹង** ត្រូវជម្រាបគណបក្សនយោបាយសាមី ឬតំណាងថា គាត់អាចប្តឹងតវ៉ាអំពីករណីនេះទៅ គ.ជ.ប ក្នុងរយៈពេលយ៉ាងយូរ ៥ (ប្រាំ) ថ្ងៃ បន្ទាប់ពីបានទទួល ទ.១២០៣ ។

**គ.** សមាសភាព និងសិទ្ធិអំណាចរបស់ក្រុមប្រឹក្សាជំនុំជម្រះនៃ គធ.ខប ត្រូវអនុវត្តតាមលក្ខខណ្ឌដូចមានចែងក្នុងជំពូកទី៣ នៃសៀវភៅណែនាំនេះ។

## ២. ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងនៅ គ.ជ.ប

### ២.១ ការដាក់ និងការទទួលពាក្យបណ្តឹងនៅ គ.ជ.ប

គណបក្សនយោបាយសាមី ឬតំណាងដែលមិនសុខចិត្តនឹងសេចក្តីសម្រេចរបស់ គធ.ខប មានសិទ្ធិប្តឹងតវ៉ាជាលាយលក្ខណ៍អក្សរតាម ទ.១២០២ ទៅ គ.ជ.ប ក្នុងរយៈពេលយ៉ាងយូរ ៥ (ប្រាំ) ថ្ងៃ បន្ទាប់ពីបានទទួល ទ.១២០៣ ។ អ្នកប្តឹងត្រូវបំពេញ ទ.១២០២ ចំនួន ៣ (បី) ច្បាប់។

### ២.២ ការដោះស្រាយពាក្យបណ្តឹងនៅ គ.ជ.ប

**ក.** គ.ជ.ប ត្រូវបើកសវនាការជាសាធារណៈ ក្នុងរយៈពេលយ៉ាងយូរ ៣ (បី) ថ្ងៃ បន្ទាប់ពីទទួលបាន ទ.១២០២ ។

**ខ.** ក្នុងករណីដែល គ.ជ.ប បើកសវនាការសម្រេចបដិសេធ ឬយល់ព្រមលើពាក្យបណ្តឹងតវ៉ា ប្រធានក្រុមប្រឹក្សាជំនុំជម្រះនៃ គ.ជ.ប ត្រូវ ៖

ខ.១ ចាត់គណៈលេខាធិការសវនាការ ឱ្យស្រង់សេចក្តីសម្រេចចូលក្នុង ទ.១២០៣ ចំនួន ៤ (បួន) ច្បាប់ ដោយមានការចុះហត្ថលេខា ឈ្មោះរបស់ប្រធានគណៈលេខាធិការសវនាការ និងប្រធានក្រុមប្រឹក្សាជំនុំជម្រះ ហើយចុះកាលបរិច្ឆេទ និងបោះត្រា គ.ជ.ប ហើយគណៈលេខាធិការសវនាការ ត្រូវចាត់ចែងជូនគណបក្សនយោបាយសាមី ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូន គធ.ខប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ ផ្ញើជូន គឃ.សប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

ខ.២ **ក្នុងករណីបដិសេធលើពាក្យបណ្តឹង** ត្រូវជម្រាបគណបក្សនយោបាយសាមី ឬតំណាងថា សេចក្តីសម្រេចរបស់ គ.ជ.ប ជាសេចក្តីសម្រេចចុងក្រោយបិទផ្លូវតវ៉ា ។

**គ.** បន្ទាប់ពីបានបញ្ចប់រយៈពេលចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយ ហើយឃុំ សង្កាត់ណាដែលការប្តឹងតវ៉ាទាំងអស់ ត្រូវបានដោះស្រាយរួចរាល់ គ.ជ.ប ត្រូវចាត់ឱ្យ គឃ.សបប បិទផ្សាយជាសាធារណៈនៅទីស្នាក់ការរបស់ខ្លួននូវបញ្ជីបេក្ខជនដំបូង ក្នុងរយៈពេលយ៉ាងយូរ ៣ (បី) ថ្ងៃ បន្ទាប់ពីថ្ងៃបានទទួល ទ.១២០៣ ពី គ.ជ.ប ។

**ឃ.** សមាសភាព និងសិទ្ធិអំណាចរបស់ក្រុមប្រឹក្សាជំនុំជម្រះនៃ គ.ជ.ប ត្រូវអនុវត្តតាមលក្ខខណ្ឌដូចមានចែងក្នុងជំពូកទី៣ នៃសៀវភៅណែនាំនេះ។

## ៣. គំនូសបំព្រួញរយៈពេលនៃការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្ដឹង ក្នុងដំណាក់កាលចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយ



# ផ្នែកទី ៣
# បណ្តឹងក្នុងដំណាក់កាលបិទផ្សាយបញ្ជីបេក្ខជនដំបូង

## ១. ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងនៅ គ.ជ.ប

### ១.១ ការដាក់ និងការទទួលពាក្យបណ្តឹងនៅ គ.ជ.ប

**ក.** ប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតក្នុងឃុំ សង្កាត់នោះ មានសិទ្ធិប្តឹងជំទាស់ជាលាយលក្ខណ៍អក្សរទៅ គ.ជ.ប អំពីបេក្ខជន ឬបញ្ជីបេក្ខជនដំបូង ក្នុងរយៈពេលយ៉ាងយូរ ៣ (បី) ថ្ងៃ បន្ទាប់ពីថ្ងៃបិទផ្សាយជាសាធារណៈ។ អ្នកប្តឹងត្រូវបំពេញ ទ.១២០២ ចំនួន ៤ (បួន) ច្បាប់។

**ខ.** ពាក្យបណ្តឹងជំទាស់ត្រូវចោទប្រកាន់ទៅលើបេក្ខជន ឬបញ្ជីបេក្ខជននៃគណបក្សនយោបាយណាមួយ ដែលបំពេញមិនបានគ្រប់គ្រាន់តាមលក្ខខណ្ឌដូចមានចែងក្នុងប្រការ ៦.១ ដល់ប្រការ ៦.៦ នៃ ប.ន.ឃ.ស ។

**គ.** អ្នកប្តឹងត្រូវបង្ហាញអំពីបេក្ខជន ឬបញ្ជីបេក្ខជននៃគណបក្សនយោបាយជាក់លាក់ណាមួយដោយបញ្ជាក់ពីចំណុចខ្វះខាតជាក់ស្តែង និងហេតុផលដែលស្នើសុំឱ្យប្រធានចោលបេក្ខជន ឬបញ្ជីបេក្ខជននោះ។

### ១.២ ការដោះស្រាយពាក្យបណ្តឹងនៅ គ.ជ.ប

**ក.** គ.ជ.ប ត្រូវបើកសវនាការជាសាធារណៈដោះស្រាយពាក្យបណ្តឹងជំទាស់ក្នុងរយៈពេលយ៉ាងយូរ ៣ (បី) ថ្ងៃ បន្ទាប់ពីថ្ងៃបានទទួល ទ.១២០២ ។

**ខ.** ក្នុងករណីដែល គ.ជ.ប បើកសវនាការសម្រេចបដិសេធ ឬយល់ព្រមលើពាក្យបណ្តឹងជំទាស់ ប្រធានក្រុមប្រឹក្សាជំនុំជម្រះនៃ គ.ជ.ប ត្រូវ ៖

**ខ.១** ចាត់គណៈលេខាធិការសវនាការ ឱ្យស្រង់សេចក្តីសម្រេចចូលក្នុង ទ.១២០៣ ចំនួន ៥ (ប្រាំ) ច្បាប់ ដោយមានការចុះហត្ថលេខា ឈ្មោះរបស់ប្រធានគណៈលេខាធិការសវនាការ និងប្រធានក្រុមប្រឹក្សាជំនុំជម្រះ ហើយចុះកាលបរិច្ឆេទ និងបោះត្រា គ.ជ.ប ហើយគណៈលេខាធិការសវនាការ ត្រូវចាត់ចែងជូនអ្នកប្តឹងជំទាស់ ១ (មួយ) ច្បាប់ គណបក្សនយោបាយដែលត្រូវគេប្តឹងជំទាស់ ១ (មួយ) ច្បាប់ ផ្ញើជូន គធ.ខប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ ផ្ញើជូន គឃ.សប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

**ខ.២ ក្នុងករណីបដិសេធលើពាក្យបណ្ដឹង** ត្រូវជម្រាបអ្នកប្ដឹងជំទាស់ថា សេចក្ដីសម្រេចរបស់ គ.ជ.ប ជាសេចក្ដីសម្រេចចុងក្រោយ បិទផ្លូវតវ៉ា។

**គ.** សមាសភាព និងសិទ្ធិអំណាចរបស់ក្រុមប្រឹក្សាជំនុំជម្រះនៃ គ.ជ.ប ត្រូវអនុវត្តតាមលក្ខខណ្ឌដូចមានចែងក្នុងជំពូកទី៣ នៃសៀវភៅណែនាំនេះ។

## ២. គំនូសបំព្រួញរយៈពេលនៃការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្ដឹងក្នុងដំណាក់កាលនៃការបិទផ្សាយបញ្ជីបេក្ខជនដំបូង

គំនូសបំព្រួញទី ២



# ផ្នែកទី ៤
# នីតិវិធីនៃការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្ដឹង ក្នុងដំណាក់កាលឃោសនាបោះឆ្នោត និងនៅមួយថ្ងៃមុនថ្ងៃបោះឆ្នោត និងនៅថ្ងៃបោះឆ្នោត និងរាប់សន្លឹកឆ្នោត ចំពោះគ្រប់អំពើបំពានលើបទប្បញ្ញត្តិនៃជំពូកទី១៤ នៃ ច.ប.ឃ.ស ដែលអាចនាំឱ្យមានការផាកពិន័យ

ផ្នែកទី ៤ នេះ ណែនាំអំពីនីតិវិធីនៃការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្ដឹងចំពោះគ្រប់អំពើបំពានលើបទប្បញ្ញត្តិនៃជំពូកទី១៤ នៃ ច.ប.ឃ.ស ប.ន.ឃ.ស និងបទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប ដែលប្រព្រឹត្តដោយជនដែលជាមន្ត្រីបោះឆ្នោត ឬ/និងជនមិនមែនជាមន្ត្រីបោះឆ្នោត ឬ/និងគណបក្សនយោបាយដែលអាចនាំឱ្យមានការផាកពិន័យនៅគ្រប់ដំណាក់កាលនៃការបោះឆ្នោតជ្រើសរើស កបឃ.ស រួមទាំងនៅមួយថ្ងៃមុនថ្ងៃបោះឆ្នោត និងនៅថ្ងៃបោះឆ្នោតផង។

## I. ពាក្យបណ្ដឹងពាក់ព័ន្ធនឹងជនដែលមិនមែនជាមន្ត្រីបោះឆ្នោត ឬគណបក្សនយោបាយ

ជនណាក៏ដោយដែលទទួលរងឥទ្ធិពល ឬជនដែលស្ថិតនៅកន្លែងកើតហេតុ ឬតំណាង មានសិទ្ធិដាក់ពាក្យបណ្ដឹងចំពោះជនដែលមិនមែនជាមន្ត្រីបោះឆ្នោត ឬគណបក្សនយោបាយទៅ គឃ.សប ក្នុងរយៈពេល ៣ (បី) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃកើតហេតុ។ អ្នកប្ដឹង ឬតំណាងអាចបន្តប្ដឹងទៅ គធ.ខប ក្នុងរយៈពេល ៣ (បី) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹង ឬផ្សះផ្សានៅ គឃ.សប ឬបន្តប្ដឹងទៅ គ.ជ.ប ក្នុងរយៈពេល ៣ (បី) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹង ឬ ទ.១២០៣ របស់ គធ.ខប ។ ពាក្យបណ្ដឹងត្រូវបញ្ជាក់នូវព័ត៌មានចាំបាច់មួយចំនួនដូចមានចែងក្នុង**ចំណុច ១.ពាក្យបណ្ដឹង (ទំព័រ៧)** នៃសៀវភៅណែនាំនេះ។

## ១. ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្ដឹងនៅ គឃ.សប

### ១.១ ការដាក់ និងការទទួលពាក្យបណ្ដឹងនៅ គឃ.សប

**ក.** អ្នកប្ដឹងត្រូវបំពេញ ទ.១២០២ ចំនួន ៤ (បួន) ច្បាប់។ អ្នកប្ដឹងដំបូងអាចថតចម្លង ទ.១២០២ ដែលខ្លួនបានបំពេញ រួចចុះហត្ថលេខា ឬផ្ដិតមេដៃលើច្បាប់ចម្លងទាំងនោះដោយខ្លួនឯង ហើយអាចដាក់ពាក្យបណ្ដឹងដោយផ្ទាល់ ឬអាចប្រគល់សិទ្ធិជាលាយលក្ខណ៍អក្សរឱ្យតំណាងដាក់ពាក្យបណ្ដឹងជួសខ្លួនបាន។

ខ. នៅពេលបានទទួលពាក្យបណ្ដឹង សមាជិកទទួលបន្ទុកលើការងារសេវាកម្មច្បាប់ និងវិវាទកម្ម និងសន្តិសុខបោះឆ្នោត ត្រូវពិនិត្យជាសំខាន់លើព័ត៌មានចាំបាច់មួយចំនួនមានជាអាទិ៍ ៖

១- ឈ្មោះ និងអាសយដ្ឋានរបស់អ្នកប្ដឹង ឬតំណាង

២- កម្មវត្ថុនៃពាក្យបណ្ដឹង និងការគោរពរយៈពេលកំណត់ ៣ (បី) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃកើតហេតុ។

គ. បន្ទាប់មកសមាជិកទទួលបន្ទុកលើការងារសេវាកម្មច្បាប់ និងវិវាទកម្ម និងសន្តិសុខបោះឆ្នោត ត្រូវធ្វើកំណត់ហេតុសាកសួរយកព័ត៌មានបន្ថែមពីអ្នកប្ដឹង ឬតំណាង ដោយត្រូវកត់ត្រាឱ្យបានច្បាស់លាស់ រួចឱ្យអ្នកប្ដឹង ឬតំណាងនោះ ផ្ដិតមេដៃ ឬចុះហត្ថលេខាលើកំណត់ហេតុ។ ក្នុងករណីអ្នកប្ដឹង ឬតំណាងមិនព្រមផ្ដិតមេដៃ ឬចុះហត្ថលេខា សមាជិកទទួលបន្ទុកលើការងារសេវាកម្មច្បាប់ និងវិវាទកម្ម និងសន្តិសុខបោះឆ្នោត ត្រូវចុះនិទ្ទេសបញ្ជាក់ពីការមិនព្រមផ្ដិតមេដៃ ឬចុះហត្ថលេខាលើកំណត់ហេតុនេះ។

ឃ. បន្ទាប់ពីបានពិនិត្យលើពាក្យបណ្ដឹង និងកំណត់ហេតុសាកសួរហើយ ឃើញថា ៖

ឃ.១ ពាក្យបណ្ដឹងមិនគោរពរយៈពេលកំណត់ ៣ (បី) ថ្ងៃ បន្ទាប់ពីថ្ងៃកើតហេតុ ប្រធាន គឃ.សប ឬសមាជិកដែលបានទទួលសិទ្ធិជាលាយលក្ខណ៍អក្សរ ត្រូវចារបដិសេធលើពាក្យបណ្ដឹងគ្រប់ច្បាប់ ដោយបញ្ជាក់អំពីមូលហេតុថា “ **ពាក្យបណ្ដឹងនេះបានដាក់ក្រោយរយៈពេលកំណត់ដូចមានចែងក្នុងចំណុច ១៤.២.២ នៃ ប.ន.ឃ.ស ដែលជាហេតុផ្ដាច់សិទ្ធិក្នុងការប្ដឹងមក គឃ.សប ។ ដូចនេះ គឃ.សប មិនអាចទទួលពាក្យបណ្ដឹងនេះ មកពិនិត្យ និងដោះស្រាយបានឡើយ** ” ហើយចុះហត្ថលេខា ឈ្មោះ បោះត្រា គឃ.សប និងចុះកាលបរិច្ឆេទ រួចប្រគល់ជូនអ្នកប្ដឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូន គជ.ខប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ២ (ពីរ) ច្បាប់ ។

ឃ.២ ពាក្យបណ្ដឹងមិនមានបញ្ជាក់ព័ត៌មានចាំបាច់ដូចមានចែងក្នុង**ចំណុច ១. ពាក្យបណ្ដឹង (ទំព័រ៧)** ឬតំណាងមិនមានលិខិតប្រគល់សិទ្ធិ

ជាលាយលក្ខណ៍អក្សរ ឬលិខិតប្រគល់សិទ្ធិមិនត្រឹមត្រូវជាអាទិ៍ សមាជិកទទួលបន្ទុកលើការងារសេវាកម្មច្បាប់ និងវិវាទកម្ម និងសន្តិសុខបោះឆ្នោតត្រូវណែនាំអ្នកប្តឹង ឬតំណាងឱ្យបំពេញបន្ថែមនូវចំណុចខ្វះខាតដោយមិនឱ្យហួសរយៈពេលកំណត់នៃការដាក់ពាក្យបណ្តឹង ហើយកត់ត្រាបន្ថែមក្នុងកំណត់ហេតុសាកសួរ។ ក្នុងករណីដែលដល់ពេលកំណត់អ្នកប្តឹង ឬតំណាងមិនបានបំពេញបន្ថែមនូវចំណុចខ្វះខាត ប្រធាន គឃ.សប ឬសមាជិកដែលបានទទួលសិទ្ធិជាលាយលក្ខណ៍អក្សរ ត្រូវចារបដិសេធលើពាក្យបណ្តឹងគ្រប់ច្បាប់ ដោយបញ្ជាក់អំពីមូលហេតុថា **"ពាក្យបណ្តឹងមិនមានបញ្ជាក់ព័ត៌មានចាំបាច់ ឬតំណាងមិនមានលិខិតប្រគល់សិទ្ធិជាលាយលក្ខណ៍អក្សរ ឬលិខិតប្រគល់សិទ្ធិមិនត្រឹមត្រូវ"** ហើយចុះហត្ថលេខា ឈ្មោះ បោះត្រា គឃ.សប និងចុះកាលបរិច្ឆេទ រួចផ្ញើជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូន គធ.ខបពាក់ព័ន្ធ ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ២ (ពីរ) ច្បាប់ ។

**ឃ.៣** ពាក្យបណ្តឹងគោរពរយៈពេលកំណត់ ៣ (បី) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃកើតហេតុ និងមានព័ត៌មានចាំបាច់ និងមានលិខិតប្រគល់សិទ្ធិត្រឹមត្រូវតាមច្បាប់ **(ករណីសាមីខ្លួនមិនចូលខ្លួនប្តឹងផ្ទាល់)** សមាជិកទទួលបន្ទុកលើការងារសេវាកម្មច្បាប់ និងវិវាទកម្ម និងសន្តិសុខបោះឆ្នោតត្រូវចុះកាលបរិច្ឆេទ ពេលវេលា ហើយចុះហត្ថលេខា ឈ្មោះ និងបោះត្រា គឃ.សប លើពាក្យបណ្តឹងគ្រប់ច្បាប់ រួចត្រូវប្រគល់ជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូនអ្នកត្រូវគេប្តឹង ១ (មួយ) ច្បាប់ រក្សាទុកក្នុងពេលប្រជុំផ្សះផ្សា ១ (មួយ) ច្បាប់ និងបិទផ្សាយជាសាធារណៈ ១ (មួយ) ច្បាប់ ។

### ១.២ ការដោះស្រាយពាក្យបណ្តឹងនៅ គឃ.សប

**ក.** បន្ទាប់ពីបានទទួលពាក្យបណ្តឹងហើយ គឃ.សប ត្រូវប្រជុំពិភាក្សាដើម្បីពិនិត្យជាបន្ទាន់លើពាក្យបណ្តឹង។ ក្នុងករណី គឃ.សប ពិនិត្យ និងយល់ឃើញថា ៖

១. ពាក្យបណ្តឹងគ្មានមូលដ្ឋានពាក់ព័ន្ធនឹងការបំពានលើបទប្បញ្ញត្តិនៃ ច.ប.ឃ.ស ឬ ប.ន.ឃ.ស ឬបទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប គឃ.សប

ត្រូវធ្វើលិខិតជូនដំណឹងបដិសេធតាមលិខិតរដ្ឋបាលទៅអ្នកប្តឹង ឬតំណាង ដោយបញ្ជាក់អំពីមូលហេតុឱ្យបានច្បាស់លាស់ ហើយចុះហត្ថលេខា ឈ្មោះ បោះត្រា គឃ.សប និងចុះកាលបរិច្ឆេទ រួចផ្ញើជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូនអ្នកត្រូវគេប្តឹង ១ (មួយ) ច្បាប់ ផ្ញើជូន គធ.ខប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់ ។

២. កម្មវត្ថុ និងមូលហេតុនៃពាក្យបណ្តឹងមានលក្ខណៈជាបទល្មើសព្រហ្មទណ្ឌសុទ្ធសាធ មិនពាក់ព័ន្ធទៅនឹងការបំពានលើបទប្បញ្ញត្តិនៃ ច.ប.ឃ.ស ឬ ប.ន.ឃ.ស ឬបទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប គឃ.សប ត្រូវធ្វើលិខិតជូនដំណឹងបដិសេធតាមលិខិតរដ្ឋបាលទៅអ្នកប្តឹង ឬតំណាង ដោយបញ្ជាក់ថា **"បណ្តឹងនេះមិនអាចដោះស្រាយបានទេ ដោយហេតុថា ករណីនេះ ឬទាំងនេះ ពុំមែនជាសមត្ថកិច្ចរបស់ គឃ.សប"** ហើយចុះហត្ថលេខា ឈ្មោះ បោះត្រា គឃ.សប និងចុះកាលបរិច្ឆេទ រួចផ្ញើជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូនអ្នកត្រូវគេប្តឹង ១ (មួយ) ច្បាប់ ផ្ញើជូន គធ.ខប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់ ។

៣. ពាក្យបណ្តឹងមានមូលដ្ឋានច្បាប់ត្រឹមត្រូវ និងមានព័ត៌មានចាំបាច់ គឃ.សប ត្រូវបង្កើតក្រុមត្រួតពិនិត្យ និងស្រាវជ្រាវ ដែលអាចមានសមាសភាពដូចខាងក្រោម ៖
- ប្រធាន គឃ.សប ឬតំណាង ជាប្រធានក្រុម
- សមាជិក គឃ.សប ១ (មួយ) រូប ជាសមាជិក
- សមាជិក គឃ.សប ១ (មួយ) រូប ជាលេខាធិការ។

ខ. ក្រុមត្រួតពិនិត្យ និងស្រាវជ្រាវត្រូវបើកការស៊ើបអង្កេតជាបន្ទាន់ ដោយសហការយ៉ាងជិតស្និទ្ធជាមួយអាជ្ញាធរទទួលបន្ទុកសន្តិសុខបោះឆ្នោត និងអាជ្ញាធរពាក់ព័ន្ធនានាដើម្បីចុះពិនិត្យ និងកត់ត្រាកំណត់ហេតុដល់ទីកន្លែងកើតហេតុ ប្រមូលភស្តុតាង សាកសួរសាក្សី និងជនដែលពាក់ព័ន្ធក្នុងពាក្យបណ្តឹង។ ប្រធានក្រុមត្រួតពិនិត្យ និងស្រាវជ្រាវនេះអាចស្នើសុំ និងអនុញ្ញាតឱ្យអ្នកប្តឹងអមដំណើរជាមួយ បើមានការយល់ព្រមពីអ្នកប្តឹង។

**គ.** បន្ទាប់ពីក្រុមត្រួតពិនិត្យ និងស៊ើបអង្កេតចប់ហើយ លទ្ធផលពិនិត្យឃើញថា ជនដែលត្រូវគេប្តឹងចោទប្រកាន់នោះមិនបានបំពានលើបទប្បញ្ញត្តិនៃ ច.ប.ឃ.ស ឬ ប.ន.ឃ.ស ឬបទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប គឃ.សប ត្រូវធ្វើលិខិតជូនដំណឹងបដិសេធតាមលិខិតរដ្ឋបាលទៅអ្នកប្តឹង ឬតំណាង ដោយបញ្ជាក់អំពីមូលហេតុឱ្យបានច្បាស់លាស់ ហើយចុះហត្ថលេខា ឈ្មោះ បោះត្រា គឃ.សប និងចុះកាលបរិច្ឆេទ រួចផ្ញើជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូនអ្នកត្រូវគេប្តឹង ១ (មួយ) ច្បាប់ ផ្ញើជូន គធ.ខប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

**ឃ.** ក្នុងករណីលទ្ធផលនៃការស៊ើបអង្កេតឃើញថា ជនដែលត្រូវគេប្តឹងចោទប្រកាន់បានបំពានលើបទប្បញ្ញត្តិនៃ ច.ប.ឃ.ស ឬ ប.ន.ឃ.ស ឬបទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប **គឃ.សប ត្រូវអញ្ជើញភាគីទំនាស់ទាំងអស់មកធ្វើការផ្សះផ្សាតាមថ្ងៃ និងពេលវេលាសមស្របជាបន្ទាន់កំណត់ដោយ គឃ.សប ។**

**ង.** គឃ.សប ត្រូវធ្វើកំណត់ហេតុប្រជុំផ្សះផ្សា ដោយឱ្យគូភាគីផ្តិតមេដៃលើកំណត់ហេតុប្រជុំផ្សះផ្សានោះ។

**ច.** ក្នុងការប្រជុំផ្សះផ្សា ប្រសិនបើគូភាគីទំនាស់ ៖

- **ច.១ ព្រមព្រៀងគ្នា** គឃ.សប ត្រូវកត់ត្រាក្នុងកំណត់ហេតុប្រជុំផ្សះផ្សានោះឱ្យបានច្បាស់ថា **ភាគីទំនាស់យល់ព្រមសះជានឹងគ្នា** ដោយឱ្យភាគីទំនាស់ផ្តិតមេដៃលើកំណត់ហេតុប្រជុំផ្សះផ្សានោះ បន្ទាប់មកត្រូវបញ្ជូនកំណត់ហេតុប្រជុំផ្សះផ្សានោះជាបន្ទាន់មក គធ.ខប ពាក់ព័ន្ធ។
- **ច.២ មិនព្រមព្រៀងគ្នាទេ** គឃ.សប ត្រូវកត់ត្រាក្នុងកំណត់ហេតុប្រជុំផ្សះផ្សានោះឱ្យបានច្បាស់ថា **ភាគីទំនាស់មិនព្រមសះជានឹងគ្នាទេ។** បន្ទាប់មក ត្រូវបញ្ជូនកំណត់ហេតុប្រជុំផ្សះផ្សានោះជាបន្ទាន់មក គធ.ខប ពាក់ព័ន្ធ ទោះបីភាគីណាមួយមិនព្រមផ្តិតមេដៃក៏ដោយ។ គឃ.សប ត្រូវជម្រាបអ្នកប្តឹងថា គាត់មានសិទ្ធិប្តឹងបន្តទៅ គធ.ខប ក្នុងរយៈពេល ៣ (បី) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃផ្សះផ្សា។

**ឆ.** គឃ.សប ត្រូវបើកការប្រជុំផ្សះផ្សាចំពោះរាល់ពាក្យបណ្ដឹងគ្រប់អំពើបំពានលើបទប្បញ្ញត្តិនៃជំពូកទី១៤ (ទោសប្បញ្ញត្តិ) នៃ ច.ប.ឃ.ស ប៉ុន្តែមិនមានអំណាចបើកអង្គប្រជុំសម្រេច និងចេញ ទ.១២០៣ ឡើយ។

**ជ.** សមាសភាព និងសិទ្ធិអំណាចរបស់ក្រុមប្រឹក្សាប្រជុំផ្សះផ្សានៃ គឃ.សប ត្រូវអនុវត្តតាមលក្ខខណ្ឌដូចមានចែងក្នុងជំពូកទី៣នៃសៀវភៅណែនាំនេះ។

## ២. ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្ដឹងនៅ គធ.ខប

### ២.១ ការដាក់ និងការទទួលពាក្យបណ្ដឹងនៅ គធ.ខប

**ក.** ភាគីវិវាទ ឬតំណាងដែលមិនសុខចិត្តនឹងលិខិតជូនដំណឹង ឬការផ្សះផ្សានៅថ្នាក់ គឃ.សប អាចប្ដឹងទៅ គធ.ខប ក្នុងរយៈពេល ៣ (បី) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹង ឬថ្ងៃផ្សះផ្សានៅ គឃ.សប ។ អ្នកប្ដឹង ឬតំណាងត្រូវបំពេញ ទ.១២០២ ចំនួន ៤ (បួន) ច្បាប់ ។

**ខ.** នៅពេលបានទទួលពាក្យបណ្ដឹង សមាជិក គធ.ខប ដែលជាប្រធានផ្នែកសេវាកម្មច្បាប់ វិវាទកម្ម និងសន្តិសុខបោះឆ្នោត ត្រូវពិនិត្យជាសំខាន់លើព័ត៌មានចាំបាច់មួយចំនួនមានជាអាទិ៍ ៖

- ១- ឈ្មោះ និងអាសយដ្ឋានរបស់អ្នកប្ដឹង ឬតំណាង
- ២- កម្មវត្ថុនៃពាក្យបណ្ដឹង និងការគោរពរយៈពេលកំណត់ ៣ (បី) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹង ឬថ្ងៃផ្សះផ្សានៅ គឃ.សប ។

**គ.** បន្ទាប់មក សមាជិក គធ.ខប ដែលជាប្រធានផ្នែកសេវាកម្មច្បាប់ វិវាទកម្ម និងសន្តិសុខបោះឆ្នោត ត្រូវធ្វើកំណត់ហេតុសាកសួរយកព័ត៌មានបន្ថែមពីអ្នកប្ដឹង ឬតំណាង ដោយត្រូវកត់ត្រាឱ្យបានច្បាស់លាស់ រួចឱ្យអ្នកប្ដឹង ឬតំណាងនោះ ផ្តិតមេដៃ ឬចុះហត្ថលេខាលើកំណត់ហេតុនោះ។ ក្នុងករណីអ្នកប្ដឹង ឬតំណាងមិនព្រមផ្តិតមេដៃ ឬចុះហត្ថលេខា សមាជិក គធ.ខប ដែលជាប្រធានផ្នែកសេវាកម្មច្បាប់ វិវាទកម្ម និងសន្តិសុខបោះឆ្នោត ត្រូវចុះនិទ្ទេសបញ្ជាក់ពីការមិនព្រមផ្តិតមេដៃ ឬចុះហត្ថលេខាលើកំណត់ហេតុនេះ។

**ឃ.** បន្ទាប់ពីបានពិនិត្យលើពាក្យបណ្ដឹង និងកំណត់ហេតុសាកសួរ ហើយឃើញថា ៖

ឃ.១ ពាក្យបណ្ដឹងមិនគោរពរយៈពេលកំណត់ ៣ (បី) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹង ឬថ្ងៃផ្សះផ្សា ប្រធាន គធ.ខប ឬសមាជិកដែលបានទទួលសិទ្ធិជាលាយលក្ខណ៍អក្សរ ត្រូវចារបដិសេធលើពាក្យបណ្ដឹងគ្រប់ច្បាប់ ដោយបញ្ជាក់អំពីមូលហេតុថា "**ពាក្យបណ្ដឹងនេះបានដាក់ក្រោយរយៈពេលកំណត់ដូចមានចែងក្នុងចំណុច ១៤.២.១៣ នៃ ប.ន.ឃ.ស ដែលជាហេតុផ្ដោះសិទ្ធិក្នុងការប្ដឹងមក គធ.ខប ។ ដូចនេះ គធ.ខប មិនអាចទទួលពាក្យបណ្ដឹងនេះមកពិនិត្យ និងដោះស្រាយបានឡើយ**" ហើយចុះហត្ថលេខា ឈ្មោះ បោះត្រា គធ.ខប និងចុះកាលបរិច្ឆេទ រួចផ្ញើជូនអ្នកប្ដឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូន គ.ជ.ប ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ២ (ពីរ) ច្បាប់។

ឃ.២ ពាក្យបណ្ដឹងមិនមានបញ្ជាក់ព័ត៌មានចាំបាច់ដូចមានចែងក្នុង**ចំណុច ១.ពាក្យបណ្ដឹង (ទំព័រ៧)** ឬតំណាងមិនមានលិខិតប្រគល់សិទ្ធិជាលាយលក្ខណ៍អក្សរ ឬលិខិតប្រគល់សិទ្ធិមិនត្រឹមត្រូវជាអាទិ៍ សមាជិក គធ.ខប ដែលជាប្រធានផ្នែកសេវាកម្មច្បាប់ វិវាទកម្ម និងសន្តិសុខបោះឆ្នោត ត្រូវណែនាំអ្នកប្ដឹង ឬតំណាងឱ្យបំពេញបន្ថែមនូវចំណុចខ្វះខាត ដោយមិនឱ្យហួសរយៈពេលកំណត់នៃការដាក់ពាក្យបណ្ដឹង ហើយកត់ត្រាបន្ថែមក្នុងកំណត់ហេតុសាកសួរ។ ក្នុងករណីដែលដល់ពេលកំណត់ អ្នកប្ដឹង ឬតំណាងមិនបានបំពេញបន្ថែមនូវចំណុចខ្វះខាត ប្រធាន គធ.ខប ឬសមាជិកដែលបានទទួលសិទ្ធិជាលាយលក្ខណ៍អក្សរ ត្រូវចារបដិសេធលើពាក្យបណ្ដឹងគ្រប់ច្បាប់ ដោយបញ្ជាក់អំពីមូលហេតុថា "**ពាក្យបណ្ដឹងមិនមានបញ្ជាក់ព័ត៌មានចាំបាច់ ឬតំណាងមិនមានលិខិតប្រគល់សិទ្ធិជាលាយលក្ខណ៍អក្សរ ឬលិខិតប្រគល់សិទ្ធិមិនត្រឹមត្រូវ**" ហើយចុះហត្ថលេខា ឈ្មោះ បោះត្រា គធ.ខប និងចុះកាលបរិច្ឆេទ រួចផ្ញើជូនអ្នកប្ដឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូន គ.ជ.ប ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ២ (ពីរ) ច្បាប់។

ឃ.៣ កម្មវត្ថុនៃពាក្យបណ្ដឹងពាក់ព័ន្ធនឹងការបំពានលើបទប្បញ្ញត្តិនៃ ច.ប.ឃ.ស ឬ ប.ន.ឃ.ស ឬបទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប ពាក្យបណ្ដឹងគោរពរយៈពេលកំណត់ ៣ (បី) ថ្ងៃយ៉ាងយូរបន្ទាប់ពី

ថ្ងៃបានទទួលលិខិតជូនដំណឹង ឬថ្ងៃផ្សះផ្សានៅ គឃ.សប មានព័ត៌មានចាំបាច់ និងមានលិខិតប្រគល់សិទ្ធិត្រឹមត្រូវតាមច្បាប់ **(ចំពោះករណីសាមីខ្លួនមិនចូលខ្លួនប្តឹងផ្ទាល់)** សមាជិក គធ.ឧប ដែលជាប្រធានផ្នែកសេវាកម្មច្បាប់ វិវាទកម្ម និងសន្តិសុខបោះឆ្នោត ត្រូវចុះកាលបរិច្ឆេទ ពេលវេលា ហើយចុះហត្ថលេខា ឈ្មោះ និងបោះត្រា គធ.ឧប លើពាក្យបណ្តឹងគ្រប់ច្បាប់ រួចត្រូវប្រគល់ជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូនអ្នកត្រូវគេប្តឹង ១ (មួយ) ច្បាប់ រក្សាទុកក្នុងពេលប្រជុំផ្សះផ្សា ១ (មួយ) ច្បាប់ និងទុកបិទផ្សាយជាសាធារណៈ ១ (មួយ) ច្បាប់។

## ២.២ ការដោះស្រាយពាក្យបណ្តឹងនៅ គធ.ឧប

**ក.** បន្ទាប់ពីបានទទួលពាក្យបណ្តឹងហើយ គធ.ឧប ត្រូវប្រជុំពិភាក្សាដើម្បីពិនិត្យជាបន្ទាន់លើពាក្យបណ្តឹង។ ក្នុងករណី គធ.ឧប ពិនិត្យ និងយល់ឃើញថា ៖

**១.** ពាក្យបណ្តឹងគ្មានមូលដ្ឋានពាក់ព័ន្ធនឹងការបំពានលើបទប្បញ្ញត្តិនៃ ច.ប.ឃ.ស ឬ ប.ន.ឃ.ស ឬបទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប គធ.ឧប ត្រូវធ្វើលិខិតជូនដំណឹងបដិសេធតាមលិខិតរដ្ឋបាលទៅអ្នកប្តឹង ឬតំណាង ដោយបញ្ជាក់អំពីមូលហេតុឱ្យបានច្បាស់លាស់ ហើយចុះហត្ថលេខា ឈ្មោះ បោះត្រា គធ.ឧប និងចុះកាលបរិច្ឆេទ រួចផ្ញើជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូនអ្នកត្រូវគេប្តឹង ១ (មួយ) ច្បាប់ ផ្ញើជូន គឃ.សប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ ផ្ញើជូន គ.ជ.ប ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់ ។

**២.** កម្មវត្ថុ និងមូលហេតុនៃពាក្យបណ្តឹងមានលក្ខណៈជាបទល្មើសព្រហ្មទណ្ឌសុទ្ធសាធ មិនពាក់ព័ន្ធទៅនឹងការបំពានលើបទប្បញ្ញត្តិនៃ ច.ប.ឃ.ស ឬ ប.ន.ឃ.ស គធ.ឧប ត្រូវធ្វើលិខិតជូនដំណឹងបដិសេធតាមលិខិតរដ្ឋបាលទៅអ្នកប្តឹង ឬតំណាង ដោយបញ្ជាក់អំពីមូលហេតុថា "**បណ្តឹងនេះមិនអាចដោះស្រាយបានទេ ដោយហេតុថា ករណីនេះ ឬទាំងនេះ ពុំមែនជាសមត្ថកិច្ចរបស់ គធ.ឧប**" ហើយចុះហត្ថលេខា ឈ្មោះ បោះត្រា គធ.ឧប និងចុះកាលបរិច្ឆេទ រួចផ្ញើជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូនអ្នកត្រូវគេប្តឹង ១ (មួយ) ច្បាប់ ផ្ញើជូន គឃ.សប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ ផ្ញើជូន គ.ជ.ប ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

៣. ពាក្យបណ្ដឹងដែលត្រូវបានភាគីទំនាស់សះជានឹងគ្នារួចហើយ នៅថ្នាក់ គយ.សប គធ.ខប ត្រូវពិនិត្យសម្រេចថា ត្រូវដោះស្រាយសាជាថ្មី ឬសម្រេចបដិសេធ។ ក្នុងករណីបដិសេធ គធ.ខប ត្រូវធ្វើលិខិតជូនដំណឹងបដិសេធតាមលិខិតរដ្ឋបាលទៅអ្នកប្ដឹង ឬតំណាង ដោយបញ្ជាក់អំពីមូលហេតុឱ្យបានច្បាស់លាស់ ហើយចុះហត្ថលេខា ឈ្មោះ បោះត្រា គធ.ខប និងចុះកាលបរិច្ឆេទ រួចផ្ញើជូនអ្នកប្ដឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូនអ្នកត្រូវគេប្ដឹង ១ (មួយ) ច្បាប់ ផ្ញើជូន គយ.សប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ ផ្ញើជូន គ.ជ.ប ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

៤. ពាក្យបណ្ដឹងមានមូលដ្ឋានច្បាប់ត្រឹមត្រូវ និងមានព័ត៌មានចាំបាច់ គធ.ខប ត្រូវបង្កើតក្រុមត្រួតពិនិត្យ និងស្រាវជ្រាវដែលអាចមានសមាសភាពដូចខាងក្រោម ៖

- ប្រធាន គធ.ខប ឬតំណាង ជាប្រធានក្រុម
- សមាជិក គធ.ខប ១ (មួយ) រូប ជាសមាជិក
- មន្ត្រីផ្នែកសេវាកម្មច្បាប់ វិវាទកម្ម និងសន្តិសុខបោះឆ្នោត ១(មួយ)រូប ជាលេខាធិការ។

ខ. ក្រុមត្រួតពិនិត្យ និងស្រាវជ្រាវត្រូវបើកការស៊ើបអង្កេតជាបន្ទាន់ដោយសហការយ៉ាងជិតស្និទ្ធជាមួយអាជ្ញាធរទទួលបន្ទុកសន្តិសុខបោះឆ្នោត និងអាជ្ញាធរពាក់ព័ន្ធនានាដើម្បីចុះពិនិត្យ និងកត់ត្រាកំណត់ហេតុដល់ទីកន្លែងកើតហេតុ ប្រមូលភស្តុតាង សាកសួរសាក្សី និងជនដែលពាក់ព័ន្ធក្នុងពាក្យបណ្ដឹង។ ប្រធានក្រុមត្រួតពិនិត្យ និងស្រាវជ្រាវនេះ អាចស្នើសុំ និងអនុញ្ញាតឱ្យអ្នកប្ដឹងអមដំណើរជាមួយ បើមានការយល់ព្រមពីអ្នកប្ដឹង។

គ. បន្ទាប់ពីក្រុមត្រួតពិនិត្យ និងស្រាវជ្រាវស៊ើបអង្កេតចប់សព្វគ្រប់ហើយ លទ្ធផលបង្ហាញថា ជនដែលត្រូវគេប្ដឹងចោទប្រកាន់នោះមិនបានបំពានលើបទប្បញ្ញត្តិនៃ ច.ប.យ.ស ឬ ប.ន.យ.ស ឬបទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប គធ.ខប ត្រូវធ្វើលិខិតជូនដំណឹងបដិសេធតាមលិខិតរដ្ឋបាលទៅអ្នកប្ដឹង ឬតំណាង ដោយបញ្ជាក់អំពីមូលហេតុនៃការបដិសេធឱ្យបានច្បាស់លាស់ ហើយចុះហត្ថលេខា ឈ្មោះ បោះត្រា គធ.ខប និងចុះកាលបរិច្ឆេទ រួចផ្ញើជូនអ្នកប្ដឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូនអ្នកត្រូវគេប្ដឹង ១ (មួយ) ច្បាប់ ផ្ញើជូន គយ.សប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ ផ្ញើជូន គ.ជ.ប ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

**ឃ.** ក្នុងករណីលទ្ធផលនៃការស៊ើបអង្កេតឃើញថា ជនដែលត្រូវគេប្តឹងចោទប្រកាន់បានបំពានលើបទប្បញ្ញត្តិនៃ ច.ប.ឃ.ស ឬ ប.ន.ឃ.ស ឬ បទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប **គធ.ខប ត្រូវអញ្ជើញភាគីទំនាស់ទាំងអស់មកធ្វើការផ្សះផ្សាតាមថ្ងៃ និងពេលវេលាសមស្របជាបន្ទាន់កំណត់ដោយ គធ.ខប ។**

**ង.** គធ.ខប ត្រូវធ្វើកំណត់ហេតុប្រជុំផ្សះផ្សា ដោយឱ្យគូភាគីផ្តិតមេដៃលើកំណត់ហេតុប្រជុំផ្សះផ្សានោះ។

**ច.** ក្នុងការផ្សះផ្សា ប្រសិនបើគូភាគីទំនាស់ ៖

**ច.១** ព្រមព្រៀងគ្នា គធ.ខប ត្រូវកត់ត្រាក្នុងកំណត់ហេតុប្រជុំផ្សះផ្សានោះឱ្យបានច្បាស់ថា **ភាគីទំនាស់យល់ព្រមសះជានឹងគ្នា** ដោយឱ្យភាគីទំនាស់ផ្តិតមេដៃលើកំណត់ហេតុប្រជុំផ្សះផ្សានោះ បន្ទាប់មកត្រូវបញ្ជូនកំណត់ហេតុប្រជុំផ្សះផ្សានោះជាបន្ទាន់មក គ.ជ.ប ។

**ច.២** មិនព្រមព្រៀងគ្នាទេ គធ.ខប ត្រូវកត់ត្រាក្នុងកំណត់ហេតុប្រជុំផ្សះផ្សានោះឱ្យបានច្បាស់ថា **ភាគីទំនាស់មិនព្រមសះជានឹងគ្នាទេ។** គធ.ខប ត្រូវកំណត់ពេលវេលា និងកាលបរិច្ឆេទបើកសវនាការជាសាធារណៈ ក្នុងរយៈពេល ១ (មួយ) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃផ្សះផ្សា ហើយត្រូវជូនដំណឹងភ្លាមនៅនឹងកន្លែងផ្សះផ្សាទៅភាគីពាក់ព័ន្ធឱ្យបានដឹងពីពេលវេលា កាលបរិច្ឆេទ និងទីកន្លែងបើកសវនាការតែម្តង។

**ឆ.** គធ.ខប ត្រូវបើកសវនាការជាសាធារណៈសម្រេចយល់ព្រម ឬបដិសេធលើពាក្យបណ្តឹងដោយមានកំណត់ហេតុសវនាការ សេចក្តីសម្រេច និង ទ.១២០៣ ចំនួន ៥ (ប្រាំ) ច្បាប់ ដោយមានការចុះហត្ថលេខា ឈ្មោះរបស់លេខាធិការសវនាការ និងប្រធានក្រុមប្រឹក្សាជំនុំជម្រះ ហើយបោះត្រា គធ.ខប និងចុះកាលបរិច្ឆេទ រួចប្រគល់ជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ប្រគល់ជូនអ្នកត្រូវគេប្តឹង ១ (មួយ) ច្បាប់ ផ្ញើជូន គឃ.សប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ ផ្ញើជូន គ.ជ.ប ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

**ជ.** សមាសភាព និងសិទ្ធិអំណាចរបស់ក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាជំនុំជម្រះនៃ គធ.ខប ត្រូវអនុវត្តតាមលក្ខខណ្ឌដូចមានចែងក្នុងជំពូកទី៣ នៃសៀវភៅណែនាំនេះ។

## ៣. ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងនៅ គ.ជ.ប

### ៣.១ ការដាក់ និងការទទួលពាក្យបណ្តឹងនៅ គ.ជ.ប

**ក.** ភាគីវិវាទ ឬតំណាងដែលមិនសុខចិត្តនឹងលិខិតជូនដំណឹង ឬសេចក្តីសម្រេចរបស់ គធ.ខប អាចប្តឹងទៅ គ.ជ.ប ក្នុងរយៈពេល ៣ (បី) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹង ឬ ទ.១២០៣ របស់ គធ.ខប ។ អ្នកប្តឹង ឬតំណាងត្រូវបំពេញ ទ.១២០២ ចំនួន ៤ (បួន) ច្បាប់។

**ខ.** នៅពេលបានទទួលពាក្យបណ្តឹង មន្ត្រីជំនាញនៃនាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម ត្រូវពិនិត្យជាសំខាន់លើព័ត៌មានចាំបាច់មួយចំនួនមានជាអាទ៍ ៖

- ១- ឈ្មោះ និងអាសយដ្ឋានរបស់អ្នកប្តឹង ឬតំណាង
- ២- កម្មវត្ថុនៃពាក្យបណ្តឹង និងការគោរពរយៈពេលកំណត់ ៣ (បី) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹង ឬ ទ.១២០៣ របស់ គធ.ខប ។

**គ.** បន្ទាប់មកមន្ត្រីជំនាញនៃនាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម ត្រូវធ្វើកំណត់ហេតុសាកសួរយកព័ត៌មានបន្ថែមពីអ្នកប្តឹង ឬតំណាងដោយត្រូវកត់ត្រាឱ្យបានច្បាស់លាស់ រួចឱ្យអ្នកប្តឹង ឬតំណាងផ្តិតមេដៃ ឬចុះហត្ថលេខាលើកំណត់ហេតុសាកសួរនោះ។ ក្នុងករណីអ្នកប្តឹង ឬតំណាងមិនព្រមផ្តិតមេដៃ ឬចុះហត្ថលេខា មន្ត្រីជំនាញនៃនាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម ត្រូវចុះនិទ្ទេសបញ្ជាក់ពីការមិនព្រមផ្តិតមេដៃ ឬចុះហត្ថលេខាលើកំណត់ហេតុនេះ។

**ឃ.** បន្ទាប់ពីបានពិនិត្យលើពាក្យបណ្តឹង និងកំណត់ហេតុសាកសួរ ហើយឃើញថា ៖

- ១- ពាក្យបណ្តឹងមិនគោរពរយៈពេលកំណត់ ៣ (បី) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹង ឬ ទ.១២០៣ របស់ គធ.ខប គ.ជ.ប ត្រូវចារបដិសេធលើពាក្យបណ្តឹងគ្រប់ច្បាប់ ដោយបញ្ជាក់អំពីមូលហេតុថា "**ពាក្យបណ្តឹងបានដាក់ក្រោយរយៈពេលកំណត់ ដូចមានចែងក្នុងចំណុច ១៤.២.២៦ នៃ ប.ន.ឃ.ស ដែលជាហេតុផ្លោះសិទ្ធិក្នុងការប្តឹងមក គ.ជ.ប ។ ដូចនេះ គ.ជ.ប មិនអាចទទួលពាក្យបណ្តឹងនេះមកពិនិត្យ និងដោះស្រាយបានឡើយ**" ហើយចុះហត្ថលេខាឈ្មោះ បោះត្រា គ.ជ.ប និងចុះកាលបរិច្ឆេទ រួចប្រគល់ជូនអ្នកប្តឹងឬតំណាង ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ៣ (បី) ច្បាប់។

២- ពាក្យបណ្ដឹងមិនមានបញ្ជាក់ព័ត៌មានចាំបាច់ដូចមានចែងក្នុង**ចំណុច ១.ពាក្យបណ្ដឹង (ទំព័រ៧)** ឬតំណាងមិនមានលិខិតប្រគល់សិទ្ធិជាលាយលក្ខណ៍អក្សរ ឬលិខិតប្រគល់សិទ្ធិមិនត្រឹមត្រូវជាអាទិ៍ មន្ត្រីជំនាញនៃនាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម ត្រូវណែនាំអ្នកប្ដឹង ឬតំណាងឱ្យបំពេញបន្ថែមនូវចំណុចខ្វះខាត ដោយមិនឱ្យហួសរយៈពេលកំណត់នៃការដាក់ពាក្យបណ្ដឹង ហើយត្រូវកត់ត្រាបន្ថែមក្នុងកំណត់ហេតុសាកសួរ។ ក្នុងករណីដែលដល់ពេលកំណត់ អ្នកប្ដឹង ឬតំណាងមិនបានបំពេញបន្ថែមនូវចំណុចខ្វះខាត គ.ជ.ប ត្រូវចារបដិសេធលើពាក្យបណ្ដឹងគ្រប់ច្បាប់ ដោយបញ្ជាក់អំពីមូលហេតុឱ្យបានច្បាស់លាស់ថា "**ពាក្យបណ្ដឹងមិនមានបញ្ជាក់ព័ត៌មានចាំបាច់ ឬតំណាងមិនមានលិខិតប្រគល់សិទ្ធិជាលាយលក្ខណ៍អក្សរ ឬលិខិតប្រគល់សិទ្ធិមិនត្រឹមត្រូវ....** " ហើយចុះហត្ថលេខា ឈ្មោះ បោះត្រា គ.ជ.ប និងចុះកាលបរិច្ឆេទ រួចផ្ញើជូនអ្នកប្ដឹង ឬតំណាង ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ៣ (មួយ) ច្បាប់។

៣- ពាក្យបណ្ដឹងគោរពរយៈពេលកំណត់ ៣ (បី) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹង ឬ ទ.១២០៣ របស់ គធ.ខប និងមានព័ត៌មានចាំបាច់ និងមានលិខិតប្រគល់សិទ្ធិត្រឹមត្រូវតាមច្បាប់ **(ចំពោះករណីសាមីខ្លួនមិនចូលខ្លួនប្ដឹងផ្ទាល់)** មន្ត្រីជំនាញនៃនាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម ត្រូវចុះកាលបរិច្ឆេទ ពេលវេលា ហើយចុះហត្ថលេខា ឈ្មោះ លើពាក្យបណ្ដឹងគ្រប់ច្បាប់ រួចប្រគល់ជូនអ្នកប្ដឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូនអ្នកត្រូវគេប្ដឹង ១ (មួយ) ច្បាប់ រក្សាទុកប្រើក្នុងពេលសវនាការ ១ (មួយ) ច្បាប់ និងទុកបិទផ្សាយជាសាធារណៈ ១ (មួយ) ច្បាប់។

## ៣.២ ការដោះស្រាយពាក្យបណ្ដឹងនៅ គ.ជ.ប

ក. បន្ទាប់ពីបានទទួលពាក្យបណ្ដឹងហើយ គ.ជ.ប ត្រូវពិនិត្យជាបន្ទាន់លើពាក្យបណ្ដឹង។ ក្នុងករណី គ.ជ.ប ពិនិត្យ និងយល់ឃើញថា៖

១- ពាក្យបណ្ដឹងគ្មានមូលដ្ឋានពាក់ព័ន្ធនឹងការបំពានលើបទប្បញ្ញត្តិនៃ ច.ប.ឃ.ស ឬ ប.ន.ឃ.ស ឬបទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប គ.ជ.ប ត្រូវធ្វើលិខិតជូនដំណឹងបដិសេធតាមលិខិតរដ្ឋបាលទៅអ្នកប្ដឹង

ឬតំណាង ដោយបញ្ជាក់អំពីមូលហេតុឱ្យបានច្បាស់លាស់ ហើយចុះហត្ថលេខា ឈ្មោះ បោះត្រា គ.ជ.ប និងចុះកាលបរិច្ឆេទ រួចផ្ញើជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូនអ្នកត្រូវគេប្តឹង ១ (មួយ) ច្បាប់ ផ្ញើជូន គធ.ខប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

២- កម្មវត្ថុ និងមូលហេតុនៃពាក្យបណ្តឹងមានលក្ខណៈជាបទល្មើសព្រហ្មទណ្ឌសុទ្ធសាធ មិនពាក់ព័ន្ធទៅនឹងការបំពានលើបទប្បញ្ញត្តិនៃ ច.ប.ឃ.ស ឬ ប.ន.ឃ.ស គ.ជ.ប ត្រូវធ្វើលិខិតជូនដំណឹងបដិសេធតាមលិខិតរដ្ឋបាលទៅអ្នកប្តឹង ដោយបញ្ជាក់អំពីមូលហេតុឱ្យបានច្បាស់លាស់ថា **បណ្តឹងនេះមិនអាចដោះស្រាយបានទេ ដោយហេតុថា ករណីនេះ ឬទាំងនេះ ពុំមែនជាសមត្ថកិច្ចរបស់ គ.ជ.ប** ហើយចុះហត្ថលេខា ឈ្មោះ បោះត្រា គ.ជ.ប និងចុះកាលបរិច្ឆេទ រួចផ្ញើជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូនអ្នកត្រូវគេប្តឹង ១ (មួយ) ច្បាប់ ផ្ញើជូន គធ.ខប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

៣- ពាក្យបណ្តឹងដែលត្រូវបានភាគីទំនាស់សះជានឹងគ្នាហើយ នៅថ្នាក់ គធ.ខប គ.ជ.ប ត្រូវពិនិត្យសម្រេចថា ត្រូវដោះស្រាយសាជាថ្មី ឬសម្រេចបដិសេធ។ ក្នុងករណីបដិសេធ គ.ជ.ប ត្រូវធ្វើលិខិតជូនដំណឹងបដិសេធតាមលិខិតរដ្ឋបាល ដោយបញ្ជាក់អំពីមូលហេតុឱ្យបានច្បាស់លាស់ ហើយចុះហត្ថលេខា ឈ្មោះ បោះត្រា គ.ជ.ប និងចុះកាលបរិច្ឆេទ រួចផ្ញើជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូនអ្នកត្រូវគេប្តឹង ១ (មួយ) ច្បាប់ ផ្ញើជូន គធ.ខប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

៤- ពាក្យបណ្តឹងមានមូលដ្ឋានច្បាប់ត្រឹមត្រូវ និងមានព័ត៌មានចាំបាច់ដូចមានចែងក្នុង**ចំណុច ១.ពាក្យបណ្តឹង (ទំព័រ៧)** គ.ជ.ប ត្រូវកំណត់នីតិវិធីដោះស្រាយ។

**ខ.** គ.ជ.ប អាចបើកការស៊ើបអង្កេតជាបន្ទាន់ចំពោះករណីណាដែលយល់ថាជាការចាំបាច់ និងស្មុគស្មាញ។

**គ.** បន្ទាប់ពីបានធ្វើការស៊ើបអង្កេតចប់សព្វគ្រប់ហើយ គ.ជ.ប មានសិទ្ធិមិនយកពាក្យបណ្តឹងនោះមកបើកសវនាការដោះស្រាយ ប្រសិនបើយល់ឃើញថា ពាក្យបណ្តឹងផ្ទុយនឹងទម្រង់ ឬគតិច្បាប់ ឬ/និងមិនមាន

អំណះអំណាងណាមួយពាក់ព័ន្ធនឹងកម្មវត្ថុនៃពាក្យបណ្តឹង ដែលអាចយកមកដោះស្រាយបាន ឬ/និងអំណះអំណាងមិនច្បាស់លាស់ ឬ/និងតាមការស៊ើបអង្កេតស្រាវជ្រាវរបស់ គ.ជ.ប ឃើញថា ផ្ទុយពីការអះអាងក្នុងពាក្យបណ្តឹង។ ការបដិសេធមិនទទួលដោះស្រាយរបស់ គ.ជ.ប ត្រូវធ្វើតាមរយៈលិខិតជូនដំណឹងបដិសេធតាមបែបបទរដ្ឋបាល ក្នុងរយៈពេលសមស្របមួយទៅអ្នកប្តឹង ឬតំណាងដើម្បីជូនជ្រាបថា ពាក្យបណ្តឹងរបស់គាត់មិនត្រូវបានយកមកដោះស្រាយ ហើយចុះហត្ថលេខា ឈ្មោះ បោះត្រា គ.ជ.ប និងចុះកាលបរិច្ឆេទ រួចផ្ញើជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូនអ្នកត្រូវគេប្តឹង ១ (មួយ) ច្បាប់ ផ្ញើជូន គធ.ខប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

**ឃ.** បន្ទាប់ពីបានធ្វើការស៊ើបអង្កេតចប់សព្វគ្រប់ ប្រសិនបើ គ.ជ.ប រកឃើញភស្តុតាងពាក់ព័ន្ធនឹងកម្មវត្ថុនៃពាក្យបណ្តឹង គ.ជ.ប ត្រូវដោះស្រាយពាក្យបណ្តឹងតាមពេលវេលាសមស្របជាបន្ទាន់។

**ង.** គ.ជ.ប ត្រូវបើកសវនាការសម្រេចយល់ព្រម ឬបដិសេធលើពាក្យបណ្តឹងដោយមានកំណត់ហេតុសវនាការ សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាជំនុំជម្រះនៃ គ.ជ.ប ត្រូវធ្វើឡើងដោយផ្អែកតាមកំណត់ហេតុសវនាការ ហើយត្រូវចុះហត្ថលេខាដោយប្រធានក្រុមប្រឹក្សាជំនុំជម្រះ។ សេចក្តីសម្រេចនេះត្រូវស្រង់ដាក់ក្នុង ទ.១២០៣ ហើយត្រូវចុះហត្ថលេខាដោយប្រធានគណៈ-លេខាធិការសវនាការ និងប្រធានក្រុមប្រឹក្សាជំនុំជម្រះ ឈ្មោះ បោះត្រា គ.ជ.ប និងចុះកាលបរិច្ឆេទ រួចប្រគល់ជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ជូនអ្នកត្រូវគេប្តឹង ១ (មួយ) ច្បាប់ ផ្ញើជូន គធ.ខប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

**ច.** សេចក្តីសម្រេចរបស់ គ.ជ.ប ជាសេចក្តីសម្រេចស្ថាពរបិទផ្លូវតវ៉ា។

**ឆ.** សមាសភាព និងសិទ្ធិអំណាចរបស់ក្រុមប្រឹក្សាជំនុំជម្រះនៃ គ.ជ.ប ត្រូវអនុវត្តតាមលក្ខខណ្ឌដូចមានចែងក្នុងជំពូកទី៣ នៃសៀវភៅណែនាំនេះ។

## ៤. គំនូសបំព្រួញរយៈពេលនៃការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងពាក់ព័ន្ធនឹងជនដែលមិនមែនជាមន្ត្រីបោះឆ្នោត ឬគណបក្សនយោបាយ

គំនូសបំព្រួញទី ៣

**បណ្តឹងពាក់ព័ន្ធនឹងជនដែលមិនមែនជាមន្ត្រីបោះឆ្នោត ឬគណបក្សនយោបាយ**



## II. ពាក្យបណ្ដឹងពាក់ព័ន្ធនឹងជនដែលជាមន្ត្រីបោះឆ្នោត

គ្រប់ពាក្យបណ្ដឹងពាក់ព័ន្ធនឹងអំពើបំពានលើបទប្បញ្ញត្តិនៃ ច.ប.ឃ.ស ប.ន.ឃ.ស និងបទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប ដែលប្ដឹង គ.ក.ប/គ.ក.រ ឬ គឃ.សប ឬ គធ.ខប ឬមន្ត្រីបោះឆ្នោត ត្រូវដាក់ទៅថ្នាក់លើមួយថ្នាក់ ក្នុងរយៈពេល ៣ (បី) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃកើតហេតុ។

**ក.** ពាក្យបណ្ដឹងពាក់ព័ន្ធនឹងសមាសភាព គ.ក.ប/គ.ក.រ ដំបូងត្រូវប្ដឹងទៅ គឃ.សប តាមលក្ខខណ្ឌដូចបានណែនាំក្នុងសៀវភៅណែនាំនេះ **(ទំព័រ ១៥ ដល់ទំព័រ ២៩)**។

**ខ.** ពាក្យបណ្ដឹងពាក់ព័ន្ធនឹងសមាសភាព គឃ.សប ត្រូវប្ដឹងទៅ គធ.ខប តាមលក្ខខណ្ឌដូចបានណែនាំក្នុងសៀវភៅណែនាំនេះ **(ទំព័រ ២០ ដល់ទំព័រ ២៩)**។

**គ.** ពាក្យបណ្ដឹងពាក់ព័ន្ធនឹងសមាសភាព គធ.ខប ឬមន្ត្រី លគធ.ខប ឬមន្ត្រី គ.ជ.ប ត្រូវប្ដឹងទៅ គ.ជ.ប តាមលក្ខខណ្ឌដូចបានណែនាំក្នុងសៀវភៅណែនាំនេះ **(ទំព័រ ២៥ ដល់ទំព័រ ២៩)**។

**ឃ.** ពាក្យបណ្ដឹងពាក់ព័ន្ធនឹងសមាសភាព គ.ជ.ប ត្រូវប្ដឹងទៅរដ្ឋសភា ដោយអនុលោមតាម ច.គ.ជ.ប ។

ពាក្យបណ្ដឹងពាក់ព័ន្ធនឹងការប្រព្រឹត្តកំហុសផ្នែករដ្ឋបាល ដែលអាចនាំឱ្យផ្ទុយពីបទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប រួមមាន ការចោទប្រកាន់សមាជិក ឬមន្ត្រីដែលបដិសេធមិនទទួលពាក្យបណ្ដឹងដោយគ្មានមូលហេតុ និងគតិច្បាប់ត្រឹមត្រូវ ឬ/និងមិនព្រមដោះស្រាយពាក្យបណ្ដឹងដែលសមាជិក ឬមន្ត្រីនោះបានទទួលពាក្យបណ្ដឹងរួចហើយ ជាអាទិ៍ អ្នកប្ដឹងត្រូវដាក់ពាក្យបណ្ដឹងទៅថ្នាក់លើមួយថ្នាក់ ក្នុងរយៈពេល ៣ (បី) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃប្រព្រឹត្តកំហុស។

**ក្នុងករណីដែលរកឃើញថា ៖**

- សមាជិក ឬមន្ត្រីនោះ ពិតជាបានប្រព្រឹត្តផ្ទុយពីបទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប ប្រាកដមែន សមាជិក ឬមន្ត្រីនោះត្រូវទទួលទណ្ឌកម្មផ្នែកវិន័យស្របតាមបទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប ។
- សមាជិក ឬមន្ត្រីនោះ បានគោរពតាមបទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប ត្រឹមត្រូវហើយ ត្រូវបដិសេធពាក្យបណ្ដឹងនេះ ហើយពាក្យបណ្ដឹងដែលត្រូវបានចារបដិសេធ និងមិនដោះស្រាយនោះ ក៏ត្រូវបានបដិសេធផងដែរ។

# គំនូសបំព្រួញរយៈពេលនៃការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងពាក់ព័ន្ធនឹងជនដែលជាមន្ត្រីបោះឆ្នោត



# ផ្នែកទី ៥
# បណ្តឹងទាក់ទងនឹងភាពមិនប្រក្រតីនៅមួយថ្ងៃមុនថ្ងៃបោះឆ្នោត និងក្នុងថ្ងៃបោះឆ្នោត

ផ្នែកទី ៥ នេះ ណែនាំអំពីនីតិវិធីនៃការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងទាក់ទងនឹងភាពមិនប្រក្រតីណាមួយដែលកើតមានឡើង ៖

- នៅក្នុងតំបន់បោះឆ្នោតណាមួយក្នុងរយៈពេលនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោតនៅការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោតពាក់ព័ន្ធនៅមួយថ្ងៃមុនថ្ងៃបោះឆ្នោត និងក្នុងថ្ងៃបោះឆ្នោត។
- កិច្ចប្រតិបត្តិការបោះឆ្នោត ឬ/និងកិច្ចប្រតិបត្តិការរាប់សន្លឹកឆ្នោត។

## ១. ការតវ៉ា ឬការជំទាស់ និងការដោះស្រាយនៅ គ.ក.ប/គ.ក.រ

### ១.១ ការតវ៉ា ឬការជំទាស់នៅ គ.ក.ប/គ.ក.រ

**ក.** ភ្នាក់ងារគណបក្សនយោបាយមានសិទ្ធិតវ៉ា ឬជំទាស់ផ្ទាល់ភ្លាមៗចំពោះជនណាម្នាក់ទៅប្រធាន គ.ក.ប/គ.ក.រ ក្នុងករណីដែលជននោះបង្កភាពមិនប្រក្រតីនានាក្នុងពេលកំពុងបោះឆ្នោត ឬរាប់សន្លឹកឆ្នោតនៅការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត ដែលខ្លួនបំពេញការងារសង្កេតការណ៍។

**ខ.** អ្នកតវ៉ា ឬជំទាស់ ត្រូវបញ្ជាក់ពីមូលហេតុ ឬ/និងភស្តុតាងដែលនាំឱ្យប្រធាន គ.ក.ប/គ.ក.រ ជឿថាមានភាពមិនប្រក្រតី ឬមានការបំពាន ច.ប.ឃ.ស ឬ/និង ប.ន.ឃ.ស ។

### ១.២ ការដោះស្រាយការតវ៉ា ឬការជំទាស់នៅ គ.ក.ប/គ.ក.រ

**ក.** ប្រធាន គ.ក.ប/គ.ក.រ ត្រូវដោះស្រាយភ្លាមនូវការតវ៉ា ឬការជំទាស់នោះ។

**ខ.** បើយល់ឃើញថាការតវ៉ា ឬការជំទាស់ទាំងនោះ សមហេតុផលប្រធាន គ.ក.ប/គ.ក.រ ត្រូវបញ្ឈប់ជាបណ្តោះអាសន្ននូវកិច្ចប្រតិបត្តិការបោះឆ្នោត ឬរាប់សន្លឹកឆ្នោត ហើយត្រូវរិះរកវិធានការដើម្បីដោះស្រាយភាពមិនប្រក្រតីទាំងនោះជាបន្ទាន់។

**គ.** បើយល់ឃើញថាការតវ៉ា ឬការជំទាស់មិនសមហេតុផល ប្រធាន គ.ក.ប/គ.ក.រ មានសិទ្ធិបដិសេធការតវ៉ា ឬការជំទាស់នោះ។

**គ.១** ក្នុងការបដិសេធការតវ៉ា ឬការជំទាស់ ប្រធាន គ.ក.ប/គ.ក.រ ត្រូវផ្តល់ហេតុផលពាក់ព័ន្ធនឹងការបដិសេធ រួចកត់ត្រាការតវ៉ា ឬការជំទាស់នោះចូលក្នុងកំណត់ហេតុនៃការបោះឆ្នោត ឬការរាប់សន្លឹកឆ្នោត ប្រសិនបើអ្នកតវ៉ា ឬជំទាស់យល់ព្រម ចុះហត្ថលេខា។

**គ.២** ប្រសិនបើអ្នកតវ៉ា ឬជំទាស់មិនយល់ព្រមចុះហត្ថលេខាទេនោះ ប្រធាន គ.ក.ប/គ.ក.រ មិនចាំបាច់កត់ត្រាអំពីការតវ៉ា ឬការជំទាស់ ក្នុងកំណត់ហេតុនៃការបោះឆ្នោត ឬការរាប់សន្លឹកឆ្នោតទេ។

**គ.៣** ប្រសិនបើមានការស្នើសុំ ប្រធាន គ.ក.ប/គ.ក.រ ត្រូវផ្តល់ ទ.១២០២ ចំនួន ៣ (បី) ច្បាប់ ដល់អ្នកតវ៉ា ឬជំទាស់នោះ ដើម្បីប្តឹងបន្តទៅ គឃ.សប និងជម្រាបគាត់ថា រយៈពេលប្តឹងត្រូវធ្វើជាបន្ទាន់ ស្របពេលនឹងការបញ្ជូន ស្បោង "ខ" ព្រមទាំងសម្ភារ ឯកសារ បោះឆ្នោតផ្សេងទៀតទៅ គឃ.សប នៅពេលល្ងាចនៃថ្ងៃបោះឆ្នោត ឬយ៉ាងយូរបំផុតត្រឹមម៉ោង ១១:៣០ នាទីព្រឹក នៃថ្ងៃបន្ទាប់ពីថ្ងៃ បោះឆ្នោត។

**ឃ.** ការសម្រេចរបស់ប្រធាន គ.ក.ប/គ.ក.រ ជាការសម្រេចក្នុងកម្រិត សមត្ថកិច្ចរបស់ខ្លួន។

**ង.** ការសម្រេចរបស់ប្រធាន គ.ក.ប/គ.ក.រ ត្រូវតែមានប្រសិទ្ធភាព ហើយ ប្រធាន គ.ក.ប/គ.ក.រ មានសិទ្ធិប្រកាសបន្តដំណើរការបោះឆ្នោត ឬ រាប់សន្លឹកឆ្នោតតទៅទៀត។

## ២. ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងនៅ គឃ.សប

### ២.១ ការដាក់ និងការទទួលពាក្យបណ្តឹងនៅ គឃ.សប

**ក.** ការដាក់ពាក្យបណ្តឹងទៅ គឃ.សប ត្រូវធ្វើឡើងជាបន្ទាន់ ស្របពេល នឹងការបញ្ជូន ស្បោង "ខ" ព្រមទាំងសម្ភារ ឯកសារបោះឆ្នោតផ្សេងទៀត ទៅ គឃ.សប នៅពេលល្ងាចនៃថ្ងៃបោះឆ្នោត ឬយ៉ាងយូរបំផុតត្រឹម ម៉ោង ១១:៣០ នាទីព្រឹក នៃថ្ងៃបន្ទាប់ពីថ្ងៃបោះឆ្នោត។

**ខ.** ភ្នាក់ងារគណបក្សនយោបាយដែលមានបំណងប្តឹងត្រូវបំពេញ និង ចុះហត្ថលេខា ឬផ្តិតមេដៃលើពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ ទ.១២០២ ចំនួន ៣ (បី) ច្បាប់ ក្នុងនោះត្រូវផ្តល់ព័ត៌មានចាំបាច់មួយចំនួន ដូចមានចែងក្នុង**ចំណុច ១.ពាក្យបណ្តឹង (ទំព័រ៧)** នៃសៀវភៅណែនាំនេះ។

**គ.** ចំពោះពាក្យបណ្តឹងដែលបានទទួលក្រោយរយៈពេលកំណត់ ដូចមាន ចែងក្នុងចំណុច ក (**ទំព័រ៣៥**) ប្រធាន គឃ.សប ឬសមាជិកដែលបាន ទទួលសិទ្ធិជាលាយលក្ខណ៍អក្សរ ត្រូវចារបដិសេធលើពាក្យបណ្តឹង គ្រប់ច្បាប់ដោយបញ្ជាក់អំពីមូលហេតុ ហើយចុះហត្ថលេខា ឈ្មោះ បោះត្រា គឃ.សប និងចុះកាលបរិច្ឆេទ រួចប្រគល់ជូនអ្នកប្តឹងវិញ ១ (មួយ) ច្បាប់

រក្សាទុកជាឯកសារ ១ (មួយ) ច្បាប់ ផ្ញើជូន គធ.ខប ១ (មួយ) ច្បាប់ និង ប្រាប់អ្នកប្តឹងថា ពាក្យបណ្តឹងរបស់គាត់ដែលបានដាក់នៅក្រោយពេលកំណត់ គឃ.សប មិនអាចទទួលយកមកដោះស្រាយបានទេ។

**ឃ.** ចំពោះពាក្យបណ្តឹងមិនមានបញ្ជាក់ព័ត៌មានចាំបាច់ គឃ.សប ត្រូវណែនាំអ្នកប្តឹង ឬតំណាងឱ្យបំពេញបន្ថែមនូវចំណុចខ្វះខាតមិនឱ្យហួសរយៈពេលកំណត់នៃការដាក់ពាក្យបណ្តឹង ហើយកត់ត្រាក្នុងកំណត់ហេតុ។ ក្នុងករណីដែលដល់ពេលកំណត់ អ្នកប្តឹង ឬតំណាងមិនបានបំពេញបន្ថែមនូវចំណុចខ្វះខាត ប្រធាន គឃ.សប ត្រូវចារបដិសេធលើពាក្យបណ្តឹងគ្រប់ច្បាប់ដោយបញ្ជាក់អំពីមូលហេតុ ហើយចុះហត្ថលេខា ឈ្មោះ បោះត្រា គឃ.សប និងចុះកាលបរិច្ឆេទ រួចប្រគល់ឱ្យអ្នកប្តឹងវិញ ១ (មួយ) ច្បាប់ ផ្ញើជូន គធ.ខប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

**ង.** ចំពោះពាក្យបណ្តឹងដែលបានទទួលក្នុងរយៈពេលកំណត់ ដូចមានចែងក្នុងចំណុច ក **(ទំព័រ៣៥)** និងមានបញ្ជាក់ព័ត៌មានចាំបាច់ សមាជិកទទួលបន្ទុកលើការងារសេវាកម្មច្បាប់ និងវិវាទកម្ម និងសន្តិសុខបោះឆ្នោត ឬសមាជិកដែលបានទទួលសិទ្ធិជាលាយលក្ខណ៍អក្សរ ត្រូវធ្វើកំណត់ហេតុសាកសួរបន្ថែមពីអ្នកប្តឹង ឬតំណាង ដោយត្រូវកត់ត្រា រួចឱ្យអ្នកប្តឹង ឬតំណាងនោះ ចុះហត្ថលេខា ឬផ្តិតមេដៃលើកំណត់ហេតុ។ ក្នុងករណីអ្នកប្តឹង ឬតំណាងមិនព្រមចុះហត្ថលេខា ឬផ្តិតមេដៃ សមាជិកទទួលបន្ទុកលើការងារសេវាកម្មច្បាប់ និងវិវាទកម្ម និងសន្តិសុខបោះឆ្នោត ឬសមាជិកដែលបានទទួលសិទ្ធិ ត្រូវចុះនិទ្ទេសបញ្ជាក់ពីការមិនព្រមចុះហត្ថលេខា ឬផ្តិតមេដៃលើកំណត់ហេតុនេះ។ បន្ទាប់មក ត្រូវចុះកាលបរិច្ឆេទ ពេលវេលា ហើយចុះហត្ថលេខា ឈ្មោះ បោះត្រា គឃ.សប លើពាក្យបណ្តឹងគ្រប់ច្បាប់ រួចប្រគល់ឱ្យអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ បិទផ្សាយជាសាធារណៈនៅ គឃ.សប ១ (មួយ) ច្បាប់ និងទុក ១ (មួយ) ច្បាប់សម្រាប់ គឃ.សប ប្រើក្នុងពេលប្រជុំសម្រេច។

## ២.២ ការដោះស្រាយពាក្យបណ្តឹងនៅ គឃ.សប

**ក.** គឃ.សប ត្រូវប្រជុំសម្រេចលើពាក្យបណ្តឹង បន្ទាប់ពីបានត្រួតពិនិត្យផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការរាប់សន្លឹកឆ្នោតនៃការិយាល័យមានពាក្យបណ្តឹង ក្នុងរយៈពេលយ៉ាងយូរ ៣ (បី) ថ្ងៃបន្ទាប់ពីថ្ងៃបានទទួលកំណត់ហេតុនៃការបោះឆ្នោត និងសម្ភារបោះឆ្នោតពីគ្រប់ការិយាល័យរាប់សន្លឹកឆ្នោតទាំងអស់។

ខ. ក្នុងករណីពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់មានពាក់ព័ន្ធនឹងភាពមិនប្រក្រតីណាមួយ ដែលអាចប៉ះពាល់ដល់លទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោត នៅការិយាល័យបោះឆ្នោតណាមួយ ប្រធាន គឃ.សប ត្រូវ ៖

ខ.១ ចាត់ចែងការត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការរាប់សន្លឹកឆ្នោតរបស់ការិយាល័យបោះឆ្នោត ដែលមានពាក្យបណ្តឹង។

ខ.២ បើកកញ្ចប់សុវត្ថិភាព "ក" ដើម្បីធ្វើការត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារឯកសារបោះឆ្នោត និងសន្លឹកឆ្នោត។ ក្នុងការបើកកញ្ចប់សុវត្ថិភាព "ក" នេះ គឃ.សប ពុំមានសិទ្ធិធ្វើការរាប់ និងផ្តល់សុពលភាពសន្លឹកឆ្នោតឡើងវិញបាននោះទេ។

ខ.៣ អនុញ្ញាតឱ្យអ្នកប្តឹង ភ្នាក់ងារគណបក្សនយោបាយដែលឈរឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់នោះ និងអ្នកសង្កេតការណ៍ចូលរួមសង្កេតមើលក្នុងការអនុវត្តនីតិវិធី។

គ. ប្រសិនបើ ក្នុងការត្រួតពិនិត្យឡើងវិញ គឃ.សប មិនឃើញមានភស្តុតាងបញ្ជាក់ថា មានភាពមិនប្រក្រតីណាមួយក្នុងការបោះឆ្នោត ឬ/និងការរាប់សន្លឹកឆ្នោត ដែលអាចធ្វើឱ្យប៉ះពាល់ដល់លទ្ធផលបណ្តោះអាសន្ននៃការរាប់សន្លឹកឆ្នោត នៅការិយាល័យបោះឆ្នោតពាក់ព័ន្ធទេនោះ គឃ.សប ត្រូវប្រជុំសម្រេចលើពាក្យបណ្តឹងនោះ។ ក្នុងករណី គឃ.សប បដិសេធលើពាក្យបណ្តឹង ប្រធាន គឃ.សប ត្រូវ ៖

គ.១ ចាត់សមាជិកទទួលបន្ទុកលើការងារសេវាកម្មច្បាប់ និងវិវាទកម្ម និងសន្តិសុខបោះឆ្នោត ឱ្យបំពេញ ទ.១២០៣ បដិសេធលើពាក្យបណ្តឹងតវ៉ា ឬ/និងពាក្យបណ្តឹងជំទាស់ ចំនួន ៣ (បី) ច្បាប់ និងចុះហត្ថលេខាផង។

គ.២ ចុះហត្ថលេខា ឈ្មោះ បោះត្រា គឃ.សប និងចុះកាលបរិច្ឆេទលើ ទ.១២០៣ រួចប្រគល់ឱ្យអ្នកប្តឹង ១ (មួយ) ច្បាប់ ផ្ញើជូន គជ.ឧប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

គ.៣ ជម្រាបអ្នកប្តឹងថា គាត់អាចប្តឹងតវ៉ាទៅនឹងសេចក្តីសម្រេចរបស់ គឃ.សប ទៅ គជ.ឧប ក្នុងរយៈពេល ៣ (បី) ថ្ងៃយ៉ាងយូរ បន្ទាប់ពី គឃ.សប បានបិទផ្សាយលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់។

គ.៤ ប្រគល់ជូនអ្នកប្តឹងតវ៉ានូវ ទ.១២០២ សម្រាប់បំពេញពាក្យបណ្តឹងតវ៉ា ចំនួន ៣ (បី) ច្បាប់ (បើគាត់ស្នើសុំ)។

**ឃ.** ប្រសិនបើ ក្នុងការត្រួតពិនិត្យឡើងវិញ គឃ.សប បានរកឃើញភស្តុតាងបញ្ជាក់ថា មានភាពមិនប្រក្រតីធ្ងន់ធ្ងរណាមួយក្នុងការបោះឆ្នោត ឬ/និងការរាប់សន្លឹកឆ្នោត ដែលអាចធ្វើឱ្យប៉ះពាល់ដល់លទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតពាក់ព័ន្ធនោះ គឃ.សប ត្រូវប្រជុំសម្រេចលើពាក្យបណ្តឹងនោះ ដោយធ្វើកំណត់ហេតុផង។ ក្នុងករណី គឃ.សប យល់ព្រមតាមពាក្យបណ្តឹង ប្រធាន គឃ.សប ត្រូវ ៖

- **ឃ.១** ចាត់សមាជិកទទួលបន្ទុកលើការងារសេវាកម្មច្បាប់ និងវិវាទកម្ម និងសន្តិសុខបោះឆ្នោត ឱ្យបំពេញ ទ.១២០៣ យល់ព្រមលើពាក្យបណ្តឹងតវ៉ា ឬ/និងពាក្យបណ្តឹងជំទាស់ ចំនួន ៣ (បី) ច្បាប់ និងចុះហត្ថលេខាផង។
- **ឃ.២** ចុះហត្ថលេខា ឈ្មោះ បោះត្រា គឃ.សប និងចុះកាលបរិច្ឆេទលើ ទ.១២០៣ រួចប្រគល់ឱ្យអ្នកប្តឹង ១ (មួយ) ច្បាប់ ផ្ញើជូន គធ.ខប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់ និងជម្រាបអ្នកប្តឹងថា គឃ.សប នឹងធ្វើរបាយការណ៍ និងលើកយោបល់ស្តីពីករណីនេះ ផ្ញើអមជាមួយកំណត់ហេតុបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១០៣) ជូន គធ.ខប ដើម្បីពិនិត្យ សម្រេច។

## ៣. ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងនៅ គធ.ខប

### ៣.១ ការដាក់ និងការទទួលពាក្យបណ្តឹងនៅ គធ.ខប

**ក.** ជនគ្រប់រូបដែលបានចុះឈ្មោះបោះឆ្នោត និងមានឈ្មោះក្នុងបញ្ជីបោះឆ្នោតក្នុងឃុំ សង្កាត់ ឬគណបក្សនយោបាយដែលមានបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ ដែលមានភស្តុតាងច្បាស់លាស់បញ្ជាក់អំពីភាពមិនប្រក្រតីធ្ងន់ធ្ងរណាមួយក្នុងដំណើរការបោះឆ្នោត ដែលនាំឱ្យផ្លាស់ប្តូរលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ ឬអ្នកប្តឹងមិនសុខចិត្តនឹងការសម្រេចរបស់ គឃ.សប អាចធ្វើការប្តឹងជំទាស់ជាលាយលក្ខណ៍អក្សរទៅ គធ.ខប ក្នុងរយៈពេលយ៉ាងយូរ ៣ (បី) ថ្ងៃ បន្ទាប់ពីថ្ងៃ គឃ.សប បិទផ្សាយកំណត់ហេតុបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់។

**ខ.** អ្នកប្តឹងត្រូវបំពេញ និងចុះហត្ថលេខា ឬផ្តិតមេដៃលើ ទ.១២០២ ចំនួន ៣ (បី) ច្បាប់ ក្នុងនោះត្រូវផ្តល់ព័ត៌មានចាំបាច់មួយចំនួន ដូចមានចែងក្នុង**ចំណុច ១.ពាក្យបណ្តឹង (ទំព័រ៧)** នៃសៀវភៅណែនាំនេះ។

**គ.** ចំពោះពាក្យបណ្តឹងដែលបានទទួលក្រោយរយៈពេលកំណត់ ដូចមានចែងក្នុងចំណុច ក **(ទំព័រ៣៩)** ប្រធាន គធ.ខប ឬសមាជិកដែលបានទទួលសិទ្ធិជាលាយលក្ខណ៍អក្សរ ត្រូវចារបដិសេធលើពាក្យបណ្តឹងគ្រប់ច្បាប់ដោយបញ្ជាក់អំពីមូលហេតុ ហើយចុះហត្ថលេខា ឈ្មោះ បោះត្រា គធ.ខប និងចុះកាលបរិច្ឆេទ រួចប្រគល់ឱ្យអ្នកប្តឹង ១ (មួយ) ច្បាប់ រក្សាទុកជាឯកសារ ១ (មួយ) ច្បាប់ ផ្ញើជូន គ.ជ.ប ១ (មួយ) ច្បាប់ និងជម្រាបអ្នកប្តឹងថា ពាក្យបណ្តឹងរបស់គាត់ដែលបានដាក់នៅក្រោយរយៈពេលកំណត់ គធ.ខប មិនអាចទទួលយកមកដោះស្រាយបានទេ។

**ឃ.** ចំពោះពាក្យបណ្តឹង មិនមានបញ្ជាក់ព័ត៌មានចាំបាច់ គធ.ខប ត្រូវណែនាំអ្នកប្តឹងឱ្យបំពេញបន្ថែមនូវចំណុចខ្វះខាតមិនឱ្យហួសរយៈពេលនៃការដាក់ពាក្យបណ្តឹង ហើយកត់ត្រាក្នុងកំណត់ហេតុសាកសួរ។ ក្នុងករណីដែលដល់ពេលកំណត់ អ្នកប្តឹងមិនបានបំពេញបន្ថែមនូវចំណុចខ្វះខាត ប្រធាន គធ.ខប ត្រូវចារបដិសេធលើពាក្យបណ្តឹងគ្រប់ច្បាប់ដោយបញ្ជាក់អំពីមូលហេតុ ហើយចុះហត្ថលេខា ឈ្មោះ បោះត្រា គធ.ខប និងចុះកាលបរិច្ឆេទ រួចប្រគល់ជូនអ្នកប្តឹង ១ (មួយ) ច្បាប់ រក្សាទុកជាឯកសារ ១ (មួយ) ច្បាប់ និងផ្ញើជូន គ.ជ.ប ១ (មួយ) ច្បាប់។

**ង.** ចំពោះពាក្យបណ្តឹងដែលបានទទួលក្នុងរយៈពេលកំណត់ និងមានព័ត៌មានចាំបាច់ មន្ត្រីទទួលពាក្យបណ្តឹងនៃ គធ.ខប ត្រូវចុះពេលវេលា និងកាលបរិច្ឆេទនៃការទទួលពាក្យបណ្តឹង ប្រគល់ជូនអ្នកប្តឹង ១ (មួយ) ច្បាប់ បិទផ្សាយជាសាធារណៈ ១ (មួយ) ច្បាប់ និងទុក ១ (មួយ) ច្បាប់ សម្រាប់ គធ.ខប ប្រើក្នុងពេលប្រជុំសម្រេច។ បន្ទាប់មកប្រាប់អ្នកប្តឹងថា គធ.ខប នឹងប្រជុំសម្រេចលើពាក្យបណ្តឹងរបស់គាត់ បន្ទាប់ពីក្រុមត្រួតពិនិត្យលទ្ធផលបានបញ្ចប់ការត្រួតពិនិត្យលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ ពាក់ព័ន្ធនឹងពាក្យបណ្តឹងនោះ។

## ៣.២ ការដោះស្រាយពាក្យបណ្តឹងនៅ គធ.ខប

**ក.** គធ.ខប ត្រូវសម្រេចលើពាក្យបណ្តឹងក្នុងរយៈពេលយ៉ាងយូរ ៥ (ប្រាំ) ថ្ងៃ បន្ទាប់ពីបានទទួលពាក្យបណ្តឹង។

**ខ.** ក្រុមត្រួតពិនិត្យលទ្ធផលនៃ គធ.ខប ដែលធ្វើការត្រួតពិនិត្យលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនៅឃុំ សង្កាត់ដែលមានបណ្តឹងនេះ ត្រូវអនុវត្តបន្ថែមតាមលក្ខខណ្ឌដូចខាងក្រោម ៖

ខ.១ ក្រុមត្រួតពិនិត្យលទ្ធផល ត្រូវត្រួតពិនិត្យជាមុននូវសម្រង់សេចក្ដីសម្រេចរបស់ គឃ.សប លើពាក្យបណ្ដឹងពាក់ព័ន្ធ របាយការណ៍របស់ គឃ.សប ស្ដីពីការបើកកញ្ចប់សុវត្ថិភាព "ក" ដើម្បីត្រួតពិនិត្យ ផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោត និងពាក្យបណ្ដឹងតវ៉ា ឬពាក្យបណ្ដឹងជំទាស់ពាក់ព័ន្ធនឹងឃុំ សង្កាត់ដែលបានដាក់នៅ គធ.ខប ហើយត្រូវស្នើសុំយោបល់សម្រេចរបស់ គធ.ខប អំពីការអនុញ្ញាតឱ្យបើក ឬមិនឱ្យបើកកញ្ចប់សុវត្ថិភាព "ក" នៃការិយាល័យបោះឆ្នោតពាក់ព័ន្ធ។

ខ.២ ផ្អែកតាមឯកសារខាងលើ ក្នុងករណីគ្មានភាពមិនប្រក្រតីធ្ងន់ធ្ងរ គធ.ខប មិនចាំបាច់តម្រូវឱ្យបើកកញ្ចប់សុវត្ថិភាព "ក" ដើម្បីត្រួតពិនិត្យ ផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោតឡើងវិញឡើយ។

ខ.៣ ផ្អែកតាមឯកសារខាងលើ ក្នុងករណីមានភាពមិនប្រក្រតីធ្ងន់ធ្ងរដែលនាំឱ្យប៉ះពាល់លទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ពាក់ព័ន្ធ គធ.ខប ត្រូវសម្រេចឱ្យបើកកញ្ចប់សុវត្ថិភាព "ក" ដើម្បីត្រួតពិនិត្យ ផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោតឡើងវិញ។

ខ.៤ ក្នុងការត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោតខាងលើនេះ ត្រូវធ្វើនៅចំពោះមុខភ្នាក់ងារគណបក្សនយោបាយ អ្នកសង្កេតការណ៍ និងអ្នកប្ដឹង ឬអ្នកពាក់ព័ន្ធ។

គ. ប្រសិនបើ គធ.ខប សម្រេចយល់ព្រមទទួលយកលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតនៅឃុំ សង្កាត់ ឬនៅការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់ គធ.ខប ត្រូវបដិសេធសេចក្ដីសម្រេចរបស់ គឃ.សប ដែលបានយល់ព្រមតាមពាក្យបណ្ដឹងពាក់ព័ន្ធ និងបដិសេធពាក្យបណ្ដឹងតវ៉ា ឬពាក្យបណ្ដឹងជំទាស់ដែលបានដាក់នៅ គធ.ខប ។ ប្រធាន គធ.ខប ត្រូវ៖

គ.១ ចារយល់ព្រមលើតារាងត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១១៦គ៣) និងលើរបាយការណ៍ស្ដីពីការបើកកញ្ចប់សុវត្ថិភាព "ក" ដើម្បីត្រួតពិនិត្យ ផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោតឡើងវិញ របស់ក្រុមត្រួតពិនិត្យលទ្ធផល ឬ/និង លើរបាយការណ៍របស់ គឃ.សប ស្ដីពីការបើកកញ្ចប់សុវត្ថិភាព "ក" ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារឯកសារបោះឆ្នោតនិងសន្លឹកឆ្នោត

ដែលបានដាក់ភ្ជាប់ជាមួយសំណុំឯកសារពាក់ព័ន្ធជូន គធ.ខប ពិនិត្យ សម្រេច រួចចុះហត្ថលេខា ឈ្មោះ បោះត្រា និងកាលបរិច្ឆេទ ព្រមទាំងដាក់បង្ហាញចំពោះអ្នកប្តឹង ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ដែលមានវត្តមាន។

**គ.២** ចារបដិសេធលើ ទ.១២០៣ របស់ គឃ.សប ដែលបានយល់ព្រមលើពាក្យបណ្តឹងពាក់ព័ន្ធ រួចចុះហត្ថលេខា ឈ្មោះ បោះត្រា និងកាលបរិច្ឆេទ។

**គ.៣** ធានាថាសមាជិក គធ.ខប ដែលជាប្រធានផ្នែកសេវាកម្មច្បាប់ វិវាទកម្ម និងសន្តិសុខបោះឆ្នោតបានបំពេញ ទ.១២០៣ របស់ គធ.ខប យល់ព្រមទទួលយកលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនៅឃុំ សង្កាត់ ឬនៅការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់ពាក់ព័ន្ធ និងត្រូវបដិសេធពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ដែលដាក់នៅ គធ.ខប ដោយបញ្ជាក់ច្បាស់អំពីមូលហេតុ ហើយត្រូវចុះហត្ថលេខា ឈ្មោះ បោះត្រា និងកាលបរិច្ឆេទ ដោយសមាជិក គធ.ខប ដែលជាប្រធានផ្នែកសេវាកម្មច្បាប់ វិវាទកម្ម និងសន្តិសុខបោះឆ្នោត និងប្រធាន គធ.ខប ។

**គ.៤** ប្រគល់ ទ.១២០៣ របស់ គធ.ខប យល់ព្រមទទួលយកលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោត ជូនអ្នកប្តឹង ១ (មួយ) ច្បាប់ ជូនគ្រប់ភ្នាក់ងារគណបក្សនយោបាយឈរឈ្មោះក្នុងឃុំ សង្កាត់ ១ (មួយ) ច្បាប់ ផ្ញើជូន គ.ជ.ប ១ (មួយ) ច្បាប់ ផ្ញើជូន គឃ.សប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

**គ.៥** ជម្រាបអ្នកប្តឹងថា គាត់មានសិទ្ធិដាក់ពាក្យបណ្តឹងតវ៉ាទៅនឹងសេចក្តីសម្រេចរបស់ គធ.ខប នៅ គ.ជ.ប ក្នុងរយៈពេលយ៉ាងយូរ ៤ (បួន) ថ្ងៃ បន្ទាប់ពីថ្ងៃបានទទួល ទ.១២០៣ របស់ គធ.ខប ។

**គ.៦** ប្រគល់ ទ.១២០២ ចំនួន ៣ (បី) ច្បាប់ ជូនអ្នកប្តឹង ប្រសិនបើគាត់ស្នើសុំ។

**ឃ.** ប្រសិនបើ គធ.ខប សម្រេចព្យួរលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនៅក្នុងឃុំ សង្កាត់ណាមួយ គធ.ខប ត្រូវយល់ព្រមតាមសេចក្តីសម្រេចរបស់ គឃ.សប និងត្រូវបដិសេធលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនៅឃុំ សង្កាត់ ឬនៅការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់ពាក់ព័ន្ធ ហើយយល់ព្រមតាមពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ដែលបានដាក់នៅ គធ.ខប ប្រធាន គធ.ខប ត្រូវ ៖

ឃ.១ ចារព្យួរលទ្ធផលលើតារាងត្រួតពិនិត្យលទ្ធផល និងលើរបាយការណ៍ស្ដីពីការបើកកញ្ចប់សុវត្ថិភាព "ក" ដើម្បីត្រួតពិនិត្យ ផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោតឡើងវិញ របស់ក្រុមត្រួតពិនិត្យលទ្ធផលដែលបានដាក់ជូន គធ.ឃប ពិនិត្យសម្រេច រួចចុះហត្ថលេខា ឈ្មោះ បោះត្រា និងកាលបរិច្ឆេទ ព្រមទាំងដាក់បង្ហាញចំពោះមុខអ្នកប្ដឹង ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ដែលមានវត្តមាន។

ឃ.២ ចារយល់ព្រមលើ ទ.១២០៣ របស់ គឃ.សប ដែលបានយល់ព្រមតាមពាក្យបណ្ដឹងតវ៉ា ឬពាក្យបណ្ដឹងជំទាស់ពាក់ព័ន្ធ រួចចុះហត្ថលេខា ឈ្មោះ បោះត្រា និងកាលបរិច្ឆេទ។

ឃ.៣ ធានាថាសមាជិក គធ.ឃប ដែលជាប្រធានផ្នែកសេវាកម្មច្បាប់ វិវាទកម្ម និងសន្តិសុខបោះឆ្នោត បានបំពេញ ទ.១២០៣ របស់ គធ.ឃប បដិសេធលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតនៅឃុំ សង្កាត់ ឬនៅការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់ពាក់ព័ន្ធ និងត្រូវយល់ព្រមតាមពាក្យបណ្ដឹងតវ៉ា ឬពាក្យបណ្ដឹងជំទាស់ ដែលបានដាក់នៅ គធ.ឃប ដោយបញ្ជាក់ច្បាស់អំពីមូលហេតុផង ហើយដែលត្រូវចុះហត្ថលេខា ឈ្មោះ បោះត្រា និងកាលបរិច្ឆេទ ដោយសមាជិក គធ.ឃប ដែលជាប្រធានផ្នែកសេវាកម្មច្បាប់ វិវាទកម្ម និងសន្តិសុខបោះឆ្នោត និងប្រធាន គធ.ឃប ។

ឃ.៤ ប្រគល់ ទ.១២០៣ របស់ គធ.ឃប បដិសេធលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតខាងលើ ជូនអ្នកប្ដឹង ១ (មួយ) ច្បាប់ ជូនគ្រប់ភ្នាក់ងារគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ក្នុងឃុំ សង្កាត់ ១ (មួយ) ច្បាប់ ផ្ញើជូន គ.ជ.ប ១ (មួយ) ច្បាប់ ផ្ញើជូន គឃ.សប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

ឃ.៥ ប្រកាសថា លទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតនៅឃុំ សង្កាត់ ឬនៅការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់នោះ ត្រូវបានបដិសេធដោយ គធ.ឃប ហើយសេចក្ដីសម្រេចនេះស្ថិតក្រោមការពិនិត្យឡើងវិញរបស់ គ.ជ.ប ។

**ឃ.៦** បញ្ជូន ទ.១២០៣ បដិសេធលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតនៅឃុំ សង្កាត់នោះ ឬនៅការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់នោះ និងសម្ភារ ឯកសារបោះឆ្នោតពាក់ព័ន្ធជូន គ.ជ.ប មិនឱ្យលើសពី ២៤ (ម្ភៃបួន) ម៉ោង គិតចាប់ពីពេលចេញ ទ.១២០៣ ។

## ៤. ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្ដឹងនៅ គ.ជ.ប

### ៤.១ ការដាក់ និងការទទួលពាក្យបណ្ដឹងនៅ គ.ជ.ប

**ក.** អ្នកប្ដឹង ឬភ្នាក់ងារគណបក្សនយោបាយ ឬតំណាង ដែលមិនសុខចិត្តនឹងសេចក្ដីសម្រេចបដិសេធរបស់ គធ.ខប លើពាក្យបណ្ដឹងរបស់ខ្លួនពាក់ព័ន្ធនឹងលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតនៅឃុំ សង្កាត់ ឬនៅការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់ មានសិទ្ធិដាក់ពាក្យបណ្ដឹងជាលាយលក្ខណ៍អក្សរទៅ គ.ជ.ប ក្នុងរយៈពេល ៤ (បួន) ថ្ងៃបន្ទាប់ពីថ្ងៃបានទទួល ទ.១២០៣ បដិសេធ។

**ខ.** អ្នកប្ដឹង ឬតំណាងត្រូវបំពេញ និងចុះហត្ថលេខា ឬផ្ដិតមេដៃលើពាក្យបណ្ដឹងរបស់ខ្លួន ដែលក្នុងនោះត្រូវផ្ដល់ព័ត៌មានចាំបាច់ ដូចមានចែងក្នុង **ចំណុច ១.ពាក្យបណ្ដឹង (ទំព័រ៧)** នៃសៀវភៅណែនាំនេះ។

**គ.** ចំពោះពាក្យបណ្ដឹងតវ៉ា ដែលត្រូវបានដាក់ក្រោយរយៈពេលកំណត់ ដូចមានចែងក្នុងចំណុច ក **(ទំព័រ៤៣)** ខាងលើ មន្ត្រីទទួល និងពិនិត្យពាក្យបណ្ដឹងនៅ គ.ជ.ប ត្រូវចុះពេលវេលា និងកាលបរិច្ឆេទឱ្យបានច្បាស់លាស់ រួចដាក់ជូន គ.ជ.ប តាមឋានានុក្រម ចារបដិសេធលើពាក្យបណ្ដឹងគ្រប់ច្បាប់ ចុះហត្ថលេខា ឈ្មោះ បោះត្រា គ.ជ.ប និងចុះកាលបរិច្ឆេទលើពាក្យបណ្ដឹងនោះ ហើយប្រគល់ជូនអ្នកប្ដឹង ឬតំណាង ១ (មួយ) ច្បាប់ រក្សាទុកជាឯកសារ ២ (ពីរ) ច្បាប់ និងជម្រាបអ្នកប្ដឹង ឬតំណាងថាពាក្យបណ្ដឹងរបស់គាត់ដែលបានដាក់នៅក្រោយរយៈពេលកំណត់ គ.ជ.ប មិនអាចទទួលដោះស្រាយបានទេ។

**ឃ.** ចំពោះពាក្យបណ្ដឹងតវ៉ា ដែលគ្មានបញ្ជាក់ព័ត៌មានចាំបាច់ គ.ជ.ប ត្រូវណែនាំអ្នកប្ដឹង ឬតំណាងឱ្យបំពេញបន្ថែមនូវចំណុចខ្វះខាតមិនឱ្យហួសរយៈពេលកំណត់នៃការដាក់ពាក្យបណ្ដឹង រួចកត់ត្រាក្នុងកំណត់ហេតុ។ ក្នុងករណីដែលដល់ពេលកំណត់ហើយ អ្នកប្ដឹង ឬតំណាងមិនបានបំពេញបន្ថែមនូវចំណុចខ្វះខាតនោះទេ គ.ជ.ប ត្រូវចារបដិសេធលើពាក្យបណ្ដឹងគ្រប់ច្បាប់ ដោយបញ្ជាក់អំពីមូលហេតុនៃការបដិសេធឱ្យបានច្បាស់លាស់ រួចចុះហត្ថលេខា ឈ្មោះ បោះត្រា គ.ជ.ប និងចុះកាលបរិច្ឆេទ ហើយប្រគល់ជូនអ្នកប្ដឹង ឬតំណាង ចំនួន ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារចំនួន ២ (ពីរ) ច្បាប់។

ង. ចំពោះពាក្យបណ្ដឹងតវ៉ា ដែលត្រូវបានដាក់ក្នុងរយៈពេលកំណត់ ដូចមានចែងក្នុងចំណុច ក **(ទំព័រ៤៣)** និងមានបញ្ជាក់ព័ត៌មានចាំបាច់ មន្ត្រីទទួលនិងពិនិត្យពាក្យបណ្ដឹងនៃ គ.ជ.ប ត្រូវធ្វើកំណត់ហេតុសួរយកព័ត៌មានបន្ថែមពីអ្នកប្ដឹង ឬតំណាង ដោយត្រូវកត់ត្រា រួចឱ្យអ្នកប្ដឹង ឬតំណាងចុះហត្ថលេខា ឬផ្ដិតមេដៃលើកំណត់ហេតុ។ ក្នុងករណីអ្នកប្ដឹង ឬតំណាងមិនព្រមចុះហត្ថលេខា ឬផ្ដិតមេដៃ មន្ត្រីទទួលនិងពិនិត្យពាក្យបណ្ដឹងត្រូវចុះនិទ្ទេសបញ្ជាក់ពីការមិនព្រមចុះហត្ថលេខា ឬផ្ដិតមេដៃលើកំណត់ហេតុនេះ។ បន្ទាប់មកត្រូវចុះពេលវេលា និងកាលបរិច្ឆេទនៃការទទួលពាក្យបណ្ដឹង ហើយត្រូវប្រគល់ពាក្យបណ្ដឹងនោះ ១ (មួយ) ច្បាប់ជូនអ្នកប្ដឹង ឬតំណាង ប្រាប់អ្នកប្ដឹង ឬតំណាងថា គ.ជ.ប នឹងសម្រេចលើពាក្យបណ្ដឹងតវ៉ារបស់គាត់ បន្ទាប់ពីក្រុមត្រួតពិនិត្យលទ្ធផលនៃ គ.ជ.ប បានបញ្ចប់ការត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ពាក់ព័ន្ធនឹងពាក្យបណ្ដឹងនោះ បិទផ្សាយពាក្យបណ្ដឹងនេះ ១ (មួយ) ច្បាប់ជាសាធារណៈ ត្រៀមពាក្យបណ្ដឹង ១ (មួយ) ច្បាប់ សម្រាប់ គ.ជ.ប ប្រើពេលសវនាការ។

## ៤.២ ការដោះស្រាយពាក្យបណ្ដឹងនៅ គ.ជ.ប

ក. នាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្មនៃអគ្គនាយកដ្ឋានសេវាកម្មច្បាប់ និងបច្ចេកទេស ត្រូវរាយការណ៍ជាបន្ទាន់ជូន គ.ជ.ប តាមរយៈអគ្គលេខាធិការ គ.ជ.ប អំពីករណីនៃបណ្ដឹងដោយភ្ជាប់ពាក្យបណ្ដឹងតវ៉ាដែលបានទទួល និង ទ.១២០៣ របស់ គធ.ឃប បដិសេធលើពាក្យបណ្ដឹងតវ៉ា ឬពាក្យបណ្ដឹងជំទាស់ និងសុំការណែនាំពី គ.ជ.ប អំពីករណីនៃការត្រួតពិនិត្យលទ្ធផល និងភាពចាំបាច់ ឬមិនចាំបាច់ឱ្យបើកកញ្ចប់សុវត្ថិភាព "ក" ដើម្បីត្រួតពិនិត្យ ផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោតឡើងវិញ។ ផ្អែកតាមការណែនាំខាងលើនេះ អគ្គលេខាធិការ គ.ជ.ប ត្រូវចាត់ចែងក្រុមត្រួតពិនិត្យ និងបូកសរុបលទ្ធផល ឱ្យធ្វើការត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ពាក់ព័ន្ធនឹងពាក្យបណ្ដឹងនោះនៅចំពោះមុខភ្នាក់ងារគណបក្សនយោបាយពាក់ព័ន្ធ អ្នកប្ដឹង ឬតំណាង និងអ្នកសង្កេតការណ៍។

ខ. គ.ជ.ប ត្រូវសម្រេចលើពាក្យបណ្ដឹងតវ៉ា ឬពាក្យបណ្ដឹងជំទាស់ក្នុងរយៈពេលយ៉ាងយូរ ៤ (បួន) ថ្ងៃ បន្ទាប់ពីថ្ងៃបានទទួលពាក្យបណ្ដឹង។

គ. ក្នុងករណី គ.ជ.ប សម្រេចបដិសេធលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតមួយ ឬច្រើន គ.ជ.ប ត្រូវរៀបចំការបោះឆ្នោតសាជាថ្មីក្នុងរយៈពេលមិនឱ្យលើសពី ៣០ (សាមសិប) ថ្ងៃ បន្ទាប់ពីថ្ងៃបដិសេធលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតនោះ នៅទីតាំងដដែល ឬទីតាំងណាមួយមិនឆ្ងាយពីទីតាំងចាស់នៅក្នុងឃុំ សង្កាត់ដែលមានសន្តិសុខ និងសុវត្ថិភាពល្អ។

ឃ. ក្នុងករណី គ.ជ.ប សម្រេចយល់ព្រមទទួលយកលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ ប្រធាន គ.ជ.ប ត្រូវចារយល់ព្រមលើរបាយការណ៍ និងតារាងត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១១៧គ៣) របស់ក្រុមត្រួតពិនិត្យនៃ គ.ជ.ប រួចចុះហត្ថលេខា ឈ្មោះ បោះត្រា គ.ជ.ប និងប្រគល់របាយការណ៍ និងតារាងត្រួតពិនិត្យលទ្ធផល ព្រមទាំងសំណុំឯកសារភ្ជាប់ជាមួយតាមរយៈអគ្គលេខាធិការ គ.ជ.ប ទៅក្រុមកំណត់បែងចែកអាសនៈដើម្បីមុខការ។

ង. សេចក្តីសម្រេចរបស់ គ.ជ.ប ជាសេចក្តីសម្រេចស្ថាពរបិទផ្លូវតវ៉ា។

## ៥. គំនូសបំព្រួញរយៈពេលនៃការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្ដឹងទាក់ទងនឹងភាពមិនប្រក្រតីនៅមួយថ្ងៃមុនថ្ងៃបោះឆ្នោត និងក្នុងថ្ងៃបោះឆ្នោត

គំនូសបំព្រួញទី ៥



## ផ្នែកទី ៦
## នីតិវិធីអនុវត្តសេចក្ដីសម្រេចស្ថាពរចំពោះការដាក់ទណ្ឌកម្មពិន័យជាប្រាក់

ការអនុវត្តសេចក្ដីសម្រេចស្ថាពរដាក់ទណ្ឌកម្មពិន័យជាប្រាក់ ទៅលើជនល្មើស ត្រូវអនុវត្តតាមនីតិវិធីដូចខាងក្រោម ៖

**ក.** នាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្មនៃអគ្គនាយកដ្ឋានសេវាកម្មច្បាប់ និងបច្ចេកទេស ជាអ្នកទទួលខុសត្រូវរៀបចំសំណុំឯកសារអនុវត្តសេចក្ដីសម្រេចស្ថាពរដាក់ជូន គ.ជ.ប ពិនិត្យ និងសម្រេចតាមរយៈអគ្គលេខាធិការ គ.ជ.ប ។

**ខ.** តាមរយៈការសម្រេចឱ្យអនុវត្តសេចក្ដីសម្រេចស្ថាពរ នាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្មត្រូវចាត់វិធានការជូនដំណឹងទៅជនដែលត្រូវពិន័យ ឱ្យចូលខ្លួនមកអនុវត្តសេចក្ដីសម្រេចដាក់ទណ្ឌកម្មពិន័យជាប្រាក់នោះដោយស្ម័គ្រចិត្ត ក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ បន្ទាប់ពីថ្ងៃទទួលបានសេចក្ដីបង្គាប់។

**គ.** បើដល់ពេលកំណត់ ជនដែលត្រូវពិន័យមិនព្រមបង់ប្រាក់ពិន័យតាមសេចក្ដីជូនដំណឹងទេនោះ នាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម ត្រូវរៀបចំរបាយការណ៍ និងលើកសំណើជូន គ.ជ.ប តាមរយៈអគ្គលេខាធិការ គ.ជ.ប ដើម្បីពិនិត្យ និងសម្រេច។

**ឃ.** ក្នុងករណីដែល គ.ជ.ប យល់ឃើញថាគ្មានស្ថានភាពណាមួយដែល គ.ជ.ប ត្រូវពន្យារពេល ឬបន្ធូរបន្ថយ ឬលើកលែងទណ្ឌកម្មពិន័យជាប្រាក់ ឬរំលត់ការដាក់ទណ្ឌកម្មទេនោះ គ.ជ.ប អាចស្នើសុំអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ ដើម្បីអនុវត្តសេចក្ដីសម្រេចរបស់ គ.ជ.ប ទារប្រាក់ពីជនដែលត្រូវពិន័យជូន គ.ជ.ប ។

**ង.** ប្រាក់ពិន័យដែលទទួលបាន ត្រូវដាក់ចូលជាថវិកាជាតិ។

# ជំពូកទី ៣
# សមត្ថកិច្ច និងនីតិវិធីប្រជុំផ្សះផ្សា ប្រជុំសម្រេច និងសវនាការ ដោះស្រាយពាក្យបណ្ដឹង
## ផ្នែកទី ១
## សមាសភាព និងសិទ្ធិអំណាចរបស់ក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះ

គឃ.សប គធ.ឧប និង គ.ជ.ប មានសិទ្ធិអំណាច និងភារកិច្ចសម្រេចលើពាក្យបណ្ដឹងដែលពាក់ព័ន្ធនឹងការបោះឆ្នោតជ្រើសរើស កបឃ.ស ។ គឃ.សប បើកការប្រជុំផ្សះផ្សា ឬបើកការប្រជុំសម្រេច គធ.ឧប បើកការប្រជុំផ្សះផ្សា ឬ/និង បើកសវនាការ និង គ.ជ.ប ពិនិត្យសម្រេច ឬបើកសវនាការលើពាក្យបណ្ដឹងតវ៉ា ឬពាក្យបណ្ដឹងជំទាស់ទាក់ទងនឹងការបោះឆ្នោតនេះ លើកលែងតែពាក្យបណ្ដឹងដែលទាក់ទងនឹងសមត្ថកិច្ចរបស់តុលាការ។

នីតិវិធីប្រជុំផ្សះផ្សា ឬប្រជុំសម្រេច ឬសវនាការដោះស្រាយពាក្យបណ្ដឹងដូចបានចែងក្នុងផ្នែកនេះ ត្រូវយកមកអនុវត្តក្នុងគ្រប់ដំណាក់កាលទាំងអស់នៃការបោះឆ្នោតជ្រើសរើស កបឃ.ស ដែលរួមមាន ដំណាក់កាលចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយសម្រាប់ឈរឈ្មោះបោះឆ្នោត បិទផ្សាយបញ្ជីបេក្ខជនដំបូង ឃោសនាបោះឆ្នោត ការបោះឆ្នោត និងរាប់សន្លឹកឆ្នោត និងលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោត។

ការរាប់ចំនួនថ្ងៃតវ៉ា ឬថ្ងៃជំទាស់ និងការសម្រេចលើពាក្យបណ្ដឹងតវ៉ា ឬពាក្យបណ្ដឹងជំទាស់ ពុំត្រូវបានរាប់បញ្ចូលថ្ងៃបុណ្យជាផ្លូវការ។ សេចក្ដីសម្រេចរបស់ គ.ជ.ប ជាសេចក្ដីសម្រេចស្ថាពរបិទផ្លូវតវ៉ា។

**១. សមាសភាពក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះ**

ការប្រជុំផ្សះផ្សា ឬការប្រជុំសម្រេច ឬសវនាការ ត្រូវធ្វើឡើងដោយក្រុមប្រឹក្សាដែលត្រូវបានចាត់តាំងឱ្យចូលរួមដោយ គឃ.សប ឬ គធ.ឧប ឬ គ.ជ.ប ។

**១.១ ក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាប្រជុំសម្រេចនៃ គឃ.សប**

សមាសភាពក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាប្រជុំសម្រេចដែលចាត់តាំងដោយ គឃ.សប ត្រូវអនុវត្តការប្រជុំផ្សះផ្សា ឬការប្រជុំសម្រេចរបស់ខ្លួន ស្របតាមនីតិវិធីដោះស្រាយពាក្យបណ្ដឹង ដូចមានចែងក្នុងប្រការ ១៩.១១ នៃ ប.ន.ឃ.ស ។

ប្រធាន និងសមាជិក គឃ.សប ដែលត្រូវបានចាត់តាំងឱ្យចូលរួមប្រជុំផ្សះផ្សា ហៅថា **ក្រុមប្រឹក្សាប្រជុំផ្សះផ្សា** ឬដែលត្រូវបានចាត់តាំងឱ្យចូលរួមប្រជុំសម្រេច ហៅថា **ក្រុមប្រឹក្សាប្រជុំសម្រេច**។ សមាសភាពរបស់ក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាប្រជុំសម្រេចនៃ គឃ.សប រួមមាន ៖

- ប្រធាន គយ.សប ឬតំណាង ជាប្រធានក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬប្រធានក្រុមប្រឹក្សាប្រជុំសម្រេច
- អនុប្រធាន និងសមាជិក គយ.សប ជាសមាជិក
- សមាជិក គយ.សប ១ (មួយ) រូប ទទួលភារកិច្ចបន្ថែមជាលេខាធិការ។

កូរ៉ុម និងលក្ខខណ្ឌសុពលភាពនៃសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាប្រជុំសម្រេចនៃ គយ.សប ត្រូវអនុវត្តតាមសំឡេងភាគច្រើនដាច់ខាត។

រាល់សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាប្រជុំសម្រេចនៃ គយ.សប មិនត្រូវមានសំឡេងអនុបវាទឡើយ។

**១.២ ក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាជំនុំជម្រះនៃ គធ.ខប**

សមាសភាពក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាជំនុំជម្រះដែលចាត់តាំងដោយ គធ.ខប ត្រូវអនុវត្តការប្រជុំផ្សះផ្សា ឬសវនាការ និងការសម្រេចរបស់ខ្លួនតាមបទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប ។

ប្រធាន អនុប្រធាន និងសមាជិក គធ.ខប ដែលត្រូវបានចាត់តាំងឱ្យចូលរួមប្រជុំផ្សះផ្សា ហៅថា **ក្រុមប្រឹក្សាប្រជុំផ្សះផ្សា** ឬដែលត្រូវបានចាត់តាំងឱ្យចូលរួមសវនាការ ហៅថា **ក្រុមប្រឹក្សាជំនុំជម្រះ**។ សមាសភាពរបស់ក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាជំនុំជម្រះនៃ គធ.ខប រួមមាន ៖

- ប្រធាន គធ.ខប ឬតំណាង ជាប្រធានក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬប្រធានក្រុមប្រឹក្សាជំនុំជម្រះ
- អនុប្រធាន និងសមាជិក គធ.ខប ជាសមាជិក
- មន្ត្រី គធ.ខប ដែលត្រូវបានចាត់តាំង ជាលេខាធិការ។

កូរ៉ុម និងលក្ខខណ្ឌសុពលភាពនៃសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាជំនុំជម្រះនៃ គធ.ខប ត្រូវអនុវត្តតាមសំឡេងភាគច្រើនដាច់ខាត។

រាល់សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាជំនុំជម្រះនៃ គធ.ខប មិនត្រូវមានសំឡេងអនុបវាទឡើយ។

**១.៣ ក្រុមប្រឹក្សាជំនុំជម្រះនៃ គ.ជ.ប**

សមាសភាពក្រុមប្រឹក្សាជំនុំជម្រះដែលចាត់តាំងដោយ គ.ជ.ប ត្រូវអនុវត្តតាមការសម្រេចរបស់ គ.ជ.ប អនុលោមតាម ច.គ.ជ.ប និងបទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប ។

ប្រធាន អនុប្រធាន និងសមាជិក គ.ជ.ប ដែលត្រូវបានចាត់តាំងឱ្យចូលរួមសវនាការដោះស្រាយពាក្យបណ្តឹង ហៅថា **ក្រុមប្រឹក្សាជំនុំជម្រះ** ។ សមាសភាពរបស់ក្រុមប្រឹក្សាជំនុំជម្រះនៃ គ.ជ.ប រួមមាន ៖

- ប្រធាន គ.ជ.ប ជាប្រធានក្រុមប្រឹក្សាជំនុំជម្រះ
- អនុប្រធាន និងសមាជិក គ.ជ.ប ជាសមាជិក
- មន្ត្រីអគ្គលេខាធិការដ្ឋាន គ.ជ.ប ដែលត្រូវបានចាត់តាំង ជាគណៈលេខាធិការសវនាការ ។

លក្ខខណ្ឌសុពលភាពនៃសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាជំនុំជម្រះនៃ គ.ជ.ប ត្រូវគោរពតាមបទប្បញ្ញត្តិនៃមាត្រា ៥០ នៃ ច.គ.ជ.ប និងបទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប ។

រាល់សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាជំនុំជម្រះនៃ គ.ជ.ប មិនត្រូវមានសំទ្បេងអនុបវាទឡើយ។

## ២. សិទ្ធិអំណាចរបស់ក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះ

### ២.១ ក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាប្រជុំសម្រេចនៃ គឃ.សប

ក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាប្រជុំសម្រេចនៃ គឃ.សប មានសិទ្ធិអំណាចកោះហៅគូភាគីទំនាស់ ឱ្យចូលខ្លួនមកបំភ្លឺក្នុងពេលប្រជុំផ្សះផ្សា ឬប្រជុំសម្រេចដោយជូនដំណឹងជាលាយលក្ខណ៍អក្សរយ៉ាងតិច ២៤ (ម្ភៃបួន) ម៉ោង មុនពេលបើកការប្រជុំផ្សះផ្សា ឬការប្រជុំសម្រេច ។ ចំពោះការប្រជុំសម្រេច អាចកោះហៅសាក្សីបាន។

ក្នុងពេលប្រជុំផ្សះផ្សា ឬប្រជុំសម្រេច ប្រធានក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬប្រធានក្រុមប្រឹក្សាប្រជុំសម្រេចអាចអនុញ្ញាតឱ្យជនណាម្នាក់ឆ្លើយបំភ្លឺ ឬហាមឆ្លើយបំភ្លឺចំពោះមុខអង្គប្រជុំផ្សះផ្សា ឬអង្គប្រជុំសម្រេច ហើយមានសិទ្ធិបណ្តេញឱ្យចេញពីបន្ទប់ប្រជុំផ្សះផ្សា ឬបន្ទប់ប្រជុំសម្រេច ចំពោះជនណា ឬជនទាំងឡាយណាដែលមិនគោរពបទបញ្ជាផ្ទៃក្នុងពេលបើកអង្គប្រជុំផ្សះផ្សា ឬអង្គប្រជុំសម្រេច ឬសវនាការដោះស្រាយបណ្តឹង ដូចមានចែងក្នុងឧបសម្ព័ន្ធទី៣។

### ២.២ ក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាជំនុំជម្រះនៃ គធ.ខប

ក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាជំនុំជម្រះនៃ គធ.ខប មានសិទ្ធិអំណាចកោះហៅគូភាគី ឱ្យចូលខ្លួនមកបំភ្លឺក្នុងពេលប្រជុំផ្សះផ្សា ឬសវនាការ ដោយជូនដំណឹងជាលាយលក្ខណ៍អក្សរយ៉ាងតិច ២៤ (ម្ភៃបួន) ម៉ោង មុនពេលបើកការប្រជុំផ្សះផ្សា ឬសវនាការ ។ ចំពោះសវនាការអាចកោះហៅសាក្សីបាន។

ក្នុងពេលប្រជុំផ្សះផ្សា ឬសវនាការ ប្រធានក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬប្រធានក្រុមប្រឹក្សាជំនុំជម្រះអាចអនុញ្ញាតឱ្យជនណាម្នាក់ឆ្លើយបំភ្លឺ ឬហាមឆ្លើយបំភ្លឺចំពោះមុខអង្គប្រជុំផ្សះផ្សា ឬអង្គសវនាការ ហើយមានសិទ្ធិបណ្ដេញឱ្យចេញពីបន្ទប់ប្រជុំផ្សះផ្សា ឬបន្ទប់សវនាការ ចំពោះជនណា ឬជនទាំងឡាយណាដែលមិនគោរពបទបញ្ជាផ្ទៃក្នុងពេលបើកអង្គប្រជុំផ្សះផ្សា ឬអង្គប្រជុំសម្រេច ឬសវនាការដោះស្រាយបណ្ដឹង ដូចមានចែងក្នុងឧបសម្ព័ន្ធទី៣។

### ២.៣ ក្រុមប្រឹក្សាជំនុំជម្រះនៃ គ.ជ.ប

គ.ជ.ប ឬក្រុមប្រឹក្សាជំនុំជម្រះនៃ គ.ជ.ប អាចបញ្ចូលរឿងក្ដី ក្នុងករណីដែលមានបណ្ដឹងច្រើន ប៉ុន្តែកម្មវត្ថុនៃពាក្យបណ្ដឹងតែមួយ អ្នកប្រព្រឹត្តល្មើសជារូបវន្តបុគ្គលតែម្នាក់ ឬនីតិបុគ្គលតែមួយ ហើយអ្នកប្ដឹងជារូបវន្តបុគ្គលតែម្នាក់ ឬនីតិបុគ្គលតែមួយ ទោះទីកន្លែងប្រព្រឹត្តល្មើសមាននៅទូទាំងប្រទេសក៏ដោយ។ ក្រោយពេលដែលក្រុមប្រឹក្សាជំនុំជម្រះចេញសេចក្ដីសម្រេចជាស្ថាពរ ប៉ុន្តែអ្នកប្រព្រឹត្តល្មើសមិនរាងចាល ដោយនៅតែប្រព្រឹត្តល្មើសដដែលបន្តទៀត ហើយបើមានបណ្ដឹងថ្មីទៀតនោះ គ.ជ.ប នឹងត្រូវលើកយកមកដោះស្រាយដោយចាត់ទុកជាករណីថ្មីទៀត។

ក្រុមប្រឹក្សាជំនុំជម្រះនៃ គ.ជ.ប មានសិទ្ធិអំណាចកោះហៅគូភាគី និងសាក្សីឱ្យចូលខ្លួនមកបំភ្លឺក្នុងសវនាការ ដោយត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរយ៉ាងតិច ២៤ (ម្ភៃបួន) ម៉ោង មុនពេលបើកសវនាការ។

គ.ជ.ប មានសិទ្ធិធ្វើការស៊ើបអង្កេតលើករណីមាន ឬគ្មានបណ្ដឹង ក្នុងគោលបំណងឱ្យមានការគោរព ច.ប.ឃ.ស និង ប.ន.ឃ.ស និងដើម្បីឱ្យការបោះឆ្នោតជ្រើសរើស កបឃ.ស បានប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌។

ក្នុងពេលសវនាការ ប្រធានក្រុមប្រឹក្សាជំនុំជម្រះអាចអនុញ្ញាតឱ្យជនណាម្នាក់ឆ្លើយបំភ្លឺ ឬហាមឆ្លើយបំភ្លឺចំពោះមុខអង្គសវនាការ ហើយមានសិទ្ធិបណ្ដេញឱ្យចេញពីបន្ទប់សវនាការ ចំពោះជនណា ឬជនទាំងឡាយណាដែលមិនគោរពបទបញ្ជាផ្ទៃក្នុងពេលបើកអង្គប្រជុំផ្សះផ្សា ឬអង្គប្រជុំសម្រេច ឬសវនាការដោះស្រាយពាក្យបណ្ដឹង ដូចមានចែងក្នុងឧបសម្ព័ន្ធទី៣។

## ផ្នែកទី ២
## សិទ្ធិ និងភារកិច្ចរបស់គូភាគី ដើមបណ្ដឹង ចុងចម្លើយ មេធាវី ឬតំណាង

### ១. សិទ្ធិ និងភារកិច្ចរបស់គូភាគី

ក្នុងករណីគូភាគីមានមេធាវី ឬតំណាងដើម្បីធ្វើជាតំណាង ឬសាក្សី ឬអ្នកដែលពាក់ព័ន្ធនឹងពាក្យបណ្ដឹងដែលត្រូវចូលរួមបំភ្លឺក្នុងអង្គប្រជុំសម្រេច ឬសវនាការនោះ ត្រូវសុំការអនុញ្ញាតជាមុនពីប្រធានក្រុមប្រឹក្សាប្រជុំសម្រេច ឬប្រធានក្រុមប្រឹក្សាជំនុំជម្រះមុនពេលបើកការប្រជុំសម្រេច ឬសវនាការ។ ចំពោះការប្រជុំផ្សះផ្សា គូភាគីអាចមកចូលរួមដោយផ្ទាល់ ឬចាត់តំណាងដែលត្រូវបានប្រគល់សិទ្ធិតែមិនតម្រូវឱ្យមានសាក្សីទេ។

គូភាគីត្រូវធ្វើលិខិតប្រគល់សិទ្ធិជូនមេធាវី ឬតំណាង ដោយមានចុះហត្ថលេខា ឬផ្ដិតមេដៃ និងត្រូវមានការយល់ព្រមចុះហត្ថលេខា និងបោះត្រាពីមេធាវី ឬស្នាមមេដៃនៃតំណាងនោះ (តំណាងត្រូវតែជានីតិជន[២])។

លិខិតប្រគល់សិទ្ធិត្រូវបញ្ជាក់ច្បាស់ពីសិទ្ធិរបស់មេធាវី ឬតំណាង ហើយត្រូវដាក់ជូនក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះតាមរយៈលេខាធិការអង្គប្រជុំផ្សះផ្សា ឬលេខាធិការអង្គប្រជុំសម្រេច ឬគណៈលេខាធិការសវនាការយ៉ាងតិច ២ (ពីរ) ម៉ោងមុនពេលបើកការប្រជុំផ្សះផ្សា ឬបើកការប្រជុំសម្រេច ឬបើកសវនាការ។

ដើមបណ្ដឹង និងចុងចម្លើយមិនតម្រូវឱ្យធ្វើសម្បថទេ។

មុនពេលក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះថយទៅពិភាក្សាពិចារណា គូភាគីអាចត្រូវបានអនុញ្ញាតឱ្យធ្វើសេចក្ដីសន្និដ្ឋានចុងក្រោយ ឬជូនឯកសារទាំងឡាយដែលខ្លួនយល់ថាមានប្រយោជន៍ដល់ខ្លួន ជូនទៅក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះដើម្បីពិចារណា។

គូភាគីមានសិទ្ធិប្ដឹងតវ៉ាចំពោះសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះតាមការកំណត់ក្នុង ច.ប.ឃ.ស និង ប.ន.ឃ.ស ។

---

[២] ជនដែលមានអាយុចាប់ពី ១៨ ឆ្នាំឡើងទៅ

## ២. សិទ្ធិ និងភារកិច្ចរបស់ដើមបណ្ដឹង

ដើមបណ្ដឹងអាចដកពាក្យបណ្ដឹងទាំងមូល ឬមួយផ្នែកបានរហូតដល់ពេលដែលក្រុមប្រឹក្សាប្រជុំផ្សះផ្សានៃ គឃ.សប ឬក្រុមប្រឹក្សាប្រជុំផ្សះផ្សានៃ គធ.ខប បញ្ចប់កំណត់ហេតុប្រជុំផ្សះផ្សា ឬរហូតដល់ពេលដែលក្រុមប្រឹក្សាប្រជុំសម្រេចនៃ គឃ.សប ឬក្រុមប្រឹក្សាប្រជុំសម្រេចនៃ គធ.ខប ឬក្រុមប្រឹក្សាជំនុំជម្រះនៃ គ.ជ.ប ថយទៅពិភាក្សាពិចារណា។

ការដកពាក្យបណ្ដឹងត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរជូនទៅ គឃ.សប ឬ គធ.ខប ឬ គ.ជ.ប លើកលែងតែនៅពេលកំពុងប្រជុំផ្សះផ្សា ឬកំពុងប្រជុំសម្រេច ឬកំពុងសវនាការ នោះការដកពាក្យបណ្ដឹងអាចធ្វើឡើងដោយផ្ទាល់មាត់បាន។

ប្រសិនបើដើមបណ្ដឹងដកពាក្យបណ្ដឹង ធ្វើឡើងមុនពេលដំណើរការប្រជុំផ្សះផ្សា ឬប្រជុំសម្រេច ឬសវនាការ គឃ.សប ឬ គធ.ខប ឬ គ.ជ.ប ត្រូវសម្រេចលើកពាក្យបណ្ដឹងនោះចោល ហើយត្រូវជូនដំណឹងទៅភាគីចុងចម្លើយ។

ប្រសិនបើដើមបណ្ដឹងដកពាក្យបណ្ដឹង ធ្វើឡើងនៅពេលកំពុងប្រជុំផ្សះផ្សា ក្រុមប្រឹក្សាប្រជុំផ្សះផ្សា ត្រូវកត់ត្រាក្នុងកំណត់ហេតុប្រជុំផ្សះផ្សាថា ភាគីដើមបណ្ដឹងដកពាក្យបណ្ដឹង ហើយពាក្យបណ្ដឹងនោះត្រូវបានលើកចោលតាមការស្នើសុំ។

ប្រសិនបើដើមបណ្ដឹងដកពាក្យបណ្ដឹង ធ្វើឡើងនៅពេលកំពុងប្រជុំសម្រេច ឬកំពុងសវនាការ ក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះត្រូវសម្រេចលើកពាក្យបណ្ដឹងចោលដោយចេញ ទ.១២០៣ ។

ដើមបណ្ដឹងអាចរាយការណ៍ជាលាយលក្ខណ៍អក្សរ អំពីបញ្ហាដែលកើតមានឡើងដោយខ្លួនឯង ឬតាមរយៈមេធាវី ឬតំណាងដែលបានទទួលសិទ្ធិ ហើយត្រូវបានអនុញ្ញាតឱ្យបង្ហាញឯកសារភស្តុតាង ឬសាក្សី ដើម្បីជាសំអាងក្នុងរឿងក្ដីរបស់ខ្លួន។

ដើមបណ្ដឹង និងជនរងគ្រោះមានវិសមិតភាពរវាងឋានៈជាដើមបណ្ដឹង ឬជនរងគ្រោះ និងឋានៈជាសាក្សី។ ដើមបណ្ដឹង ឬ/និងជនរងគ្រោះមិនអនុញ្ញាតឱ្យផ្ដល់ចម្លើយក្នុងឋានៈជាសាក្សីបានទេ។

### ៣. សិទ្ធិ និងភារកិច្ចរបស់ចុងចម្លើយ

ចុងចម្លើយអាចធ្វើរបាយការណ៍ជាលាយលក្ខណ៍អក្សរអំពីបញ្ហានានា ដែលទាក់ទងនឹងបណ្តឹងដោយខ្លួនឯង ឬតាមរយៈមេធាវី ឬតំណាងដែលបានទទួលសិទ្ធិផងដែរ ហើយត្រូវបង្ហាញឯកសារភស្តុតាង ឬសាក្សីដើម្បីជាសំអាងការពាររឿងក្តីរបស់ខ្លួន។

ចុងចម្លើយអាចបង្ហាញភស្តុតាងជាទឡ្ហីករណ៍ចុងក្រោយរបស់ខ្លួន ដោយខ្លួនឯង ឬតាមរយៈមេធាវី ឬតំណាងដើម្បីឆ្លើយតបទៅនឹងទឡ្ហីករណ៍របស់ដើមបណ្តឹង។

នៅក្នុងនីតិវិធីសវនាការតទល់ ដោយមានការយល់ព្រមពីប្រធានក្រុមប្រឹក្សាប្រជុំសម្រេច ឬប្រធានក្រុមប្រឹក្សាជំនុំជម្រះ ដើមបណ្តឹងអាចតាំងសំណួរទៅចុងចម្លើយ ឬសាក្សីរបស់ចុងចម្លើយ។ ចុងចម្លើយក៏អាចចោទសំណួរទៅដើមបណ្តឹង ឬសាក្សីរបស់ដើមបណ្តឹង។

### ៤. សិទ្ធិ និងភារកិច្ចរបស់មេធាវី ឬតំណាង

មេធាវី ឬតំណាងមិនអាចប្រគល់សិទ្ធិបន្តទៅមេធាវី ឬតំណាងដទៃទៀត ដោយគ្មានការយល់ព្រមជាលាយលក្ខណ៍អក្សរ ពីអ្នកប្រគល់សិទ្ធិដំបូងបានឡើយ។

ដើមបណ្តឹង ឬចុងចម្លើយ មេធាវី ឬតំណាងរបស់ភាគី អាចស្នើសុំឱ្យ គឃ.សប ឬ គធ.ខប ឬ គ.ជ.ប ថតចម្លងសំណុំរឿងពាក់ព័ន្ធឱ្យខ្លួន ដោយត្រូវបង់ប្រាក់ត្រឹមថ្លៃផលិតប៉ុណ្ណោះ។ ការថតចម្លងត្រូវធ្វើឡើងដោយសមាជិក គឃ.សប ឬមន្ត្រី គធ.ខប ឬមន្ត្រីនៅទីស្តីការ គ.ជ.ប ដែលបានចាត់តាំង។

### ៥. សិទ្ធិ និងភារកិច្ចរបស់សាក្សី

សាក្សីត្រូវធ្វើសម្បថជាមុន ហើយត្រូវឆ្លើយបំភ្លឺជូនក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះ នៅចំពោះមុខក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះ និងសន្យាទទួលខុសត្រូវចំពោះមុខច្បាប់ អំពីការផ្តន្ទាទោសចំពោះការផ្តល់សក្ខីកម្មភូតកុហក ប្រសិនបើខ្លួនឆ្លើយបំផ្លើសការពិត **(ខ្លឹមសារសម្បថដូចមានចែងក្នុងឧបសម្ព័ន្ធទី៤)**។

សាក្សីមានសិទ្ធិឆ្លើយបំភ្លឺនូវការពិតដែលខ្លួនបានឃើញ បានដឹង បានឮ និងបានចាំ ដោយគ្មានការបង្ខិតបង្ខំពីបុគ្គលណាមួយឡើយ។

សាក្សីដើមបណ្ដឹង និងសាក្សីចុងចម្លើយត្រូវស្ថិតក្នុងបន្ទប់ផ្សេងគ្នា រង់ចាំការអញ្ជើញឱ្យមកបំភ្លឺដោយក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះ។

សាក្សីដើមបណ្ដឹង និងសាក្សីចុងចម្លើយមិនត្រូវបានអនុញ្ញាតឱ្យទាក់ទងគ្នាទោះតាមមធ្យោបាយណាក៏ដោយ ក្នុងថ្ងៃដែលបានអញ្ជើញឱ្យចូលរួមប្រជុំសម្រេច ឬសវនាការ។

សាក្សីពុំត្រូវបានអនុញ្ញាតឱ្យឃើញ ឬស្ដាប់ការសួរដេញដោលនៅក្នុងបន្ទប់ប្រជុំសម្រេច ឬបន្ទប់ជំនុំជម្រះឡើយ លើកលែងតែមានការអនុញ្ញាតពីប្រធានក្រុមប្រឹក្សាប្រជុំសម្រេច ឬប្រធានក្រុមប្រឹក្សាជំនុំជម្រះ។

## ផ្នែកទី ៣
## នីតិវិធីប្រជុំផ្សះផ្សា ឬប្រជុំសម្រេច ឬសវនាការ

ដំណើរការប្រជុំផ្សះផ្សា ឬប្រជុំសម្រេច ឬសវនាការត្រូវដឹកនាំ និងចាត់ចែងដោយប្រធានក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬប្រធានក្រុមប្រឹក្សាប្រជុំសម្រេច ឬប្រធានក្រុមប្រឹក្សាជំនុំជម្រះ។ ប្រធានក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬប្រធានក្រុមប្រឹក្សាប្រជុំសម្រេច ឬប្រធានក្រុមប្រឹក្សាជំនុំជម្រះអាចអនុញ្ញាតឱ្យជនណាម្នាក់ឆ្លើយបំភ្លឺ ឬហាមឆ្លើយបំភ្លឺចំពោះមុខអង្គប្រជុំផ្សះផ្សា ឬអង្គប្រជុំសម្រេច ឬសវនាការ ហើយមានសិទ្ធិបណ្តេញឱ្យចេញពីបន្ទប់ប្រជុំផ្សះផ្សា ឬបន្ទប់ប្រជុំសម្រេច ឬបន្ទប់សវនាការចំពោះជនណា ឬជនទាំងឡាយណាដែលមិនគោរពបទបញ្ជាផ្ទៃក្នុងពេលបើកអង្គប្រជុំផ្សះផ្សា ឬអង្គប្រជុំសម្រេច ឬសវនាការដោះស្រាយពាក្យបណ្តឹង ដូចមានចែងក្នុងឧបសម្ព័ន្ធទី៣ (**ទំព័រ៦៩**)។

### ១. ប្រភេទសវនាការ

ក្រុមប្រឹក្សាជំនុំជម្រះអាចធ្វើសវនាការសង្ខេប ឬសវនាការតទល់ ឬសវនាការសួរដេញដោល។

**សវនាការសង្ខេប** ជាសវនាការដែលគ្មានទម្រង់ការច្រើន។ ក្រុមប្រឹក្សាជំនុំជម្រះគ្រាន់តែធ្វើសេចក្តីសម្រេចមួយឆ្លើយតប នៅពេលយល់ឃើញថាមានតែចំណោទខាងច្បាប់ប៉ុណ្ណោះ ហើយគ្មានចំណោទខាងអង្គហេតុ។

**សវនាការតទល់** ជាសវនាការដែលបើកឱ្យភាគីទំនាស់ជជែកតទល់គ្នាអំពីរឿងពាក្យបណ្តឹង។ ភាគីទំនាស់កំណត់អំពីអង្គហេតុ និងត្រូវប្រមូលភស្តុតាងដើម្បីដាក់ជូនសវនាការ។

**សវនាការសួរដេញដោល** ជាសវនាការដែលក្រុមប្រឹក្សាជំនុំជម្រះមានតួនាទីយ៉ាងសំខាន់ក្នុងការសួរដេញដោលរកហេតុផលក្នុងរឿងក្តី។ ក្នុងសវនាការប្រភេទនេះ ទាំងក្រុមប្រឹក្សាជំនុំជម្រះ ទាំងគូក្តីជាអ្នកទទួលខុសត្រូវក្នុងការប្រមែប្រមូលភស្តុតាងផ្សេងៗ ដែលត្រូវដាក់បង្ហាញក្នុងសវនាការ ប៉ុន្តែក្រុមប្រឹក្សាជំនុំជម្រះមានតួនាទីទទួលខុសត្រូវសំខាន់ជាអ្នកតាំងសំណួរដល់សាក្សី ចំណែកឯគូក្តីមានតួនាទីបន្ទាប់បន្សំតែប៉ុណ្ណោះ។ ការចោទសួរដេញដោលនេះអាចធ្វើទៅបានដោយមានការអនុញ្ញាតពីប្រធានក្រុមប្រឹក្សាជំនុំជម្រះ។

## ២. ភាសាដែលប្រើក្នុងការប្រជុំផ្សះផ្សា ឬប្រជុំសម្រេច ឬសវនាការ

ភាសាដែលប្រើក្នុងការប្រជុំផ្សះផ្សា ឬប្រជុំសម្រេច ឬសវនាការ គឺភាសាខ្មែរ។

ភាគីដែលមិនអាចយល់ភាសាខ្មែរ អាចរកអ្នកបកប្រែភាសាដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ដោយខ្លួនឯង។

## ៣. ពេលវេលាដោះស្រាយពាក្យបណ្តឹង

ការប្រជុំផ្សះផ្សា ឬការប្រជុំសម្រេច ឬសវនាការអាចធ្វើជារៀងរាល់ថ្ងៃ ចាប់ពីម៉ោង ៨:០០ នាទីព្រឹក ដល់ម៉ោង ១១:៣០ នាទីថ្ងៃត្រង់ និងរសៀលចាប់ពីម៉ោង ១៤:០០ នាទី ដល់ម៉ោង ១៧:៣០ នាទី។ ក្នុងករណីចាំបាច់ ការប្រជុំផ្សះផ្សា ឬការប្រជុំសម្រេច ឬសវនាការអាចបន្តធ្វើទៅតាមស្ថានភាពជាក់ស្តែង ឬធ្វើនៅម៉ោងផ្សេងក្រៅពីការកំណត់នេះ។

ក្នុងករណីដែលថ្ងៃកំណត់ដោះស្រាយពាក្យបណ្តឹង និងសម្រេចលើពាក្យបណ្តឹងចំថ្ងៃបុណ្យជាផ្លូវការ ការប្រជុំផ្សះផ្សា ឬការប្រជុំសម្រេច ឬសវនាការត្រូវលើកទៅថ្ងៃបន្ទាប់។

ការប្រជុំផ្សះផ្សា ឬប្រជុំសម្រេច ឬសវនាការលើពាក្យបណ្តឹងអាចកំណត់ធ្វើការប្រជុំផ្សះផ្សា ឬប្រជុំសម្រេច ឬជំនុំជម្រះច្រើនករណីនៃពាក្យបណ្តឹងបាន។

## ៤. ការជូនដំណឹងបើកអង្គប្រជុំផ្សះផ្សា ឬបើកអង្គប្រជុំសម្រេច ឬបើកសវនាការ

### ៤.១ ការជូនដំណឹងបើកអង្គប្រជុំផ្សះផ្សា ឬអង្គប្រជុំសម្រេចនៅ គឃ.សប

គឃ.សប ត្រូវពិភាក្សាក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដើម្បីកំណត់ប្រតិទិនសម្រាប់ប្រជុំផ្សះផ្សា ឬ/និងប្រជុំសម្រេចនៅថ្នាក់របស់ខ្លួនទៅតាមករណីនៃពាក្យបណ្តឹង និងទៅតាមរយៈពេលកំណត់ដូចមានចែងក្នុង ច.ប.ឃ.ស និង ប.ន.ឃ.ស និងត្រូវធានាប្រគល់លិខិតអញ្ជើញអំពីការប្រជុំផ្សះផ្សា ឬប្រជុំសម្រេចដល់គូភាគីបានទាន់ពេលវេលា យ៉ាងតិច ២៤ (ម្ភៃបួន) ម៉ោង មុនពេលប្រជុំផ្សះផ្សា ឬប្រជុំសម្រេច។

### ៤.២ ការជូនដំណឹងបើកអង្គប្រជុំផ្សះផ្សា ឬបើកសវនាការនៅ គធ.ខប

គធ.ខប ត្រូវកំណត់ប្រតិទិនសម្រាប់ដោះស្រាយពាក្យបណ្តឹង ឬ/និងបើកសវនាការនៅថ្នាក់ គធ.ខប ទៅតាមករណីនៃបណ្តឹង និងទៅតាមរយៈពេលកំណត់ដូចមានចែងក្នុង ច.ប.ឃ.ស និង ប.ន.ឃ.ស ។ លគធ.ខប ត្រូវធានាប្រគល់លិខិតអញ្ជើញអំពីការបើកការប្រជុំផ្សះផ្សា ឬបើកសវនាការដល់គូភាគីឱ្យបានទាន់ពេលវេលាយ៉ាងតិច ២៤ (ម្ភៃបួន) ម៉ោង មុនពេលបើកការប្រជុំផ្សះផ្សា ឬបើកសវនាការ ហើយត្រូវជូនដំណឹងភ្លាមនៅនឹងកន្លែងប្រជុំផ្សះផ្សា ទៅភាគីពាក់ព័ន្ធឱ្យបានដឹងពីកាលបរិច្ឆេទ ពេលវេលា និងទីកន្លែងបើកសវនាការ។

### ៤.៣ ការជូនដំណឹងបើកសវនាការនៅ គ.ជ.ប

គ.ជ.ប ត្រូវកំណត់ប្រតិទិនសម្រាប់ដោះស្រាយពាក្យបណ្តឹង ឬ/និងបើកសវនាការនៅថ្នាក់ គ.ជ.ប ទៅតាមករណីនៃបណ្តឹង និងទៅតាមរយៈពេលកំណត់ដូចមានចែងនៅក្នុង ច.ប.ឃ.ស និង ប.ន.ឃ.ស ។ នាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម ត្រូវធានាប្រគល់លិខិតអញ្ជើញអំពីការបើកសវនាការដល់គូភាគី ឱ្យបានទាន់ពេលវេលាយ៉ាងតិច ២៤ (ម្ភៃបួន) ម៉ោង មុនពេលបើកសវនាការ។

## ៥. ភារកិច្ចរបស់លេខាធិការអង្គប្រជុំផ្សះផ្សា ឬលេខាធិការអង្គប្រជុំសម្រេច ឬលេខាធិការសវនាការ ឬគណៈលេខាធិការសវនាការ

លេខាធិការអង្គប្រជុំផ្សះផ្សា ឬលេខាធិការអង្គប្រជុំសម្រេច ឬលេខាធិការសវនាការ ឬគណៈលេខាធិការសវនាការ មានភារកិច្ចដូចខាងក្រោម ៖

- បិទផ្សាយ និងអានបទបញ្ជាផ្ទៃក្នុងពេលបើកអង្គប្រជុំផ្សះផ្សា ឬអង្គប្រជុំសម្រេច ឬសវនាការឱ្យអ្នកចូលរួមបានជ្រាប
- នាំសាក្សីទៅធ្វើសម្បថ **(ករណីប្រជុំសម្រេច ឬសវនាការ)**
- ប្រាប់ទៅអ្នកចូលរួមទាំងអស់ឱ្យក្រោកឈរ នៅពេលដែលក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះអញ្ជើញមកដល់
- ពិនិត្យ និងស្រង់វត្តមាន អវត្តមានដើមបណ្តឹង ចុងចម្លើយ មេធាវី ឬតំណាង ដែលត្រូវចូលរួមប្រជុំផ្សះផ្សា ឬប្រជុំសម្រេច ឬសវនាការ លើកលែងតែការប្រជុំសម្រេច ឬសវនាការដែលត្រូវស្រង់វត្តមានសាក្សី
- រាយការណ៍អំពីវត្តមាន ឬអវត្តមានភាគីពាក់ព័ន្ធជូនក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះ
- ត្រូវធ្វើកំណត់ហេតុប្រជុំផ្សះផ្សា ឬកំណត់ហេតុប្រជុំសម្រេច ឬកំណត់ហេតុសវនាការ ក្នុងពេលប្រជុំផ្សះផ្សា ឬប្រជុំសម្រេច ឬសវនាការដោយដៃ ឬដោយវាយកុំព្យូទ័រ។ ការកត់ត្រាកំណត់ហេតុប្រជុំផ្សះផ្សា ឬកំណត់ហេតុប្រជុំសម្រេច ឬកំណត់ហេតុសវនាការ មិនត្រូវទុកឱ្យមានចន្លោះបន្ទាត់ទំនេរទេ ។ ពាក្យឆូតលុបចោល និងពាក្យសរសេរយោងត្រូវមានសេចក្តីបញ្ជាក់ និងមានហត្ថលេខាលេខាធិការអង្គប្រជុំផ្សះផ្សា ឬលេខាធិការអង្គប្រជុំសម្រេច ឬលេខាធិការសវនាការ ឬប្រធានគណៈលេខាធិការសវនាការ ប្រធាន និងសមាជិកក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាប្រជុំសម្រេច និងភាគីពាក់ព័ន្ធ

- អានឯកសារផ្សេងៗដែលពាក់ព័ន្ធ តាមការបង្គាប់ពីប្រធានក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬប្រធានក្រុមប្រឹក្សាប្រជុំសម្រេច ឬប្រធានក្រុមប្រឹក្សាជំនុំជម្រះ
- រៀបចំ ទ.១២០៣ រួចចុះហត្ថលេខា ហើយដាក់ជូនប្រធានក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះ ចុះហត្ថលេខា បោះត្រា និងចុះកាលបរិច្ឆេទ
- អញ្ជើញភាគីផ្ដិតមេដៃលើកំណត់ហេតុប្រជុំផ្សះផ្សា ឬកំណត់ហេតុប្រជុំសម្រេច ឬកំណត់ហេតុសវនាការ ក្នុងករណីដែលភាគីណាមួយមិនព្រមផ្ដិតមេដៃ លេខាធិការអង្គប្រជុំផ្សះផ្សា ឬលេខាធិការអង្គប្រជុំសម្រេច ឬលេខាធិការសវនាការ ឬប្រធានគណៈលេខាធិការសវនាការត្រូវចុះនិទ្ទេសអំពីការមិនព្រមផ្ដិតមេដៃលើកំណត់ហេតុនោះ។

## ៦. ការរៀបចំកន្លែង និងរបៀបរបបការងាររបស់ក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះ

នៅថ្ងៃប្រជុំផ្សះផ្សា ឬប្រជុំសម្រេច ឬសវនាការ ក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះ ត្រូវអញ្ជើញចូលអង្គុយតាមទីកន្លែងបានរៀបចំទុក។ ប្រធានអង្គុយនៅកណ្ដាល សមាជិកអង្គុយនៅអមសងខាង និងលេខាធិការអង្គប្រជុំផ្សះផ្សា ឬលេខាធិការអង្គប្រជុំសម្រេច ឬលេខាធិការសវនាការ ឬគណៈលេខាធិការសវនាការ ត្រូវអង្គុយនៅនឹងតុដែលនៅខាងឆ្វេងដៃ ឬស្ដាំដៃនៃក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះ។

ក្រោយពីបានអញ្ជើញអង្គុយតាមទីកន្លែងរួចមក ប្រធានក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬប្រធានក្រុមប្រឹក្សាប្រជុំសម្រេច ឬប្រធានក្រុមប្រឹក្សាជំនុំជម្រះត្រូវ ៖

ទី១. ប្រកាសសមាសភាពក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះ

ទី២. ប្រកាសសំណុំរឿង និងប្រកាសបើកការប្រជុំផ្សះផ្សា ឬការប្រជុំសម្រេច ឬសវនាការ

ទី៣. បង្គាប់លេខាធិការអង្គប្រជុំសម្រេច ឬលេខាធិការសវនាការ ឬគណៈលេខាធិការសវនាការឱ្យរាយការណ៍អំពីវត្តមានដើមបណ្ដឹង ចុងចម្លើយ និងសាក្សី (ករណីប្រជុំសម្រេច ឬសវនាការ)។

មុននឹងចាប់ផ្ដើមផ្សះផ្សា ឬសួរដេញដោល ប្រធានក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬប្រធានក្រុមប្រឹក្សាប្រជុំសម្រេច ឬប្រធានក្រុមប្រឹក្សាជំនុំជម្រះ ត្រូវសួរទៅដើមបណ្ដឹងថា **តើលោក ឬលោកស្រីនៅតែបន្តប្ដឹងដូចមានចែងក្នុងកម្មវត្ថុនៃបណ្ដឹង ឬមានការកែប្រែឬទេ?** ប្រសិនបើ ៖

- ដើមបណ្តឹងឆ្លើយថាខ្លួនដកពាក្យបណ្តឹង ប្រធានក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬប្រធានក្រុមប្រឹក្សាប្រជុំសម្រេច ឬប្រធានក្រុមប្រឹក្សាជំនុំជម្រះ ត្រូវបង្គាប់ឱ្យលេខាធិការអង្គប្រជុំផ្សះផ្សា ឬលេខាធិការអង្គប្រជុំសម្រេច ឬលេខាធិការសវនាការ ឬគណៈលេខាធិការសវនាការ ឱ្យកត់ត្រាក្នុងកំណត់ហេតុប្រជុំផ្សះផ្សា ឬកំណត់ហេតុប្រជុំសម្រេច ឬកំណត់ហេតុសវនាការ ហើយឱ្យដើមបណ្តឹងផ្តិតមេដៃលើកំណត់ហេតុនោះ។ បន្ទាប់មកក្រុមប្រឹក្សាប្រជុំផ្សះផ្សា អាចផ្សះផ្សារឿងក្តីផ្សេងទៀត (ប្រសិនបើមាន) ឬក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះអាចថយទៅពិភាក្សាពិចារណា ឬបន្តទៅប្រជុំសម្រេច ឬសវនាការរឿងក្តីផ្សេងទៀត (ប្រសិនបើមាន)។
- ដើមបណ្តឹងនៅតែបន្តប្តឹង ប្រធានក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬប្រធានក្រុមប្រឹក្សាប្រជុំសម្រេច ឬប្រធានក្រុមប្រឹក្សាជំនុំជម្រះ ត្រូវចាប់ផ្តើមដំណើរការប្រជុំផ្សះផ្សា ឬប្រជុំសម្រេច ឬសវនាការ។

ប្រធានក្រុមប្រឹក្សាប្រជុំសម្រេច ឬប្រធានក្រុមប្រឹក្សាជំនុំជម្រះ ត្រូវសួរដេញដោលទៅដើមបណ្តឹងមុន រួចត្រូវសួរទៅចុងចម្លើយ។ បន្ទាប់មកប្រធានត្រូវសួរសាក្សីដើមបណ្តឹង សាក្សីចុងចម្លើយ និងអ្នកពាក់ព័ន្ធ រួចឱ្យភាគីដើមបណ្តឹង និងភាគីចុងចម្លើយធ្វើសំណូមពរចុងក្រោយ។

ប្រសិនបើមានមេធាវីការពារក្តី ប្រធានក្រុមប្រឹក្សាប្រជុំសម្រេច ឬប្រធានក្រុមប្រឹក្សាជំនុំជម្រះ ត្រូវផ្តល់ពេលវេលាឱ្យមេធាវីនិយាយការពារកូនក្តី សួរភាគី និងធ្វើសេចក្តីសន្និដ្ឋានចុងក្រោយ មុនក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះថយទៅពិភាក្សាពិចារណា។

ក្នុងពេលដំណើរការប្រជុំផ្សះផ្សា ឬប្រជុំសម្រេច ឬសវនាការ ប្រសិនបើដើមបណ្តឹងសុំដកពាក្យបណ្តឹង ប្រធានក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬប្រធានក្រុមប្រឹក្សាប្រជុំសម្រេច ឬប្រធានក្រុមប្រឹក្សាជំនុំជម្រះត្រូវបញ្ចប់ការផ្សះផ្សា ឬសួរដេញដោលនោះភ្លាម រួចត្រូវអនុវត្តដូចគ្នានឹងករណីដើមបណ្តឹងដកពាក្យបណ្តឹងពេលដែលក្រុមប្រឹក្សាប្រជុំផ្សះផ្សា ក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះសួរពេលដំបូងដែរ។

ក្រោយពីបានដំណើរការប្រជុំសម្រេច ឬសវនាការតាមលំដាប់លំដោយរួចហើយ ក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះត្រូវថយទៅពិភាក្សាពិចារណានៅបន្ទប់សម្ងាត់។ រាល់ការសម្រេចរបស់ក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះ ត្រូវផ្អែកលើអង្គហេតុ និងអង្គច្បាប់។

ក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះត្រូវប្រកាសសេចក្តីសម្រេចភ្លាមបន្ទាប់ពីពិភាក្សាគ្នារួចរាល់។ បញ្ញត្តិនេះ មិនត្រូវយកមកអនុវត្តឡើយចំពោះរឿងពាក្យបណ្តឹងដែលមានភាពស្មុគស្មាញខ្លាំង ឬមានកាលៈទេសៈពិសេសផ្សេងទៀត ប៉ុន្តែមិនត្រូវឱ្យហួសរយៈពេលកំណត់នៃការដោះស្រាយបណ្តឹងឡើយ។ ការប្រកាសសេចក្តីសម្រេច ត្រូវធ្វើឡើងដោយប្រធានក្រុមប្រឹក្សាប្រជុំសម្រេច ឬប្រធានក្រុមប្រឹក្សាជំនុំជម្រះជាអ្នកអានសេចក្តីសម្រេច ដោយផ្អែកលើច្បាប់ដើមនៃសេចក្តីសម្រេច។ ប្រធានក្រុមប្រឹក្សាប្រជុំសម្រេច ឬប្រធានក្រុមប្រឹក្សាជំនុំជម្រះ អាចចាត់តាំងសមាជិកក្រុមប្រឹក្សាប្រជុំសម្រេច ឬសមាជិកក្រុមប្រឹក្សាជំនុំជម្រះណាម្នាក់អានជំនួសបាន។

**៧. ការបង្ហាញខ្លួននៅពេលប្រជុំផ្សះផ្សា ឬប្រជុំសម្រេច ឬសវនាការ**

ប្រសិនភាគីដើមបណ្តឹងបានទទួលលិខិតអញ្ជើញហើយ ប៉ុន្តែភាគីនោះមិនបានមកបង្ហាញខ្លួននៅថ្ងៃប្រជុំផ្សះផ្សាទេនោះ ក្រុមប្រឹក្សាប្រជុំផ្សះផ្សាត្រូវសម្រេចលើកពាក្យបណ្តឹងចោលដោយធ្វើលិខិតជូនដំណឹងទៅភាគីដើមបណ្តឹង។

ប្រសិនបើភាគីដើមបណ្តឹងបានទទួលលិខិតអញ្ជើញហើយ ប៉ុន្តែភាគីនោះមិនបានមកបង្ហាញខ្លួននៅថ្ងៃប្រជុំសម្រេច ឬថ្ងៃសវនាការទេនោះ ក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះត្រូវសម្រេចកំបាំងមុខដើមបណ្តឹង ប៉ុន្តែចាត់ទុកជាចំពោះមុខដោយបញ្ជាក់ពីមូលហេតុលើសេចក្តីសម្រេច។

ប្រសិនបើភាគីដើមបណ្តឹងស្លាប់ នោះក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះនៅតែបន្តនីតិវិធីរបស់ខ្លួនដដែល។

ប្រសិនបើភាគីចុងចម្លើយស្លាប់មុនពេលបើកប្រជុំផ្សះផ្សា ឬប្រជុំសម្រេច ឬសវនាការ ក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះត្រូវលុបពាក្យបណ្តឹងចេញពីបញ្ជី ហើយត្រូវជូនដំណឹងទៅភាគីដើមបណ្តឹងឱ្យបានជ្រាប។

ប្រសិនបើចុងចម្លើយបានទទួលលិខិតអញ្ជើញហើយ ប៉ុន្តែមិនមកបង្ហាញខ្លួននៅថ្ងៃប្រជុំផ្សះផ្សា ឬថ្ងៃប្រជុំសម្រេច ឬថ្ងៃសវនាការ ក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះនៅតែបន្តនីតិវិធីរបស់ខ្លួនដដែល។

ប្រសិនបើដើមបណ្តឹង ឬចុងចម្លើយមិនបានបង្ហាញខ្លួននាថ្ងៃប្រជុំសម្រេច ឬថ្ងៃសវនាការ ក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះ ត្រូវចាត់លេខាធិការអង្គប្រជុំសម្រេច ឬលេខាធិការសវនាការ ឬគណៈលេខាធិការសវនាការ ព្រមទាំងស្នើសុំកិច្ចសហការពីអាជ្ញាធរឃុំ សង្កាត់អមដំណើរជាមួយ ដើម្បីបញ្ជូន ទ.១២០៣ ទៅជូនដើមបណ្តឹង ឬចុងចម្លើយនៅអាសយដ្ឋានរបស់ដើមបណ្តឹង ឬចុងចម្លើយ ឬទីស្នាក់ការគណបក្សនយោបាយរបស់ដើមបណ្តឹង ឬចុងចម្លើយនោះ។ ប្រសិនបើដើមបណ្តឹង ឬចុងចម្លើយបដិសេធមិនទទួលយក ទ.១២០៣ នោះ លេខាធិការអង្គប្រជុំសម្រេច ឬលេខាធិការសវនាការ ឬមន្ត្រី គ.ជ.ប ត្រូវចារលើ ទ.១២០៣ នោះដោយបញ្ជាក់ឱ្យបានច្បាស់ថា "**អ្នកប្តឹង ឬតំណាង ឬអ្នកត្រូវគេប្តឹង ឬតំណាងមិនព្រមទទួល ទ.១២០៣**" ហើយចុះកាលបរិច្ឆេទ និងហត្ថលេខា និងមានហត្ថលេខារបស់អាជ្ញាធរឃុំ សង្កាត់ដែលអមដំណើរទៅជាមួយ ដើម្បីបញ្ជាក់ថាភាគីនៃពាក្យបណ្តឹងពិតជាមិនព្រមទទួល ទ.១២០៣ រួចបិទ ទ.១២០៣ នោះ នៅមុខលំនៅឋាន ឬទីសំណាក់ ឬទីស្នាក់ការគណបក្សនយោបាយរបស់ភាគីនៃពាក្យបណ្តឹង ហើយចាត់ទុកថាភាគីនៃពាក្យបណ្តឹងបានទទួល ទ.១២០៣ រួចហើយ។

### ៨. មធ្យោបាយបង្ហាញភស្តុតាង

មធ្យោបាយបង្ហាញភស្តុតាង ដែលប្រើប្រាស់ក្នុងតុលាការជម្រះក្តីក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវយកមកប្រើប្រាស់ក្នុងអង្គប្រជុំផ្សះផ្សា ឬអង្គប្រជុំសម្រេច ឬសវនាការនេះ។

ភស្តុតាងអាចបង្ហាញបានតាមគ្រប់មធ្យោបាយ និងត្រូវគោរពតាម ច.ប.ឃ.ស និង ប.ន.ឃ.ស នេះ។

ជនណាបានប្រព្រឹត្តអំពើក្លែងលិខិត ឬឯកសារ ដោយក្លែងហត្ថលេខា ឬស្នាមមេដៃ ឬតាមមធ្យោបាយណាក៏ដោយ និងជនណាដែលបានប្រើប្រាស់ដោយដឹងខ្លួននូវលិខិត ឬឯកសារនោះ ជននោះនឹងត្រូវមានទោសតាមច្បាប់ជាធរមាន។

### ៩. ការបំពេញ និងការប្រើប្រាស់ ទ.១២០៣

ទ.១២០៣ របស់ក្រុមប្រឹក្សាប្រជុំសម្រេចនៃ គឃ.សប ត្រូវធ្វើឡើងផ្អែកតាមកំណត់ហេតុប្រជុំសម្រេច ហើយចុះហត្ថលេខាដោយលេខាធិការអង្គប្រជុំសម្រេច និងប្រធានក្រុមប្រឹក្សាប្រជុំសម្រេច។ ការបំពេញ ទ.១២០៣ នៅ គឃ.សប ត្រូវធ្វើជា ៣ (បី) ច្បាប់ សម្រាប់ពាក្យបណ្តឹងតវ៉ា ឬ ៤ (បួន) ច្បាប់ សម្រាប់ពាក្យបណ្តឹងជំទាស់ដើម្បី ៖

- ជូន ឬផ្ញើជូនសាមីជនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ជាបន្ទាន់
- ជូន ឬផ្ញើជូនអ្នកដែលត្រូវគេប្តឹងជំទាស់ ឬតំណាង ១ (មួយ) ច្បាប់ (ចំពោះបណ្តឹងជំទាស់) ជាបន្ទាន់
- ផ្ញើជូន គធ.ខប ពាក់ព័ន្ធ ១ (មួយ) ច្បាប់
- រក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាជំនុំជម្រះនៃ គធ.ខប និងក្រុមប្រឹក្សាជំនុំជម្រះនៃ គ.ជ.ប ត្រូវធ្វើឡើងផ្អែកតាមកំណត់ហេតុសវនាការ ហើយត្រូវចុះហត្ថលេខាដោយប្រធានក្រុមប្រឹក្សាជំនុំជម្រះ។ សេចក្តីសម្រេចនេះ ត្រូវស្រង់ដាក់ក្នុង ទ.១២០៣ ហើយត្រូវចុះហត្ថលេខាដោយលេខាធិការសវនាការ ឬគណៈលេខាធិការសវនាការ និងប្រធានក្រុមប្រឹក្សាជំនុំជម្រះ ហើយត្រូវធ្វើឡើងតាមចំនួន និងកម្មវត្ថុនៃពាក្យបណ្តឹង ឬចំនួនផ្សេងតាមការចាំបាច់។

ការបំពេញ ទ.១២០៣ នៅ គធ.ខប ត្រូវធ្វើជា ៤ (បួន) ច្បាប់ សម្រាប់ពាក្យបណ្តឹងតវ៉ា ឬ ៥ (ប្រាំ) ច្បាប់ សម្រាប់ពាក្យបណ្តឹងជំទាស់ដើម្បី ៖

- ជូន ឬផ្ញើជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ជាបន្ទាន់
- ជូន ឬផ្ញើជូនអ្នកដែលត្រូវគេប្តឹងជំទាស់ ឬតំណាង ១ (មួយ) ច្បាប់ (ចំពោះពាក្យបណ្តឹងជំទាស់) ជាបន្ទាន់
- ផ្ញើជូន គឃ.សប ពាក់ព័ន្ធ ១ (មួយ) ច្បាប់
- ផ្ញើជូន គ.ជ.ប ១ (មួយ) ច្បាប់
- រក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

ការបំពេញ ទ.១២០៣ នៅ គ.ជ.ប ត្រូវធ្វើជា ៤ (បួន) ច្បាប់ សម្រាប់ពាក្យបណ្តឹងតវ៉ា ឬ ៥ (ប្រាំ) ច្បាប់ សម្រាប់ពាក្យបណ្តឹងជំទាស់ដើម្បី ៖

- ជូន ឬផ្ញើជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ជាបន្ទាន់
- ជូន ឬផ្ញើជូនអ្នកដែលត្រូវគេប្តឹងជំទាស់ ឬតំណាង ១ (មួយ) ច្បាប់ (ចំពោះពាក្យបណ្តឹងជំទាស់) ជាបន្ទាន់
- ផ្ញើជូន គឃ.សប ពាក់ព័ន្ធ ១ (មួយ) ច្បាប់
- ផ្ញើជូន គធ.ខប ពាក់ព័ន្ធ ១ (មួយ) ច្បាប់
- រក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

**១០. ទម្រង់បែបបទផ្សេងៗទៀតសម្រាប់ការប្រជុំផ្សះផ្សា ការប្រជុំសម្រេច និងសវនាការ**

គយ.សប គធ.ខប និង គ.ជ.ប មានទម្រង់បែបបទផ្សេងៗទៀតសម្រាប់ប្រើប្រាស់ក្នុងការប្រជុំផ្សះផ្សា ឬការប្រជុំសម្រេច ឬសវនាការ មានជាអាទិ៍ លិខិតអញ្ជើញឱ្យចូលរួមប្រជុំផ្សះផ្សា ឬប្រជុំសម្រេច ឬសវនាការ កំណត់ហេតុសាកសួរ និងកំណត់ហេតុប្រជុំផ្សះផ្សា ឬកំណត់ហេតុប្រជុំសម្រេច ឬកំណត់ហេតុសវនាការ និងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាជំនុំជម្រះនៃ គធ.ខប និងក្រុមប្រឹក្សាជំនុំជម្រះនៃ គ.ជ.ប ។

លិខិតអញ្ជើញឱ្យចូលរួមប្រជុំផ្សះផ្សា ឬប្រជុំសម្រេច ឬសវនាការ ត្រូវបំពេញតាមចំនួនជាក់ស្តែងនៃអ្នកពាក់ព័ន្ធ ដែលត្រូវអញ្ជើញឱ្យចូលរួមប្រជុំផ្សះផ្សា ឬប្រជុំសម្រេច ឬសវនាការ រួចប្រគល់ជូនភាគីពាក់ព័ន្ធ ១ (មួយ) ច្បាប់ៗ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

កំណត់ហេតុសាកសួរអាចធ្វើឡើងដោយដៃ ឬដោយវាយកុំព្យូទ័រ។

កំណត់ហេតុប្រជុំផ្សះផ្សា ត្រូវបំពេញដោយលេខាធិការអង្គប្រជុំផ្សះផ្សាចំនួន ១ (មួយ) ច្បាប់ ដោយត្រូវកត់ត្រានូវរាល់ចម្លើយដាក់បន្ទុក ឬចម្លើយដោះសាររបស់ភាគីពាក់ព័ន្ធនឹងពាក្យបណ្តឹង និងលទ្ធផលនៃការផ្សះផ្សា។

កំណត់ហេតុប្រជុំសម្រេច ឬកំណត់ហេតុសវនាការ ត្រូវបំពេញដោយលេខាធិការអង្គប្រជុំសម្រេច ឬលេខាធិការសវនាការ ឬគណៈលេខាធិការសវនាការចំនួន ១ (មួយ) ច្បាប់ ដោយត្រូវកត់ត្រានូវរាល់ចម្លើយដាក់បន្ទុក ឬចម្លើយដោះសាររបស់ភាគីពាក់ព័ន្ធនឹងបណ្តឹង ព្រមទាំងការយល់ឃើញ និងការសម្រេចរបស់ក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះ។

សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាជំនុំជម្រះនៃ គធ.ខប និងក្រុមប្រឹក្សាជំនុំជម្រះនៃ គ.ជ.ប ត្រូវសរសេរនូវចំណុច (១) រដ្ឋធម្មនុញ្ញ ច្បាប់ និងបទបញ្ជា និងនីតិវិធីពាក់ព័ន្ធនឹងការបោះឆ្នោត ពាក្យបណ្តឹង លិខិតប្រគល់សិទ្ធិ ឬ/និងកំណត់ហេតុ ឬ/និងរបាយការណ៍ផ្សេងៗ (២) ការយល់ឃើញ និងការសម្រេចរបស់ក្រុមប្រឹក្សាជំនុំជម្រះ។ ច្បាប់ចតចម្លងនៃសេចក្តីសម្រេចនេះអាចផ្តល់ជូនគូភាគីបានប្រសិនបើមានការស្នើសុំ ។

# ឧបសម្ព័ន្ធទី ១
# ពាក្យសុំចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយ និង សេចក្តីសម្រេចរបស់ គឃ.សប (ទ.១០០៨)

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**ពាក្យសុំចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយ និងសេចក្តីសម្រេចរបស់ គឃ.សប (ទ.១០០៨)**

**ផ្នែកទី១ : ពាក្យសុំចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយ**

<table>
<tr><td colspan="8">ឈ្មោះគណបក្សនយោបាយ:</td></tr>
<tr><td colspan="8">ឈ្មោះគណបក្សនយោបាយ: (ជាអក្សរកាត់)</td></tr>
<tr><td colspan="8">អាសយដ្ឋានទីស្នាក់ការកណ្តាលគណបក្សនយោបាយ:</td></tr>
<tr><td colspan="8"></td></tr>
<tr><td colspan="8">អាសយដ្ឋានទីស្នាក់ការគណបក្សនយោបាយក្នុងឃុំ សង្កាត់:</td></tr>
<tr><td colspan="8"></td></tr>
<tr><td colspan="5">តំណាងដោយលោក-លោកស្រី:</td><td colspan="3">អាយុ: ឆ្នាំ</td></tr>
<tr><td colspan="5">សូមស្នើសុំចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយដែលមានបេក្ខជនសរុបចំនួន:</td><td colspan="3">នាក់</td></tr>
<tr><td colspan="8">សម្រាប់ឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សានៅឃុំ សង្កាត់:</td></tr>
<tr><td>លេខកូដឃុំ សង្កាត់</td><td></td><td></td><td></td><td>រាជធានី ខេត្ត:</td><td>លេខកូដ:</td><td></td><td></td></tr>
</table>

សូមភ្ជាប់មកជាមួយនូវ ៖

១- សេចក្តីចម្លងលិខិតបញ្ជាក់ការចុះបញ្ជីគណបក្សនយោបាយនៅក្រសួងមហាផ្ទៃចំនួន ១ (មួយ) ច្បាប់។

២- បញ្ជីរាយនាមបេក្ខជនឈរឈ្មោះបោះឆ្នោត ដែលមានចំនួនបេក្ខជនយ៉ាងហោចណាស់ស្មើនឹង ២ (ពីរ) ដងនៃចំនួនសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ចំនួន ៧ (ប្រាំពីរ) ច្បាប់។

៣- លិខិតបញ្ជាក់ពីមេឃុំ ចៅសង្កាត់ថា បេក្ខជនពិតជាបានចុះឈ្មោះ និងមានឈ្មោះក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោតក្នុងឃុំ សង្កាត់ ដែលខ្លួនមានបំណងឈរឈ្មោះបោះឆ្នោត ចំនួន ១ (មួយ) ច្បាប់។

៤- ជីវប្រវត្តិសង្ខេប និងសេចក្តីប្រកាសយល់ព្រមឈរឈ្មោះរបស់បេក្ខជនដែលបំពេញផ្ទាល់ដៃរបស់បេក្ខជនម្នាក់ៗ មានបិទរូបថត និងរូបថតបេក្ខជនម្នាក់ៗចំនួន ៣ (បី) សន្លឹក ទំហំ ៤x៦ ថតចំពីមុខ។

៥- ឈ្មោះគណបក្សនយោបាយជាអក្សរពេញ ជាអក្សរកាត់ និងសញ្ញាសម្គាល់គណបក្សនយោបាយ។

៦- លិខិតសន្យារបស់បេក្ខជនឈរឈ្មោះបោះឆ្នោត ដែលជាមន្ត្រីរាជការស៊ីវិល មន្ត្រីតុលាការ កងយោធពលខេមរភូមិន្ទ នគរបាលជាតិ ថានឹងផ្តល់ច្បាប់សុំឈប់ពិសេសជូន គឃ.សប។

សូមប្រកាសជាឱឡារិកថា នឹងគោរពច្បាប់ស្តីពីការបោះឆ្នោត ច្បាប់ស្តីពីគណបក្សនយោបាយ បទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប និងក្រមសីលធម៌សម្រាប់គណបក្សនយោបាយ បេក្ខជន និងភ្នាក់ងារគណបក្សនយោបាយក្នុងដំណើរការបោះឆ្នោត។

សូម គឃ.សប មេត្តាអនុញ្ញាតតាមនីតិវិធី ដោយអនុគ្រោះ។

ថ្ងៃ..............................ខែ...............ឆ្នាំ......................ព.ស..................

..............................ថ្ងៃទី.............ខែ.............ឆ្នាំ.............

**ប្រធានគណបក្ស ឬតំណាង**
**ហត្ថលេខា និងត្រា**

**ផ្នែកទី២ : សេចក្តីសម្រេចរបស់ គឃ.សប**

បន្ទាប់ពីបានពិនិត្យ គឃ.សប សម្រេច ៖

<table>
<tr><td colspan="2">ឃុំ សង្កាត់:</td><td></td><td></td><td></td></tr>
<tr><td colspan="3">រាជធានី ខេត្ត:</td><td></td><td></td></tr>
</table>

យល់ព្រមលើការសុំចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយ:..........................................ដែលបានបំពេញត្រឹមត្រូវតាមលក្ខខណ្ឌ និងដែលមានបេក្ខជនសរុបចំនួន: [ ][ ] នាក់ដូចមានក្នុងបញ្ជីរាយនាមភ្ជាប់មកជាមួយ។

ថ្ងៃ..............................ខែ...............ឆ្នាំ......................ព.ស..................

..............................ថ្ងៃទី.............ខែ.............ឆ្នាំ.............

**ជ.គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត**
**ហត្ថលេខា និងត្រា**

ចំណាំ ៖ ពាក្យសុំចុះបញ្ជីបេក្ខជននៃគណបក្សនេះត្រូវធ្វើជា ២ (ពីរ) ច្បាប់

ទម្រង់បែបបទលេខ ១០០៨ បំពេញដោយគណបក្សនយោបាយ និង គឃ.សប

## បញ្ជីរាយនាមបេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់

**គណបក្សនយោបាយ :** ..........................................................................................................................

| | | | |
|---|---|---|---|
| ឃុំ សង្កាត់: | | | |
| រាជធានី ខេត្ត: | | | |

| ល.រ. | នាមត្រកូល | នាមខ្លួន | ភេទ | ថ្ងៃខែឆ្នាំកំណើត | អាសយដ្ឋាន | ផ្សេងៗ |
|---|---|---|---|---|---|---|
| ១ | | | | | | |
| ២ | | | | | | |
| ៣ | | | | | | |
| ៤ | | | | | | |
| ៥ | | | | | | |
| ៦ | | | | | | |
| ៧ | | | | | | |
| ៨ | | | | | | |
| ៩ | | | | | | |
| ១០ | | | | | | |
| ១១ | | | | | | |
| ១២ | | | | | | |
| ១៣ | | | | | | |
| ១៤ | | | | | | |
| ១៥ | | | | | | |
| ១៦ | | | | | | |
| ១៧ | | | | | | |
| ១៨ | | | | | | |
| ១៩ | | | | | | |
| ២០ | | | | | | |
| ២១ | | | | | | |
| ២២ | | | | | | |

សរុបចំនួន:.............នាក់ ស្ត្រីចំនួន:..........នាក់

ថ្ងៃ.......................ខែ............ឆ្នាំ.....................ព.ស............

.......................ថ្ងៃទី..........ខែ...........ឆ្នាំ..............

**ប្រធានគណបក្ស ឬតំណាង**

**ហត្ថលេខា និងត្រា**

ថ្ងៃ.......................ខែ............ឆ្នាំ.....................ព.ស............

.......................ថ្ងៃទី..........ខែ...........ឆ្នាំ..............

**ជ.គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត**

**ហត្ថលេខា និងត្រា**

ចំណាំ ៖ - ក្នុងករណីទទួលបញ្ជីរាយនាមនេះមិនគ្រប់គ្រាន់គណបក្សត្រូវសរសេរដោយដៃ ឬថតចម្លងបន្ថែម
- បញ្ជីរាយនាមនេះត្រូវធ្វើជា ៧ (ប្រាំពីរ) ច្បាប់
- ចំនួនបេក្ខជនឈរឈ្មោះលើសពី ២២ (ម្ភៃពីរ) រូប ត្រូវសរសេរបញ្ជីបន្ថែម
- គឃ.សប ត្រូវបញ្ចូលទិន្នន័យបេក្ខជននៃគណបក្សនយោបាយផ្អែកតាមបញ្ជីរាយនាមបេក្ខជននេះ ដោយត្រូវទាញទិន្នន័យពីបញ្ជីបោះឆ្នោតផ្លូវការក្នុងប្រព័ន្ធគ្រប់គ្រងការចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយ ដើម្បីពិនិត្យ និងផ្ទៀងផ្ទាត់លក្ខខណ្ឌរបស់បេក្ខជន។

ឯកសារសម្រាប់ភ្ជាប់ជាមួយទម្រង់បែបបទលេខ ១០០៨ ពាក្យសុំចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយ និងសេចក្តីសម្រេចរបស់ គឃ.សប

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជធានី ខេត្ត**...............................

**ក្រុង ស្រុក ខណ្ឌ**..........................

**ឃុំ សង្កាត់**....................................

## លិខិតបញ្ជាក់

ក្រុមប្រឹក្សាឃុំ សង្កាត់.......................................................................................

## សូមបញ្ជាក់ថា

លោក-លោកស្រីឈ្មោះ................................................................................ ភេទ.....................
ថ្ងៃខែឆ្នាំកំណើត................................................ សញ្ជាតិ.............. ។
អាសយដ្ឋានបច្ចុប្បន្ន.........................................................................................................
..............................................................................................................................................

ពិតជាបានចុះឈ្មោះ និងមានឈ្មោះក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោតក្នុងឃុំ សង្កាត់ខាងលើប្រាកដមែនះ

- ការិយាល័យបោះឆ្នោតលេខ..........................................................
- លេខកូដ ឃុំ សង្កាត់.......................................................................
- លេខកូដ រាជធានី ខេត្ត....................................................................
- លេខរៀងក្នុងបញ្ជីបោះឆ្នោត..............................................................

លិខិតបញ្ជាក់នេះ ចេញឱ្យសាមីខ្លួនសម្រាប់ប្រើប្រាស់បំពេញលក្ខខណ្ឌ ដើម្បីចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ឆ្នាំ............។

ថ្ងៃ...............................ខែ............ឆ្នាំ.....................ព.ស............
.............................ថ្ងៃទី................ខែ................ឆ្នាំ...............
**ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ និងជាមេឃុំ ចៅសង្កាត់**
**ហត្ថលេខា និងត្រា**

ឯកសារសម្រាប់ភ្ជាប់ជាមួយទម្រង់បែបបទលេខ ១០០៨ ពាក្យសុំចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយ និងសេចក្ដីសម្រេចរបស់ គឃ.សប

## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជធានី ខេត្ត**...............................

**ក្រុង ស្រុក ខណ្ឌ**..........................

**ឃុំ សង្កាត់**....................................

## លិខិតបញ្ជាក់

ក្រុមប្រឹក្សាឃុំ សង្កាត់........................................................................................

## សូមបញ្ជាក់ថា

លោក-លោកស្រីដូចមានរាយនាមខាងក្រោម ពិតជាបានចុះឈ្មោះ និងមានឈ្មោះក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោតក្នុងឃុំ សង្កាត់ខាងលើប្រាកដមែន។

| ល.រ | នាមត្រកូល នាមខ្លួន | ភេទ | ថ្ងៃខែឆ្នាំកំណើត | ល.រ ក្នុងបញ្ជីបោះឆ្នោត | កាត.បោះឆ្នោត លេខ | អាសយដ្ឋានបច្ចុប្បន្ន |
|---|---|---|---|---|---|---|
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |

លិខិតបញ្ជាក់នេះ ចេញឱ្យសាមីខ្លួនសម្រាប់ប្រើប្រាស់បំពេញលក្ខខណ្ឌ ដើម្បីចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ឆ្នាំ............។

ថ្ងៃ............................ខែ..............ឆ្នាំ..........................ព.ស............

..............................ថ្ងៃទី.................ខែ.................ឆ្នាំ...............

**ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ និងជាមេឃុំ ចៅសង្កាត់**

**ហត្ថលេខា និងត្រា**

ឯកសារសម្រាប់ភ្ជាប់ជាមួយទម្រង់បែបបទលេខ ១០០៨ ពាក្យសុំចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយ និងសេចក្ដីសម្រេចរបស់ គឃ.សប

# ជីវប្រវត្តិសង្ខេប
# និងសេចក្តីប្រកាសយល់ព្រមឈរឈ្មោះរបស់បេក្ខជន

៤ x ៦
(បិទ ១សន្លឹក)
(ភ្ជាប់ ៣សន្លឹក)

## I. ជីវប្រវត្តិសង្ខេប

### ក. សាមីខ្លួន

- ឈ្មោះ..................................................................ភេទ...............................
- ថ្ងៃខែឆ្នាំកំណើត:..................................................................................................................
- ទីកន្លែងកំណើត:..................................................................................................................
- អាសយដ្ឋាន:..................................................................................................................
- មុខងារបច្ចុប្បន្ន:..................................................................................................................
- កម្រិតវប្បធម៌:

..................................................................................................................................
..................................................................................................................................
..................................................................................................................................
..................................................................................................................................
..................................................................................................................................

- មុខងារកន្លងមក:

..................................................................................................................................
..................................................................................................................................
..................................................................................................................................
..................................................................................................................................
..................................................................................................................................

### ខ. ប្រពន្ធ ឬ ប្តី និង កូន

- ប្រពន្ធ ឬ ប្តី ឈ្មោះ.........................................................................................អាយុ................ឆ្នាំ
- មុខរបរ..................................................................................................................
- មានកូន......................នាក់ ប្រុស..................នាក់ ស្រី..................នាក់

| ល.រ. | នាមត្រកូល នាមខ្លួន | ភេទ | អាយុ | មុខរបរ |
|---|---|---|---|---|
| | | | | |
| | | | | |
| | | | | |
| | | | | |

| ល.រ. | នាមត្រកូល នាមខ្លួន | ភេទ | អាយុ | មុខរបរ |
|---|---|---|---|---|
| | | | | |
| | | | | |
| | | | | |
| | | | | |

**គ. ឪពុក ម្តាយ**

- ឪពុកឈ្មោះ............................................អាយុ................ឆ្នាំ មុខរបរ............................................
- ម្តាយឈ្មោះ............................................អាយុ................ឆ្នាំ មុខរបរ............................................

ខ្ញុំសូមប្រកាសថា សេចក្តីរាយការណ៍ក្នុងជីវប្រវត្តិសង្ខេបនេះ ពិតជាត្រឹមត្រូវ។

## II. សេចក្តីប្រកាសយល់ព្រមឈរឈ្មោះរបស់បេក្ខជន

ខ្ញុំសូមប្រកាស យល់ព្រមឈរឈ្មោះជាបេក្ខជន និងទទួលយល់ព្រមលើការតែងតាំងជាបេក្ខជនតាមលំដាប់លេខរៀងនៅក្នុងបញ្ជីបេក្ខជននៃគណបក្ស:......................................................................................តែមួយគត់សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់......................................................................ឆ្នាំ...............នៃក្រុង ស្រុក ខណ្ឌ..........................................នៃរាជធានី ខេត្ត...........................................។

ថ្ងៃ.......................ខែ............ឆ្នាំ.....................ព.ស............

.......................ថ្ងៃទី..........ខែ...........ឆ្នាំ..............

**ហត្ថលេខា ឬ ស្នាមមេដៃសាមីខ្លួន**

**សេចក្តីបញ្ជាក់**

សូមបញ្ជាក់ថាហត្ថលេខា ឬស្នាមមេដៃខាងស្តាំនេះ

ពិតជារបស់លោក-លោកស្រី............................................

ជាបេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា

នៅឃុំ សង្កាត់...........................................................

នៃគណបក្ស..............................................................

ពិតប្រាកដមែន។

ថ្ងៃ.......................ខែ............ឆ្នាំ.....................ព.ស............

.......................ថ្ងៃទី..........ខែ...........ឆ្នាំ................

**ប្រធានគណបក្ស ឬ តំណាង**

**ហត្ថលេខា និងត្រា**

ចំណាំ៖ បេក្ខជនត្រូវបំពេញជីវប្រវត្តិសង្ខេប និងសេចក្តីប្រកាសនេះដោយផ្ទាល់ខ្លួន។

ឯកសារសម្រាប់ភ្ជាប់ជាមួយទម្រង់បែបបទលេខ ១០០៨ ពាក្យសុំចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយ និងសេចក្តីសម្រេចរបស់ គឃ.សប

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

## លិខិតសន្យា

## របស់បេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ដែលជា មន្ត្រីរាជការស៊ីវិល មន្ត្រីតុលាការ កងយោធពលខេមរភូមិន្ទ នគរបាលជាតិ

យោងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ បទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី.........ឆ្នាំ.......... ដែលបានចែងអំពីករណីបេក្ខជនជាមន្ត្រីរាជការស៊ីវិល មន្ត្រីតុលាការ កងយោធពលខេមរភូមិន្ទ នគរបាលជាតិ ដែលមានបំណងឈរឈ្មោះជាបេក្ខជនបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវដាក់ពាក្យសុំច្បាប់ឈប់ពិសេសយ៉ាងតិច ៧ (ប្រាំពីរ) ថ្ងៃ មុនថ្ងៃបើកយុទ្ធនាការឃោសនាបោះឆ្នោតរហូតដល់ថ្ងៃប្រកាសលទ្ធផលនៃការបោះឆ្នោតជាផ្លូវការ។

ខ្ញុំបាទ-នាងខ្ញុំ..........................................................................................អាយុ........................ឆ្នាំ

ធ្វើការនៅ..........................................................................................................................................

មុខងារ...............................................................................................................................................

ជាបេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់..................................................

លេខកូដ:/ / / / រាជធានី ខេត្ត..................................................លេខកូដ: / / /

នៃគណបក្ស:........................................................................................................................................

សូមប្រកាសជាឱឡារិកថា នឹងគោរពច្បាប់ស្តីពីការបោះឆ្នោត ច្បាប់ស្តីពីគណបក្សនយោបាយ បទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប ក្រមសីលធម៌សម្រាប់គណបក្សនយោបាយ បេក្ខជន និងភ្នាក់ងារគណបក្សនយោបាយក្នុងដំណើរការបោះឆ្នោត។ ខ្ញុំបាទ-នាងខ្ញុំ សូមសន្យាថា នឹងប្រគល់លិខិតអនុញ្ញាតច្បាប់ឈប់ពិសេស ចេញដោយស្ថាប័ន ដែលខ្ញុំបាទ-នាងខ្ញុំបំពេញការងារជូន គឃ.សប ទៅតាមពេលវេលាដូចមានចែងក្នុងមាត្រានៃច្បាប់ខាងលើកំណត់។

ថ្ងៃ..............................ខែ............ឆ្នាំ.........................ព.ស............

..............................ថ្ងៃទី................ខែ................ឆ្នាំ................

**ហត្ថលេខា និងឈ្មោះសាមីខ្លួន**

ឯកសារសម្រាប់ភ្ជាប់ជាមួយទម្រង់បែបបទលេខ ១០០៨ ពាក្យសុំចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយ និងសេចក្តីសម្រេចរបស់ គឃ.សប

## ឈ្មោះគណបក្សនយោបាយ

**ជាអក្សរពេញ** :.......................................................................................................................

**ជាអក្សរកាត់** :.......................................................................................................................

**រូបសញ្ញាគណបក្ស** (រូបស-ខ្មៅ) **ទំហំ ៖ អង្កត់ផ្ចិត ៦០មម (រង្វង់) ឬ៦០មម x ៦០មម**

ថ្ងៃ...............................ខែ............ឆ្នាំ.......................ព.ស............

..............................ថ្ងៃទី................ខែ................ឆ្នាំ...............

**ប្រធានគណបក្ស ឬតំណាង**

**ហត្ថលេខា និងត្រា**

ឯកសារសម្រាប់ភ្ជាប់ជាមួយទម្រង់បែបបទលេខ ១០០៨ ពាក្យសុំចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយ និងសេចក្តីសម្រេចរបស់ គឃ.សប

# ឧបសម្ព័ន្ធទី ២
# កំណត់ហេតុនៃការចាប់ឆ្នោតដើម្បីកំណត់លំដាប់លេខរៀង គណបក្សនយោបាយដែលត្រូវដាក់លើសន្លឹកឆ្នោតក្នុងឃុំ សង្កាត់ (ឧ.១១២១)

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**កំណត់ហេតុនៃការចាប់ឆ្នោតដើម្បីកំណត់លំដាប់លេខរៀងគណបក្សនយោបាយ ដែលត្រូវដាក់លើសន្លឹកឆ្នោតក្នុងឃុំ សង្កាត់ (ឧ.១១២១)**

**១- លក្ខណៈសម្គាល់នៃឃុំ សង្កាត់**

| | | | | |
|---|---|---|---|---|
| ឈ្មោះ និងលេខកូដឃុំ សង្កាត់ | | | | |
| ឈ្មោះ និងលេខកូដរាជធានី ខេត្ត | | | | |

**២- លទ្ធផលនៃការចាប់ឆ្នោតដើម្បីកំណត់លំដាប់លេខរៀងគណបក្សនយោបាយលើសន្លឹកឆ្នោត**

- បញ្ជីបេក្ខជននៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតផ្លូវការបានបិទផ្សាយនៅថ្ងៃទី........ខែ.........ឆ្នាំ........
- បញ្ជីបេក្ខជននៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតមានចំនួន..............................................គណបក្ស
- ការចាប់ឆ្នោតធ្វើនៅម៉ោង........................ថ្ងៃទី........................ខែ........................ឆ្នាំ........................
- ការចាប់ឆ្នោតធ្វើដោយព្រះសង្ឃ ☐ ឬឥស្សរជនចូលនិវត្តន៍ ☐ ឬចាស់ព្រឹទ្ធាចារ្យ ☐

លទ្ធផលនៃការចាប់ឆ្នោតកំណត់លំដាប់លេខរៀងលើសន្លឹកឆ្នោត ៖

| លំដាប់លេខរៀង | ឈ្មោះគណបក្សនយោបាយ | លំដាប់លេខរៀង | ឈ្មោះគណបក្សនយោបាយ |
|---|---|---|---|
| ១ | | ៦ | |
| ២ | | ៧ | |
| ៣ | | ៨ | |
| ៤ | | ៩ | |
| ៥ | | ១០ | |

ការចាប់ឆ្នោតបញ្ចប់នៅម៉ោង......................................ថ្ងៃខែឆ្នាំដដែល ។

**៣- តំណាងគណបក្សនយោបាយដែលបានចូលរួមក្នុងពិធីចាប់ឆ្នោតដើម្បីកំណត់លំដាប់លេខរៀងគណបក្សនយោបាយលើសន្លឹកឆ្នោត**

| ល.រ | ឈ្មោះគណបក្សនយោបាយ | ហត្ថលេខា | ល.រ | ឈ្មោះគណបក្សនយោបាយ | ហត្ថលេខា |
|---|---|---|---|---|---|
| ១ | | | ៦ | | |
| ២ | | | ៧ | | |
| ៣ | | | ៨ | | |
| ៤ | | | ៩ | | |
| ៥ | | | ១០ | | |

ថ្ងៃ________________ ខែ________ ឆ្នាំ________________ ព.ស.__________

................................ ថ្ងៃទី__________ ខែ__________ ឆ្នាំ ..............

**ជ.គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត**

**ប្រធាន** សមាជិកទទួលបន្ទុករដ្ឋបាល..........................

ហត្ថលេខា ត្រា និងឈ្មោះ

**កំណត់សម្គាល់ ៖** ទម្រង់បែបបទនេះបំពេញចំនួន ៤ ច្បាប់ ផ្ញើជូន គ.ជ.ប (នាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម) ១ ច្បាប់ ផ្ញើជូន គធ.ខប ១ ច្បាប់ បិទផ្សាយ ១ ច្បាប់ និងរក្សាទុកជាឯកសារនៅ គឃ.សប ១ ច្បាប់ ។

..............................................................................................................................................

ទម្រង់បែបបទ ១១២១ សម្រាប់បំពេញដោយ គឃ.សប

# ឧបសម្ព័ន្ធទី ៣

## ទម្រង់បែបបទពាក្យបណ្តឹង (ទ.១២០២)

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

## ពាក្យបណ្តឹង (ទ.១២០២)

**I. សម្រាប់អ្នកប្តឹង**

១. អត្តសញ្ញាណអ្នកប្តឹង

- ឈ្មោះអ្នកប្តឹង ៖ ........................ ភេទ ........ ថ្ងៃខែឆ្នាំកំណើត ........................
- ទីលំនៅបច្ចុប្បន្ន ៖ ផ្ទះលេខ ........ ផ្លូវ ........ ភូមិ ........ ឃុំ សង្កាត់ ........
  ក្រុង ស្រុក ខណ្ឌ ........................ រាជធានី ខេត្ត ........................
- តួនាទី/មុខងារ ៖ ☐ប្រជាពលរដ្ឋ ☐ភ្នាក់ងារគណបក្សនយោបាយ ........................
  ☐ផ្សេងៗ ........................ ទូរស័ព្ទទាក់ទង ........................

២. លក្ខណៈសម្គាល់នៃទីកន្លែងពាក់ព័ន្ធនឹងបណ្តឹង

| រាជធានី ខេត្ត | | | ក្រុង ស្រុក ខណ្ឌ | ឃុំ សង្កាត់ | | | | លេខកូដការិយាល័យ | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| លេខកូដ | | | | លេខកូដ | | | | | | | |

៣. កម្មវត្ថុនៃបណ្តឹង ៖ ..............................................................
..............................................................
..............................................................
..............................................................

៤. មូលហេតុនៃការប្តឹង ៖ ..............................................................
..............................................................
..............................................................
..............................................................
..............................................................
..............................................................
..............................................................
..............................................................(ករណីត្រូវការបន្ថែមសូមសរសេរនៅខាងខ្នង)

៥. កាលបរិច្ឆេទ ៖ ........../........../..........

៦. ហត្ថលេខា ឬស្នាមមេដៃអ្នកប្តឹង (ប្រសិនបើអ្នកជាតំណាង ត្រូវមានលិខិតផ្ទេរសិទ្ធិជាលាយលក្ខណ៍អក្សរភ្ជាប់មកជាមួយ)

**II. សម្រាប់មន្ត្រីទទួលបន្ទុកការងារបោះឆ្នោត**

ថ្ងៃ ........ ខែ ........ ឆ្នាំ ........ ព.ស. ........
........................ ថ្ងៃទី ........ ខែ ........ ឆ្នាំ ........

| លេខពាក្យបណ្តឹង | កាលបរិច្ឆេទទទួលពាក្យបណ្តឹង | កាលបរិច្ឆេទប្រជុំសម្រេច ឬបើកសវនាការ |
|---|---|---|
| | ........../........../.......... | |
| .................... | ម៉ោង ........ ព្រឹក☐, រសៀល☐ | ........../........../.......... |

**ហត្ថលេខា និងត្រា**

ទម្រង់បែបបទលេខ ១២០២ សម្រាប់បំពេញដោយអ្នកប្តឹងតវ៉ា ឬប្តឹងជំទាស់

# ឧបសម្ព័ន្ធទី ៤
## ទម្រង់បែបបទសម្រង់សេចក្ដីសម្រេច ( ឧ.១២០៣ )

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

### សម្រង់សេចក្ដីសម្រេច (ឧ.១២០៣)

១. លេខបណ្ដឹង/សំណុំរឿង និងសេចក្ដីសម្រេច

- បណ្ដឹង/សំណុំរឿងលេខ.................... ចុះថ្ងៃទី.......... ខែ.......... ឆ្នាំ.......... វេលាម៉ោង..........
- សេចក្ដីសម្រេចលេខ.................... ចុះថ្ងៃទី.......... ខែ.......... ឆ្នាំ..........

២. អត្តសញ្ញាណអ្នកប្ដឹង

- ឈ្មោះអ្នកប្ដឹង.................... ភេទ.......... ថ្ងៃខែឆ្នាំកំណើត..........
- ទីលំនៅបច្ចុប្បន្នផ្ទះលេខ.......... ផ្លូវ.......... ភូមិ.......... ឃុំ សង្កាត់..........
  ក្រុង ស្រុក ខណ្ឌ.................... រាជធានី ខេត្ត..........
- តួនាទី/មុខងារ....................

៣. កម្មវត្ថុនៃបណ្ដឹង....................

....................

....................

៤. លក្ខណៈសម្គាល់នៃទីកន្លែងពាក់ព័ន្ធនឹងបណ្ដឹង

| រាជធានី ខេត្ត | | |
|---|---|---|
| លេខកូដ | | |

| ក្រុង ស្រុក ខណ្ឌ |
|---|
| |

| ឃុំ សង្កាត់ | | | |
|---|---|---|---|
| លេខកូដ | | | |

| លេខកូដការិយាល័យ | | | |
|---|---|---|---|
| | | | |

### សម្រេច

....................

**បានស្រង់ត្រឹមត្រូវតាមច្បាប់ដើម**

ថ្ងៃ.................... ខែ.......... ឆ្នាំ.......... ព.ស..........

.................... ថ្ងៃទី.......... ខែ.......... ឆ្នាំ..........

**បានឃើញ**
**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ ឬអង្គប្រជុំសម្រេច**
**ហត្ថលេខា និងត្រា**

**លេខាធិការសវនាការ ឬអង្គប្រជុំសម្រេច**
**ហត្ថលេខា**

ទម្រង់បែបបទលេខ ១២០៣ សម្រាប់បំពេញដោយក្រុមប្រឹក្សាជំនុំជម្រះ ឬអង្គប្រជុំសម្រេច

# ឧបសម្ព័ន្ធទី ៥
# បទបញ្ជាផ្ទៃក្នុងពេលបើកអង្គប្រជុំផ្សះផ្សា ឬអង្គប្រជុំសម្រេច ឬសវនាការដោះស្រាយពាក្យបណ្តឹង

ដើម្បីរក្សាសណ្តាប់ធ្នាប់ របៀបរៀបរយ សុវត្ថិភាព និងសន្តិសុខក្នុងបន្ទប់ប្រជុំផ្សះផ្សា ឬបន្ទប់ប្រជុំសម្រេច ឬបន្ទប់សវនាការ ជនគ្រប់រូបដែលមានវត្តមានក្នុងបន្ទប់ប្រជុំផ្សះផ្សា ឬបន្ទប់ប្រជុំសម្រេច ឬបន្ទប់សវនាការត្រូវគោរព និងអនុវត្តបទបញ្ជាដូចតទៅ៖

១. ហាមជក់បារីក្នុងបន្ទប់ប្រជុំផ្សះផ្សា ឬបន្ទប់ប្រជុំសម្រេច ឬបន្ទប់សវនាការ។

២. ហាមបង្កភាពអនាធិបតេយ្យក្នុងបន្ទប់ប្រជុំផ្សះផ្សា ឬបន្ទប់ប្រជុំសម្រេច ឬបន្ទប់សវនាការដូចជា៖
   - ការដើរឆ្លងកាត់ ឬដើរចេញ-ចូលរហោតរហូត ដោយគ្មានការអនុញ្ញាត
   - ការជជែកគ្នាខ្លាំងៗ ឬស្រែកឡូឡា ឬបង្កសំឡេងរំខានផ្សេងៗ។

៣. ហាមយកក្មេងអាយុក្រោម១៨ឆ្នាំ ចូលក្នុងបន្ទប់ប្រជុំផ្សះផ្សា ឬបន្ទប់ប្រជុំសម្រេច ឬបន្ទប់សវនាការ លើកលែងតែមានការអនុញ្ញាតជាមុនពីក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះ។

៤. ហាមយកអាវុធជាតិផ្ទុះ សារធាតុពុល និងវត្ថុគ្រោះថ្នាក់ផ្សេងៗចូលក្នុងបន្ទប់ប្រជុំផ្សះផ្សា ឬបន្ទប់ប្រជុំសម្រេច ឬបន្ទប់សវនាការ។

៥. ហាមថតរូប និងអាត់សំឡេង លើកលែងតែមានការអនុញ្ញាតពីប្រធានក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬប្រធានក្រុមប្រឹក្សាប្រជុំសម្រេច ឬប្រធានក្រុមប្រឹក្សាជំនុំជម្រះ។

៦. ហាមប្រើប្រាស់ទូរសព្ទដៃ វិទ្យុទាក់ទង សម្ភារបរិក្ខារ បរិធានដែលអាចថតរូប វីដេអូ និងសំឡេងផ្សេងៗក្នុងបន្ទប់ប្រជុំផ្សះផ្សា ឬបន្ទប់ប្រជុំសម្រេច ឬបន្ទប់សវនាការ។

៧. ក្នុងករណីជនណាបង្កបញ្ហាអ្វីមួយដែលក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះយល់ឃើញថា ធ្វើឱ្យមានការប៉ះពាល់ដល់របៀបរៀបរយការប្រជុំផ្សះផ្សា ឬការប្រជុំសម្រេច ឬសវនាការ ក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះអាចបណ្តេញជននោះចេញពីបន្ទប់ប្រជុំផ្សះផ្សា ឬបន្ទប់ប្រជុំសម្រេច ឬបន្ទប់សវនាការ។

ជនណាមិនគោរពបទបញ្ជានេះ ឬបង្កភាពវឹកវរក្នុងពេលប្រជុំផ្សះផ្សា ឬប្រជុំសម្រេច ឬសវនាការត្រូវទទួលទោសតាមច្បាប់ជាធរមាន។

## ឧបសម្ព័ន្ធទី ៦
## នីតិវិធី និងខ្លឹមសារនៃសម្បថ

ការធ្វើសច្ចាប្រណិធានត្រូវដឹកនាំធ្វើឡើងដោយលេខាធិការអង្គប្រជុំសម្រេច ឬគណៈលេខាធិការសវនាការ ហើយត្រូវធ្វើនៅចំពោះមុខវត្ថុសក្តិសិទ្ធិនៅទីកន្លែងបើកអង្គប្រជុំសម្រេច ឬសវនាការនីមួយៗ។

មុននឹងចាប់ផ្តើមធ្វើសម្បថ អ្នកស្បថត្រូវអុជទៀនធូបបូជានៅចំពោះមុខវត្ថុសក្តិសិទ្ធិដែលខ្លួនត្រូវស្បថនោះ។ បន្ទាប់មកលេខាធិការអង្គប្រជុំសម្រេច ឬសមាជិកគណៈលេខាធិការសវនាការត្រូវអានប្រារព្ធវាទខ្លាំងៗ ច្បាស់ៗឱ្យអ្នកស្បថស្តាប់ រួចអានពាក្យសច្ចាប្រណិធានឱ្យអ្នកស្បថថាតាម។

ក្រោយពីធ្វើសម្បថរួច លេខាធិការអង្គប្រជុំសម្រេច ឬគណៈលេខាធិការសវនាការត្រូវធ្វើកំណត់ហេតុនៃការធ្វើសម្បថនោះ ដោយបញ្ជាក់ថាបានធ្វើត្រឹមត្រូវ ហើយសេចក្តីបានចេញវាចាឱ្យស្បថយ៉ាងណា ត្រូវកត់ក្នុងកំណត់ហេតុយ៉ាងនោះផង។

### ប្រារព្ធវាទ

បពិត្រអស់ទេព្រក្ស អារុក្ខអារក្ស អ្នកតា និងបារមីដ៏សក្តិសិទ្ធិ មានព្រះអង្គដងកើ ព្រះអង្គក្រពុំឈូក ព្រះអង្គស្វេតច្ឆត្រ ព្រះអង្គចេក ព្រះអង្គចម អ្នកតាឃ្លាំងមឿង អ្នកតាក្រហមក លោកតាដំបងដែក លោកតាដំបងគ្រញូង លោកយាយទេព ព្រះអង្គវិហារសួគ៌ ព្រះអង្គព្រះជីវរវត្តបារាយណ៍ ព្រះអង្គវត្តភ្នំខ្លែងជាដើម សូមយាងអញ្ជើញមកធ្វើជាអធិបតីក្នុងពិធីសម្បថនេះ ដ្បិតគូភាគីនេះបានឈ្លោះទាស់ទែងគ្នា ហើយអះអាងលើសាក្សីថាជាអ្នកបានដឹង បានឃើញ បានឮ និងបានចាំដោយផ្ទាល់ ហើយច្បាប់តម្រូវឱ្យអ្នកទាំងនេះមកធ្វើជាសាក្សីឱ្យឆ្លើយឱ្យបានទៀងត្រង់តាមការណ៍ពិត។

បើអ្នកណាឆ្លើយមិនពិតតាមដែលខ្លួនបានដឹង បានឃើញ បានឮ និងបានចាំទេ សូមអស់ទេព្រក្ស អារុក្ខអារក្ស អ្នកតា យាយទេព និងបារមីដ៏សក្តិសិទ្ធិ បំផ្លាញឱ្យលាញ ឱ្យស្លាប់តែហោងយ៉ាងវេទនា ដោយគ្រាប់កាំភ្លើង រន្ទះបាញ់ ខ្លាខាំ ពស់ចឹក លុះអនាគតជាតិឱ្យព្រាត់ប្រាសឪពុកម្តាយបងប្អូន កូនចៅ ឱ្យក្ររហេមរហាម ខ្សត់ទ្រព្យ រងទុក្ខវេទនាអស់ប្រាំរយជាតិ។

បើអ្នកណាឆ្លើយឱ្យការណ៍ដោយពិតត្រង់ មិនវៀចវេរ មិនភូតកុហក មិនលម្អៀង ព្រោះជាញាតិសាលោហិត មិនសមគំនិតព្រោះខ្លាច ព្រោះស្អប់ ព្រោះលាភសក្ការៈ ព្រោះស៊ីសំណូកទេ សូមអស់ទេព្រក្ស អារុក្ខអារក្ស អ្នកតា យាយទេព និងបារមីដ៏សក្តិសិទ្ធិក្នុងលោកជួយឱ្យគេមានអាយុយឺនយូរមានសុខភាពល្អ មានទ្រព្យសម្បត្តិសម្បូរណ៍ហូរហៀរ មានញាតិផៅគោរពស្រឡាញ់រាប់អានលុះអនាគតជាតិបានជួបតែសេចក្តីល្អ ចម្រុងចម្រើន ថ្កុំថ្កើង រុងរឿងសមដូចប្រាថ្នាកុំបីអាក់ខានឡើយ។

### ពាក្យសច្ចាប្រណិធាន

ខ្ញុំសូមឆ្លើយតែការពិតដែលខ្ញុំបានឃើញ បានឮ បានដឹង និងបានចាំផ្ទាល់។ បើខ្ញុំឆ្លើយមិនពិតដោយប្រការណាមួយ សូមអស់ទេព្រក្ស អារក្ស អ្នកតា និងបារមីដ៏សក្តិសិទ្ធិ ទាំងអស់បរាមុខខ្ញុំឱ្យវិនាសលាញ អន្តរាយទ្រព្យសម្បត្តិ និងស្លាប់តែហោងយ៉ាងវេទនា តែបើខ្ញុំឆ្លើយពិតត្រង់ សូមទេវតាជួយឱ្យខ្ញុំមានទ្រព្យសម្បត្តិសម្បូរណ៍ហូរហៀរ និងរស់នៅប្រកបដោយសេចក្តីសុខក្សេមក្សាន្តជួបជុំបងប្អូន កូនចៅ ញាតិផៅសន្តានជារៀងរហូតគ្រប់ជាតិកុំបីអាក់ខានឡើយ។

# គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

បោះពុម្ពផ្សាយដោយ
គ.ជ.ប

ឆ្នាំ ២០២២

អាសយដ្ឋាន ៖ វិថីរដ្ឋសភា សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
ទូរស័ព្ទ : ០២៣ ២៣៥ ២៧១

St., Ratsaphea Tonle Basac, Khan Chamkar Mon, Phnom Penh, Cambodia
អ៊ីម៉ែល : info@nec.gov.kh